ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ២០ ឧសភា
- មជ្ឈមណ្ឌលឯកសារកម្ពុជាប្រារព្ធ "ទិវា ២០ ឧសភា" បង្សុកូលឧទ្ទិសកុសលដល់អ្នកស្លាប់ដែលគ្មានសាច់ញាតិ នៅហោអដ្ឋិធាតុ (បណ្ណាល័យធាតុ) វត្តលង្កា ព្រះកុសុមារាម ក្រុងភ្នំពេញ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣០៥ ខែឧសភា ឆ្នាំ២០២៥

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


- ២០ឧសភា......................................១


### ផ្នែកឯកសារ


- ខ្វេន ង៉ុក ហៅ ឡេង៖ លេខាវរសេនាតូច......... ៥
- ឆោម សារ៉ាត៖ លេខាស្រុកឆ្លូង តំបន់២១ ...... ៩


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- សិស្សអនុវិទ្យាល័យថ្នាត មកអានឯកសារនិង សិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រ...............១២
- គរុសិស្សឆ្នាំទី១ ជំនាញប្រវត្តិវិទ្យា នៃមជ្ឈមណ្ឌល គរុកោសល្យភូមិភាគខេត្តកំពង់ចាម ............ ១៦
- សិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ... ១៩
- សិស្សអនុវិទ្យាល័យលំទង អានឯកសារ និងស្វែង យល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ................. ២១
- មជ្ឈមណ្ឌលឯកសារកម្ពុជាប្រារព្ធ "ទិវា ២០ឧសភា" បង្សុកូលឧទ្ទិសកុសល ......................... ២៤
- សង្គ្រាមមួយថ្ងៃនៅលើកោះតាង............... ២៨
- ជីវិតកុមារក្នុងរបបខ្មែរក្រហម.................. ៣១
- ចូលរៀនពេទ្យនៅប្រទេសវៀតណាម.......... ៣៣
- នាង មាន៖ ខ្ញុំពិការ តែខ្ញុំមិនសោកស្តាយទេ... ៣៦
- ម្តាយរបស់ តុល ត្រូវបានខ្មែរក្រហមបង្ខំ....... ៣៨
- យិត ភឿន៖ កម្មផលរបស់ខ្ញុំ ..................... ៤០
- «អតីតកម្មាភិបាលជនជាតិដើមភាគតិចទំពួន .. ៤២
- សួស សារឿន៖ កងសែងអ្នករបួស ........... ៤៥
- ហែម ហ៊ិន៖ ជនជាតិដើមភាគតិចព័រ........... ៤៨


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- ការអប់រំពីអំពើប្រល័យពូជសាសន៍ .............៥៣
- អគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ- ..... ៥៨
- មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំ វេទិកា ពិភាក្សា និងស្វែងយល់ពី.........................៦០




ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដែលសព្វថ្ងៃស្ថិតនៅ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកស្រាវជ្រាវរកគ្រួសារ


- សុខ ភ័ណ្ឌ៖ ម្តាយខ្ញុំគិតថាខ្ញុំបានស្លាប់........... ៦៤



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧ ៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** សួត វិចិត្រ, លី ដេវីត, ទូច វណ្ណេត, ថុន ស្រីពេជ្រ, ភា រស្មី, សុខ វណ្ណៈ, ឡុង ដានី, ចាន់ ណារិទ្ធ, ផេង ពង្សរ៉ាស៊ី, ស្រេង លីដា និង លី សុខឃាង

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ២០ ឧសភា

**សោម ប៊ុនថន**



អដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាតបឹងជើងឯក ក្រោយរបបខ្មែរក្រហមដួលរលំ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសន្និសីទអន្តរជាតិលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»។ នៅក្នុងឱកាសនោះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា «ស្ថាប័នរដ្ឋាភិបាល ទាំងអស់ ទាំងយោធា និង ស៊ីវិល ត្រូវតែគាំទ្រការងារអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយ។ យើងត្រូវតែធានាថា ការបង្រៀនប្រវត្តិសាស្ត្រត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវ នៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋនិងឯកជនចាប់ពីអនុវិទ្យាល័យរហូតដល់សាកលវិទ្យាល័យ ហើយគ្រូបង្រៀនទាំងអស់របស់យើង អាចចូលរួមជាកម្លាំង ដើម្បីផ្សព្វផ្សាយការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងសាលារៀនទូទាំងប្រទេស។ ការអប់រំពីអំពើប្រល័យពូជសាសន៍មិនចាំបាច់កំណត់ត្រឹមតែមេរៀនប្រវត្តិសាស្ត្រនោះទេ។ យើងក៏អាចបញ្ចូលទៅក្នុងមុខវិជ្ជាគ្រប់ប្រភេទ ចាប់ពីសីលធម៌ និងអក្សរសាស្ត្រខ្មែររហូតដល់ការសិក្សាពីភាពជាអ្នកដឹកនាំ និងការអភិវឌ្ឍន៍ជំនាញទន់ផ្សេងទៀតផងដែរ។ យើងក៏អាចស្វែងរកវិធីច្នៃប្រឌិតផ្សេងៗ ដើម្បីរៀបរាប់រឿងរ៉ាវពិបាកទាំងនេះ ទៅកាន់មនុស្សដែលមានវ័យ និង ជំនាន់ផ្សេងគ្នា រួមមាន តាមរយៈសិល្បៈ មាតិកាឌីជីថល ឬ គំនូរជីវចល ជាដើម»។



អដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាដបឹងជើងឯក ក្រោយរបបខ្មែរក្រហមដួលរលំ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



២០ឧសភា គឺជាទិវាចងកំហឹងនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៨៣។ នៅប្រទេសកម្ពុជា អត្ថន័យ និងការវែកញែកអំពី២០ឧសភាបានប្រែប្រួលជាច្រើនលើកច្រើនសារទៅតាមបរិបទប្រវត្តិសាស្ត្រនយោបាយ ការផ្សះផ្សាបង្រួបបង្រួមជាតិ និងការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ ទោះបីជាមានការលើកឡើងផ្សេងៗគ្នាពីការផ្លាស់ប្តូរទិវា ២០ឧសភា ជាច្រើនដំណាក់កាល ហើយបានដឹងយ៉ាងច្បាស់ពីប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏២០ឧសភានៅតែបង្កប់នូវអត្ថន័យ និងឆ្លុះបញ្ចាំងពីការការគស៊ូ ការឈឺចាប់ និងការបាត់បង់សម្រាប់ប្រជាជនកម្ពុជា ហើយនៅតែមានសារសំខាន់ដល់ក្មេងៗជំនាន់ក្រោយដើម្បីយល់ដឹង។

ជាប្រវត្តិសាស្ត្រ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ គឺជាថ្ងៃដែលមេដឹកនាំខ្មែរក្រហម ប្ករបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) កំណត់យកជាថ្ងៃបង្កើតសហករណ៍ដំបូងនៅប្រទេសកម្ពុជា នៅខែឧសភា ឆ្នាំ១៩៧៣ អំឡុងពេលតស៊ូប្រដាប់អាវុធប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ ថ្ងៃនេះគឺជាថ្ងៃដែលដីស្រែ ចម្ការ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជាត្រូវបានរួមបញ្ចូលគ្នាបង្កើតជាសហករណ៍ ហើយក្រោយមកប្រជាជនត្រូវបានបង្ខំឱ្យធ្វើការងារធ្ងន់ធ្ងរនៅតាមការដ្ឋាន បណ្តាលឱ្យបាក់កម្លាំង ជួបប្រទះភាពអត់ឃ្លាន ការបោទប្រកាន់ និងការសម្រិតសម្រាំងដើម្បីយកទៅសម្លាប់។ ២០ឧសភាធ្លាប់ត្រូវបានចាត់ទុកថាគឺជាថ្ងៃចាប់ផ្តើមកើតឡើងនូវអំពើប្រល័យពូជសាសន៍យ៉ាងទូលំទូលាយ នៅទូទាំងប្រទេសកម្ពុជាក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាស្ទើរគ្រប់ក្រុមគ្រួសារបានបាត់បង់សមាជិករបស់ខ្លួន និងមានប្រជាជនកម្ពុជាចន្លោះពី១,៨ លាន ទៅ២,២ លាននាក់ បានស្លាប់បាត់បង់ជីវិត ដូច្នេះហើយទើបរបបសាធារណរដ្ឋកម្ពុជា និងរដ្ឋកម្ពុជាបានកំណត់យកថ្ងៃទី២០ឧសភា គឺជាថ្ងៃបុណ្យជាតិយ៉ាងសំខាន់ និងត្រូវបានរៀបចំយ៉ាងហ្មត់ចត់។ ពិធីបុណ្យនេះត្រូវបានដាក់ឈ្មោះថា «ទិវាចងកំហឹង ២០ឧសភា» ហើយត្រូវបានប្រារព្ធឡើងនៅក្រុងភ្នំពេញ តាមខេត្ត ស្រុក ឃុំ និងភូមិ

នៅទូទាំងប្រទេសកម្ពុជា ដើម្បីថ្កោលទោសលើមេដឹកនាំ និងរបបខ្មែរក្រហមដែលបានប្រព្រឹត្តអំពើឃោរឃៅ និងការកាប់សម្លាប់មកលើប្រជាជនកម្ពុជា។ «ទិវាចងកំហឹង ២០ ឧសភា» គឺជានិន្នាការនយោបាយដើម្បីទប់ស្កាត់ការវិលត្រឡប់មកគ្រប់គ្រងប្រទេសវិញរបស់ក្រុមខ្មែរក្រហម។

ក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ រវាងភាគីជម្លោះនយោបាយនៅក្នុងប្រទេសកម្ពុជា ការប្រារព្ធ «ទិវាចងកំហឹង ២០ ឧសភា» លែងមានតួនាទីជាបុណ្យជាតិផ្លូវការទៀតហើយ ដោយសារជានិន្នាការដើម្បីបង្រួបបង្រួមជាតិ និងដើម្បីបញ្ចប់សង្គ្រាមស៊ីវិលដែលបានអូសបន្លាយជាងមួយទសវត្សរ៍ក្រោយរបបខ្មែរក្រហមដួលរលំពីទីក្រុងភ្នំពេញថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាសេចក្តីប្រាថ្នារបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេស។

ទោះបីជាយ៉ាងណា នៅឆ្នាំ១៩៩៨, ឆ្នាំ១៩៩៩ និង ឆ្នាំ២០០០ ទិវា ២០ ឧសភា ត្រូវបានសាលាក្រុងភ្នំពេញរៀបចំប្រារព្ធធ្វើនៅ «មជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បឹងជើងឯក» និងនៅតាមបណ្តាទីតាំងបូជនីយដ្ឋានកន្លែងតម្កល់អដ្ឋិធាតុនៅតាមខេត្ត ដោយដាក់ឈ្មោះថា «ទិវារំឭកវិញ្ញាណក្ខន្ធ» ដើម្បីរំឭកឡើងវិញពីការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម។

ដោយមានសំណើរពីរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និង សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សុំឱ្យសហគមន៍អន្តរជាតិកាត់ទោសអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ការចរចាររវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានកើតឡើងជាបន្តបន្ទាប់។ ជាលទ្ធផល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជា និងអង្គការសហប្រជាជាតិបានអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

កិច្ចព្រមព្រៀងស្តីពីការកាត់សេចក្តីឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានចូលជាធរមាន នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ហើយបន្ទាប់មកបានចាប់ផ្តើមសវនាលើសំណុំរឿង០០១ ដំបូងដែលមានជនសង្ស័យឈ្មោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១។

នៅថ្ងៃចាប់ផ្តើមអង្គសេចក្តីលើ កាំង ហ្គេចអ៊ាវ ហៅ ឌុច នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ មានមតិលើកឡើងពីសាធារណជន និងពីអង្គការក្រៅរដ្ឋាភិបាលមួយចំនួនស្នើរាជរដ្ឋាភិបាលកម្ពុជា កំណត់យកថ្ងៃសវនាការនេះជា «ទិវាជាតិនៃការចងចាំ» ប៉ុន្តែត្រូវបានការិយាល័យអ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រីបដិសេធដោយមូលហេតុថា ថ្ងៃទី៣០ ខែមីនា មិនត្រូវបានចាត់ទុកជាថ្ងៃផ្តល់យុត្តិធម៌ដំបូងដល់ជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមនោះទេ ព្រោះតុលាការធ្លាប់កាត់ទោសមេដឹកនាំកំពូលនៃរបបនេះកាលពីឆ្នាំ១៩៧៩។ កន្លងមកយើងធ្លាប់ចាត់ទុកថ្ងៃទី២០ ឧសភា គឺជា «ទិវាចងកំហឹង» ចំពោះរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយក្រោយមក ត្រូវប្តូរទៅជាទិវារំឭកវិញ្ញាណក្ខន្ធដល់ជនរួមជាតិបានស្លាប់ក្នុងរបបប្រល័យពូជសាសន៍។ ប្រសិនបើយកថ្ងៃទី៣០ ខែមីនា ជា «ទិវាជាតិ» នោះគឺជាការផ្តល់តម្លៃហួសពេកដល់ជនទាំងឡាយណាដែលធ្លាប់បានគាំទ្ររបបប្រល័យពូជសាសន៍ខ្មែរក្រហម ជាពិសេសក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ដោយបំភ្លេចចោលការពិតនៃប្រវត្តិសាស្ត្រដែលថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជាបានខិតខំរកយុត្តិធម៌ជូនប្រជាជន។

ទោះបីយ៉ាង នៅអំឡុងពេលដំណើរការកាត់ក្តីជាបន្តបន្ទាប់លើសំណុំរឿង០០២ ដែលមានជនជាប់ចោទ អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានស្នើសុំទៅសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋ

មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចេញអនុក្រឹត្យកំណត់យកថ្ងៃទី២០ ឧសភា ជា «ទិវាជាតិនៃការចងចាំ» ពាក់ព័ន្ធនឹងការរៀបចំគម្រោងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាការឆ្លើយតប នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ ទីស្តីការគណៈរដ្ឋមន្ត្រីយល់ព្រមតាមសំណើរនេះ ដោយកំណត់យកថ្ងៃទី២០ ឧសភា ជា «ទិវាជាតិនៃការចងចាំ» នៅក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ជំនួស «ទិវាចងកំហឹង ឬទិវារំឭកវិញ្ញាណក្ខន្ធ» ដែលបាននិងកំពុងប្រើប្រាស់ចាប់តាំងពីឆ្នាំ១៩៨៤ មកដល់សព្វថ្ងៃ។

ការផ្លាស់ប្តូរទិវា២០ ឧសភា នៅពេលនេះ គឺមិនមែនផ្លាស់ប្តូរប្រវត្តិសាស្ត្ររបបខ្មែរក្រហមនោះទេ ប៉ុន្តែជាផ្នែកមួយនៃការផ្តល់សំណងជំងឺចិត្ត ការផ្តល់យុត្តិធម៌ និងជាដំណើរការនៃការផ្សះផ្សាក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបច្ចុប្បន្នមានចំនួនប្រមាណ៥លាននាក់ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហមបិទបញ្ចប់ដំណើរការកាត់សេចក្តី។

នៅក្នុងនោះដែរ ចាប់តាំងពីឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅសិក្សាចំនួន៧សែនក្បាល (ឯកសារយោងដ៏សំខាន់) ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងបានចែកជូនសិស្សានុសិស្សនៅតាមវិទ្យាល័យប្រមាណជាង១០០០ នៅទូទាំងប្រទេសកម្ពុជាដើម្បីសិក្សារៀនសូត្រ, បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលប្រវត្តិវិទ្យាថ្នាក់ជាតិប្រមាណ ៥០០០នាក់រួមទាំងគ្រូអក្សរសាស្ត្រខ្មែរ និងគ្រូសីលធម៌ពលរដ្ឋវិជ្ជា, បានរៀបចំវេទិកាថ្នាក់រៀនរាប់ពាន់ថ្នាក់, បានអប់រំជាសាធារណស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, បានផ្សព្វផ្សាយ និងបានរៀបចំសន្និសីទជាច្រើន ដើម្បីលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាលើទូទាំងពិភពលោក។



ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៅខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្មករកំពុងជីកដីចាក់គ្រឹះសាងសង់ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាដបឹងជើងឯក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៅខេត្តពោធិ៍សាត់ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខៀន ង៉ុក ហៅ ឡេង ៖ លេខាវរសេនាតូច ៥០២ តំបន់១០៥ ភូមិភាគឦសាន

**មីន សាណាស់**

នៅឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទៅជា៦ភូមិភាគ ដែលក្នុងនោះមាន៣២តំបន់ៗ ភូមិភាគនីមួយៗត្រូវយកខេត្តចំនួន២ មកបូកបញ្ចូលគ្នា ឬខេត្តខ្លះគ្រាន់តែកាត់ស្រុកមួយ ឬច្រើនមកបញ្ចូលគ្នាៗ ភូមិភាគ និង តំបន់សុទ្ធតែត្រូវដាក់លេខសម្គាល់ៗ ក្នុងមួយភូមិភាគ ត្រូវចែកចេញជាច្រើនតំបន់ ហើយតំបន់នីមួយៗចែកចេញជាស្រុក និងសហករណ៍ៗ ចំណែកតំបន់១០៥ គឺស្ថិតនៅក្នុងភូមិភាគឦសាន ដែលមានប្រធានភូមិភាគឈ្មោះ ម៉ែន សាន ឈ្មោះបដិវត្តន៍ ណៃ សារ៉ាន់ ហៅ យ៉ា ដែលក្រោយមកត្រូវអង្គការចាប់ខ្លួន និងសម្លាប់ក្នុងឆ្នាំ១៩៧៦ បទចោទគឺក្បត់អង្គការបដិវត្តន៍ៗ ក្រោយពីការចាប់ខ្លួន ណៃ សារ៉ាន់ ហៅ យ៉ា អង្គការក៏បន្តស្រាវជ្រាវស្វែងរកចាប់ខ្មាំង ដែលជាខ្សែរយៈរបស់ យ៉ា ជាបន្តបន្ទាប់ៗ ដូចករណីឈ្មោះ ខៀន ង៉ុក ហៅ ឡេង មានតួនាទីជាលេខាវរសេនាតូច៥០២ នៃតំបន់១០៥ ក៏ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ៗ

ខាងក្រោមនេះជាប្រវត្តិរូប និងសកម្មភាពរបស់ ខៀន ង៉ុក ហៅ ឡេង៖

ខ្ញុំឈ្មោះ ខៀន ង៉ុក ហៅ ឡេង អាយុ៣៩ឆ្នាំ (១៩៧៨) ជាជនជាតិចារាយ កើតនៅភូមិសម ឃុំប៉ក ស្រុកបរកែវ ខេត្តរតនគិរីៗ កាលពីក្មេងខ្ញុំរស់នៅជាមួយឪពុកម្តាយដែលប្រកបរបរធ្វើស្រែ និងដាំដំណាំសម្រាប់លក់ដូរៗ ដល់អាយុ១៨ឆ្នាំ ខ្ញុំទទួលបានការអប់រំពីឈ្មោះ យ៉ាន មានតួនាទីជាគណៈឃុំប៉កឱ្យចូលធ្វើជានីរសាររត់សំបុត្រឱ្យឈ្មោះ ឌុន មានតួនាទីជាលេខាស្រុកបរកែវៗ ដល់ឆ្នាំ១៩៦០ ខ្ញុំបានទទួល



ជនជាតិដើមភាគតិចនៅខេត្តរតនគិរី ដែលជាកងឈ្លបបដិវត្តន៍ខ្មែរក្រហមបានដោតចំរូងទប់ស្កាត់ផ្លូវខ្មាំងកុំឱ្យចូលវាតត្បាតស្រុកភូមិ កាលពីអំឡុងឆ្នាំ១៩៦៨ និងឆ្នាំ១៩៦៩ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាទីជាកងការពារកម្មាភិបាលបដិវត្តន៍ក្នុងស្រុក និងតំបន់ៗ ដល់ពាក់កណ្តាលឆ្នាំ១៩៦០ កងកម្លាំងក្នុងជួរបដិវត្តន៍ ចង់ដឹងអំពីព័ត៌មានទាហាន លន់ នល់ ហេតុនេះ បងយ៉ាន និង បងឌុន ជាអ្នកគ្រប់គ្រងខ្ញុំផ្ទាល់ បានចាត់តាំងកម្លាំងបដិវត្តន៍ចំនួន៣០នាក់ឱ្យចូលរួមបង្កប់ជារូបភាពទាហានៗ ការចូលក្នុងជួរទាហាន លន់ នល់ គឺធ្វើតាមរយៈឈ្មោះ ហេង ជាទាហានស័ក្តិ២ ប្រចាំបន្ទាយបរកែវៗ បន្ទាប់មកទៀតឈ្មោះ ហេង បានឱ្យខ្ញុំ និងបក្ខពួកចូលទៅបន្ទាយដើម្បីហ្វឹកហាត់ៗ គ្រូបង្ហាត់ក្នុងជួរទាហាន លន់ នល់ ឈ្មោះ សែប អ៊ុនៗ

នៅក្នុងឆ្នាំ១៩៦១ អង្គការបានរើសកងទ័ពចំនួន១០០នាក់ រួមទាំងខ្ញុំឱ្យទៅហាត់បច្ចេកទេសយោធានៅប្រទេសវៀតណាមរយៈពេល២ឆ្នាំ។ ក្រោយពីបច្ចេកទេសយោធា ខ្ញុំ, ម៉ាន់ និង ញ៉ិរ ត្រូវបាន ស័ក្តិ៣ ខ្វែក ហៅឱ្យមកមន្ទីរយោធាគុនទូម ក្នុងគោលបំណងចង់ឱ្យរៀនឯកសារស្តីពីបក្សពលករវៀតណាម ដោយសំអាងថា ថ្ងៃទៅមុខ គឺខ្មែរ និងវៀតណាម ជាប្រទេសតែមួយ បក្សតែមួយ។ ក្រោយពីរៀនឯកសារបក្សពលករវៀតណាមបាន២ថ្ងៃ ស័ក្តិ៣ ខ្វែក បាននាំឈ្មោះ អាត ជាមេក្រុម ឱ្យមកជួបខ្ញុំទាំងបីនាក់ដើម្បីរៀបចំបញ្ចូលខ្ញុំទៅជាបក្សពលករតែម្តង។ ខ្វែក បានបញ្ជាក់ថា ចាប់ពីពេលនេះទៅ ទោះជាបីនាក់ខ្ញុំត្រឡប់ទៅប្រទេសវិញ ក៏មិនត្រូវភ្លេចបក្សពលករ ព្រោះដើម្បីឱ្យប្រទេសកម្ពុជាទៅជាប្រទេសតែមួយ។

ខែកញ្ញា ឆ្នាំ១៩៦៣ ខ្ញុំទាំងបីនាក់ក៏ត្រឡប់មកមន្ទីរតំបន់រតនគិរីវិញ។ ប៉ុន្តែអង្គការចាត់តាំងឱ្យរស់នៅបែកគ្នា ដោយ ម៉ាន់នៅ ខាងឃុំថ្មស្រាល, ញ៉ិរ នៅខាងឃុំបឡិក និង ខ្ញុំត្រូវនៅសមរភូមិ។ ដល់ខែមីនា ឆ្នាំ១៩៦៤ ខ្ញុំត្រឡប់ពីសមរភូមិវិញរំលងបាន៥ថ្ងៃ ម៉ាន់ បានផ្ញើសំបុត្រតាមឈ្មោះ ដន ជានីរសារភូមិឱ្យហៅខ្ញុំទៅភូមិម៉ក។ ខ្ញុំទៅដល់ភូមិម៉ក បានបន្តិចក៏ឃើញ ញ៉ិរ មកតាមដែរ។ មិត្តម៉ាន់ បានសួរខ្ញុំថា ឡេង ភ្លេចហើយ? ខ្ញុំតបថា អត់ភ្លេចទេ កសាងកម្លាំងបក្សពលករ។ ដល់ខែធ្នូ ឆ្នាំ១៩៦៤ អង្គការបានយកខ្ញុំមកនៅ ខាងមន្ទីរតំបន់រតនគិរី។ ខ្ញុំនៅក្នុងមន្ទីរបានមួយខែ ក៏កសាងបានកម្លាំងម្នាក់ឈ្មោះ រឿន អតីតប្រធានភូមិក្រហល បច្ចុប្បន្នជាប្រជាជនភូមិក្រហល។

ខែមីនា ឆ្នាំ១៩៦៧ អង្គការបានចាត់តាំងខ្ញុំឱ្យទៅនៅ ខាងកងទ័ពភាគ ដើម្បីយាមខ្មាំងនៅផ្លូវលេខ១៩ ហេតុនេះ ធ្វើឱ្យខ្ញុំដាច់ខ្សែរយៈអស់។ ស្ថិតនៅទីតាំងយាមខ្មាំងៗបានវាយបុកមកខ្លាំងពេក ខ្ញុំក៏រត់បោលកូនក្រុម ហើយខ្មាំងក៏កម្ទេចកម្លាំងទ័ពបដិវត្តន៍ជាបន្តបន្ទាប់។ ខែកញ្ញា ឆ្នាំ១៩៦៧ អង្គការហៅកម្មាភិបាលកងឈ្លបបដិវត្តន៍គ្រប់ជាន់ថ្នាក់ ចាប់ត្រឹមពីមេក្រុមឡើងមកឱ្យទៅរៀនផ្នែកនយោបាយនៅសាលា១០០របស់អង្គការ។ ក្រោយរៀនបានបីថ្ងៃខ្ញុំចាប់និយាយលេងសើចជាមួយមិត្តសុភា បច្ចុប្បន្នជាប្រធានសេនាធិការយោធាតំបន់១០៥ តែមិត្តសុភាបានសួរខ្ញុំអំពីការទៅរៀនសូត្រនៅប្រទេសវៀតណាមយ៉ាងម៉េចដែរ? ព្រោះ មិត្តសុភា ចង់ចូលរួមធ្វើសកម្មភាពក្នុងបក្សពលករវៀតណាម។ ខ្ញុំក៏ប្រាប់ពីខ្សែរយៈខាងខ្ញុំចំណែកមិត្តសុភា ក៏បានប្រាប់ខ្សែរយៈរបស់ខ្លួនមាន ខាំភូន, ថន និង បងយ៉ា។ ចំពោះបងយ៉ា គឺបានទាក់ទងជនជាតិវៀតណាមឈ្មោះ ធុច។ សូមបញ្ជាក់ថា ឈ្មោះ ខាំភូន មានតួនាទីជាប្រធានសេដ្ឋកិច្ចតំបន់១០៥ ( ស្លាប់ ), ថន ប្រធានដឹកជញ្ជូនរបស់តំបន់១០៥ ( ស្លាប់ ), ឈ្មោះ យ៉ា លេខាភូមិភាគឦសាន ត្រូវបានអង្គការចាប់ខ្លួន និង ឈ្មោះ ធុច ក្តាប់មិនបានតួនាទី។

ពាក់កណ្តាលឆ្នាំ១៩៦៨ អង្គការដកខ្ញុំចេញពីមន្ទីរតំបន់រួចបញ្ជូនមកនៅ ខាងកងទ័ពមជ្ឈិម តំបន់មណ្ឌលគិរី។ នៅទីតាំងនេះ ខ្ញុំបានជួបជាមួយ ម៉ាន់ ដែលមានតួនាទីជាប្រធានឈ្លប។ បន្ទាប់មកអង្គការបានឱ្យខ្ញុំទៅយកគ្រួសារនៅ ខាងសមរភូមិ មករស់នៅជុំគ្នាក្នុងតំបន់មជ្ឈិម។ ក្នុងពេលធ្វើដំណើរទៅសមរភូមិ ខ្ញុំជួបជាមួយខ្សែរយៈកាលទៅរៀននៅវៀតណាមជាច្រើន និងបានសួរនាំអំពីសុខទុក្ខ និងសកម្មភាពទាក់ទងផ្សេងៗ។ ដល់ខ្ញុំត្រឡប់មកពីយកគ្រួសារមកដល់តំបន់មជ្ឈិម អង្គការក៏បញ្ជូនខ្ញុំមកបោះទ័ពប្រចាំការនៅសមរភូមិពាមជីមាត។

ពាក់កណ្តាលឆ្នាំ១៩៦៩ កងទ័ពខ្ញុំ បូកជាមួយកងទ័ព សុភា បានវាយទាហាន លន់ នល់ ពីចំណុចពាមជីមាត ដល់សមរភូមិប៊ូស្រា។ បន្ទាប់មក ខ្ញុំក៏នាំ សុភា ទៅមន្ទីរយោធាវៀតណាមភ្នំមុទ្រូត តាមរយៈឈ្មោះ វាំង ដើម្បីសុំការអនុញ្ញាតទៅជួប ម៉ក ជាអ្នកបកប្រែភាសាវៀតណាម ពេលជួបជាមួយ ស័ក្តិ ៣ ខ្វែក។

នៅឆ្នាំ១៩៧១ ស្ថានការក្នុងប្រទេសក្រោយពីរដ្ឋប្រហាររបស់ លន់ នល់ រួច ប្រជាជនក្នុងជួរកងបដិវត្តន៍ កាន់តែវាយខ្មាំង ខ្លាំងជាងមុន។ ចំណែក ម៉ក បាននាំពាក្យ ស័ក្តិ៣ ខ្វែក បញ្ជាឱ្យក្រុមខ្ញុំលួចសម្លាប់គណៈតំបន់មណ្ឌលគិរី។ ក្នុងករណីបើសម្លាប់បាន គឺក្រុមខ្ញុំជាអ្នកគ្រប់គ្រងតំបន់មណ្ឌលគិរីជំនួស។ ពេលទទួលបញ្ជានេះរួច មិត្តសុភា ក៏ដឹកនាំហៅប្រជុំពិភាក្សានៅមន្ទីរក-១១ ដែលមានអ្នកចូលរួមដូចជា៖

ខាំភូន, ផន, សុភា និង ខ្ញុំ។ ប្រធានបទពិភាក្សាគឺ ១) ផែនការវៀតណាមឱ្យយើងសម្លាប់កម្មាភិបាលថ្នាក់តំបន់។ ២) មុនសម្លាប់ត្រូវរកវិធីកុំឱ្យមានអ្នកណាដឹង និង ៣) ត្រូវកសាងកម្លាំងតទៅមុខទៀត។ ចំពោះផែនការសម្លាប់គណៈតំបន់ ក្រុមខ្ញុំអនុវត្តរយៈពេល៣ខែ តែមិនបានសម្រេច។ បន្ទាប់មកទៀត កងទ័ពខ្ញុំត្រូវអង្គការដកឱ្យមកជួយវាយទ័ព លន់ នល់ នៅខាងខេត្តកំពង់ចាម រហូតឆ្នាំ១៩៧៣។

នៅខែមីនា ឆ្នាំ១៩៧៣ មិត្តសុភា បានហៅខ្ញុំមកប្រជុំម្តងទៀត នៅមន្ទីរក-១៦ ទាក់ទងផែនការមិនបានសម្រេចក្នុងការសម្លាប់គណៈតំបន់។ តែលើកនេះមានសមាជិកបន្ថែមម្នាក់ទៀតគឺឈ្មោះ ស្វាយ។ ដោយផែនការថ្មី សម្លាប់គណៈតំបន់មិនបានសម្រេច ត្រូវប្តូរមកសម្លាប់គណៈស្រុកវិញ ដោយក្នុងខែសីហា ឆ្នាំ១៩៧៣ គណៈស្រុកគ្រប់ស្រុកត្រូវមករៀននៅមន្ទីរក-១៧ ហេតុនេះ ស្វាយ មានតួនាទីលួចបាញ់រួចដកខ្លួនចូលទៅប្រទេសវៀតណាម។ ខាំភូន និង ផន បានរៀបចំកាំភ្លើងឱ្យ ស្វាយ ដល់ម៉ោង២យប់ ស្នូរកាំភ្លើងផ្ទុះឡើង៤គ្រាប់ ដែលស្វាយបាញ់ទៅលើ ដាំង និង គី ត្រូវស្លាប់ទាំងពីរនាក់។ ស្វាយ ក៏រត់ចូលព្រៃ តែរំលងបាន២ថ្ងៃ ស្វាយ ក៏ចងករសម្លាប់ខ្លួនឯង។

ដើមឆ្នាំ១៩៧៤ ខ្ញុំមានជំងឺល្បែង (ជំងឺរបេង) ហេតុនេះត្រូវមកសម្រាកនៅមន្ទីរពេទ្យតំបន់១០៥ ចំនួន ៦ខែ ដោយមិនបានចេញពីពេទ្យ និង គ្មានសកម្មភាពទាក់ទងខ្សែរយៈ។ ខែកញ្ញា ឆ្នាំ១៩៧៤ ខ្ញុំចេញពីមន្ទីរពេទ្យ រួចបន្តទៅមន្ទីរយោធាដដែល រំលងបានមួយខែ មិត្តដៃបាននាំកម្លាំងយុទ្ធជនកងតូចទី៣ ដែលជាប់ខ្សែរយៈ មិត្ត អឿន ប្រធានកងតូចទី៣ មកជួបខ្ញុំ។

នៅខែមីនា ឆ្នាំ១៩៧៥ ខ្ញុំបានទៅមន្ទីរកងធំទី២ នៅចំណុចក្រង់តេះ ជាប់ព្រំដែនវៀតណាម ដើម្បីរកផ្លូវទាក់ទងទៅលេងភ្នំមុទ្រេត តែអង្គភាពមិនឱ្យចូល។ ខ្ញុំត្រឡប់មកជួប សុភា វិញ ដើម្បីប្រាប់ដំណឹងថា មិនអាចទាក់ទងខ្សែរបស់ ម៉ីក បាន។ បន្តមកទៀត អង្គការមករៀបចំកងការពារតាមព្រំដែន ដែលមុខសញ្ញាខ្ញុំទាក់ទងផ្ទាល់តែម្តង។ ខែវិច្ឆិកា ឆ្នាំ១៩៧៥ សុភា បានកសាងកម្លាំងក្បត់ពីយោធា និង មន្ទីរមកប្រជុំនៅមន្ទីរក-១១ ដែលមានឈ្មោះដូចជា៖ ខ្ញុំ, បង ខាំភូន, មិត្ត ឡាន់ ជាលេខាវរសេនាតូច៤០៣ តំបន់១០៥, មិត្ត បាំង អនុលេខាវរសេនាតូច៤០៣, មិត្តចាន់ផន ប្រធានពាណិជ្ជកម្ម តំបន់១០៥, មិត្ត ដៃ អនុប្រធានកងធំទី១ វរសេនាតូច៥០២, មិត្តអឿន ប្រធានកងតូចទី៣ កងធំទី១, មិត្ត សុភាព ប្រធានសេនាធិការយោធាតំបន់១០៥។ ការជួបប្រជុំមួយនេះគឺនិយាយពីសកម្មភាពកន្លងមក និង បច្ចុប្បន្នអង្គការបានចាប់មិត្ត ភីនិត ជាខ្សែទាក់ទងយកទៅបាត់។

នៅឆ្នាំ១៩៧៦ ដោយសារខ្ញុំមានបញ្ហាខុសសីលធម៌ជាមួយនារី ឡូន នៅមន្ទីរតំបន់១០៥ អង្គការក៏ដកតំណែងខ្ញុំមកនៅជាយុទ្ធជនមន្ទីរតំបន់១០៥ រយៈពេល៤ខែ។ ក្រោយពី៤ខែ នៅក្នុងខែតុលា ឆ្នាំ១៩៧៦ ដដែល អង្គការបានចាត់តាំងដំឡើងតំណែងខ្ញុំវិញ មកតួនាទីដដែលគឺលេខាវរសេនាតូច៥០២។ ខ្ញុំបានចូលធ្វើការវិញភ្លាម មិត្តសុភា បានហៅទៅពិភាក្សា ដើម្បីឱ្យខ្ញុំទៅ ទាក់ទងជាមួយខាង វៀតណាម ព្រោះមិនបានទាក់ទងជាមួយមុខព្រួញវៀតណាមយូរមកហើយ។

ដល់ខែមករា ឆ្នាំ១៩៧៧ ឡាន់ បានជិះរថយន្តមកយកខ្ញុំ និង បន្តទៅយកមិត្ត ឡើម រួចបន្តដំណើរទៅយកមិត្ត សុភា នៅមន្ទីរក-១១។ ជុំគ្នាហើយ កម្លាំងយើងក៏បន្តដំណើរទៅមន្ទីរកងធំទី២ របស់វរសេនាតូច៥០២ ទុកដាក់ ឡាននៅត្រង់ចំណុច ចម្ការដាំកប្បាស នៅក្រង់តេះ ទើបបន្តដំណើរដោយថ្មើរជើងឆ្ពោះទៅមុខព្រួញមន្ទីរមុទ្រេត។ ចូលដល់មន្ទីរមុទ្រេត មិត្តសុភា ក៏ហុចសំបុត្រទៅឈ្មោះ ខាញ់ សុំជួប បង ម៉ីក។ ឈ្មោះ ខាញ់ ក៏ឱ្យកងការពារយកសំបុត្រទៅជូនម៉ីក នៅដាក់ ឡាក់១។ បន្តិចក្រោយមក ម៉ីក បានមកដល់មន្ទីរ ដើរមកចាប់ដៃក្រុមខ្ញុំ មាត់និយាយថា ខានធ្វើការជាមួយគ្នាយូរមកហើយ។ ម៉ីក ក៏សុំឱ្យមិត្តឡើងរាយការណ៍ ៣ចំណុចគឺ៖ ១) អំពីសភាពការណ៍បដិវត្តន៍កម្ពុជា ខ្លាំង ឬខ្សោយ។ ២) កសាងកម្លាំងបានប៉ុន្មាន ឈ្មោះអ្វីខ្លះ? រស់នៅទីណាខ្លះ? និង ៣) កម្ទេចកម្មាភិបាលបដិវត្តន៍កម្ពុជាបានប៉ុន្មាននាក់ហើយ? មិត្តសុភា ឡើងធ្វើរបាយការណ៍ជូនរួចក៏នាំគ្នាត្រឡប់មកទីតាំងរៀងៗខ្លួនវិញ។ ដល់ខែកញ្ញា ឆ្នាំ១៩៧៧ អង្គការបានឱ្យខ្ញុំឡើងមករៀននៅទីក្រុង

ភ្នំពេញរយៈពេល៧ថ្ងៃ។ ពេលឡើងមករៀនខ្ញុំគ្មានសកម្មភាពទាក់ទងខ្សែរយៈបន្ថែមទេ ព្រោះមិត្តសុភា ក៏ឱ្យផ្អាកសកម្មភាពបណ្ដោះអាសន្ន។ ខែតុលា ឆ្នាំ១៩៧៧ មិត្តសុភា ឱ្យខ្ញុំទៅជួប ម៉ឺក ដើម្បីសួរនាំពីកងទ័ពវៀតណាម អាចវាយចូលមកបានហើយឬនៅ? តែខ្ញុំមិនអាចជួប ម៉ឺក បានទេ ព្រោះស្ថានភាពព្រំដែនមានការតឹងតែងជាងមុន។ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧ កងទ័ពវៀតណាមវាយចូលមកតាមភ្នំមុទ្រូត ចូលមកអូររាំង ដែលមានចម្ងាយ ៣០០គីឡូម៉ែត្រពីព្រំដែនវៀតណាម។ ដល់មកខែធ្នូ ឆ្នាំ១៩៧៧ ខ្ញុំដឹកនាំប្រជាជនដែលជម្លៀសចេញពីព្រំដែនឱ្យមកខាងទំនប់អូរយ៉េ។ ប្រជាជនទាំងអស់ ខ្ញុំបានបំផុសថា វៀតណាមអត់មានបាយហូប ប៉ុន្តែវាយឈ្នះបដិវត្តន៍កម្ពុជា។ បដិវត្តន៍រស់នៅស្រួលតែដូចលំបាក ប្រសិនជាចង់ស្រួល ហេតុនេះនាំគ្នារត់ចូលទៅវៀតណាម។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រឡប់មកអង្គភាពវិញ។ មិត្តសុភា ប្រញាប់ឱ្យខ្ញុំទៅជួបនៅមន្ទីរក-១១។ ពេលជួបមិត្តសុភា បានឱ្យ ឡាន់ ធ្វើសេចក្ដីរាយការណ៍ម្ដងទៀតពីបញ្ហាទាក់ទងឈ្មោះ ទៀង គឺបញ្ហាដែល ទៀង យកសំបុត្រទៅឱ្យ ម៉ឺក ចំនួន៥ថ្ងៃហើយ តែបែរជាតបវិញថា ម៉ឺក មិនបានទទួលសំបុត្រព្រោះជាប់ធ្វើការ។ ហេតុនេះ មិត្តសុភា ចង់ឱ្យ ខ្ញុំ ឡើងទៅជួប ម៉ឺក ដោយយកជិះជិះ ធ្វើជារូបភាពស្វែងរកជីកថ្នាំបុរាណ។ ព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ វេលាម៉ោង៧ ខ្ញុំបានជិះដំរីជាមួយមិត្ត ឡឹម, ហៀង មកព្រំដែន ក្នុងគោលបំណងទៅ ទាក់ទង ម៉ឺក។ ជិះមកដល់ក្រង់តែះមេឃងងឹតក៏ចូលសម្រាកនៅមន្ទីរកងធំទី២ មួយយប់។ ថ្ងៃបន្ទាប់នៅម៉ោង១១ ដល់ម៉ោង១ថ្ងៃត្រង់ ខ្ញុំឃើញនីរសាររបស់អង្គការយកសំបុត្រឱ្យប្រធានកងធំទី២ រួចមកប្រធានកងធំប្រាប់ឱ្យខ្ញុំវិលមកអង្គភាពវិញជាប្រញាប់។ ប្រធានកងធំទី២ យក ឡានដឹកខ្ញុំមកកាន់អង្គភាពខ្ញុំវិញ ដល់ព្រឹកឡើងមានសំបុត្រឱ្យខ្ញុំទៅមន្ទីរក-១៧។ ពេលខ្ញុំទៅដល់មន្ទីរក-១៧ អង្គការបានចាប់ខ្លួនខ្ញុំតែម្ដង។

**កំណត់ចំណាំ៖ អត្ថបទដែលដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00១៣៤ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ខ្វេន ង៉ុក ហៅ ឡុង ពិតប្រាកដយ៉ាងណានោះទេ។**

អាវុធបុរាណដែលកងឈ្លបបដិវត្តន៍ខ្មែរក្រហមវាយប្រយុទ្ធតទល់ជាមួយខ្មាំងសត្រូវកាលពីអំឡុងឆ្នាំ១៩៦៨ និងឆ្នាំ១៩៦៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ឆោម សាវ៉ាត ៖ លេខាស្រុកឆ្លូង តំបន់២១ ភូមិភាគបូព៌ា (២០៣)

**ដារ៉ាវដ្ឋ មេត្តា**



*កងចល័តនៅតាមសហករណ៍ក្នុងរបបខ្មែរក្រហម ចាំងសម្អាតស្មៅ ដើម្បីដាំដុះដំណាំ និងស្រូវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ដើម ប៉ែន ផែ និង មានឈ្មោះ បដិវត្តន៍ ឆោម សាវ៉ាត ជនជាតិខ្មែរ អាយុ៥២ឆ្នាំ (ឆ្នាំ១៩៧៧)។ ខ្ញុំមានប្រពន្ធឈ្មោះ យិន ស្រី និងមានកូនចំនួន៩ នាក់ ក្នុងនោះប្រុស៨ នាក់ និងស្រី១ នាក់។ ខ្ញុំមានស្រុកកំណើតនៅភូមិបារាយ ឃុំក្របីក្រៀក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ ខ្ញុំអាចសរសេរនិងអានអក្សរបានបន្តិចបន្តួចៗ ឪពុកខ្ញុំឈ្មោះ ហ៊ីង ប៉ែន និងម្តាយឈ្មោះ កុល ហេ ហើយខ្ញុំរស់នៅជាមួយពួកគាត់រហូតដល់ខ្ញុំអាយុ១៨ឆ្នាំ។ ខ្ញុំបានទៅនៅវត្តបារាយ ដើម្បីរៀនអក្សររយៈពេល១ឆ្នាំក៏បួសជានេន ដែលមានព្រះចៅអធិការវត្តឈ្មោះ លាស់។ រយៈពេល២ឆ្នាំក្រោយ ខ្ញុំត្រឡប់មកផ្ទះជួយធ្វើស្រែឪពុកម្តាយ និងដើររកស៊ីឈ្នួលធ្វើជាងឈើក្នុងភូមិសម្រាប់ចិញ្ចឹមគ្រួសារ។

នៅខែមេសា ឆ្នាំ១៩៤៨ ខ្ញុំចូលបដិវត្តន៍តាមរយៈតា សាយ ហៅ សេរីវុទ្ធី គឺជាអ្នកនាំចូល។ ខ្ញុំចូលដំបូងក្នុងសមាគមខ្មែរឥស្សរ ឃុំក្របីក្រៀក។ កាលនោះមានតា សាយ ហៅ សេរីវុទ្ធី គឺជាអនុប្រធានសមាគមខេត្តកំពង់ចាម, តា ចាន់សាម៉ន គឺជាប្រធានសមាគមខេត្តកំពង់ចាម និង ពាំង សេនា គឺជានាយកគណៈជាតិ។

នៅឆ្នាំ១៩៤៩ ខ្ញុំមានភារកិច្ច គឺជាអនុប្រធានសមាគមខ្មែរឥស្សរៈ ស្រុកក្រូចឆ្មារ។ កាលនោះមាន តាសាយ ហៅ សេរីវុទ្ធី គឺជាប្រធាន និងតាម៉ាន គឺជាសមាជិក។ ចាប់តាំងពីពេលនោះមកខ្ញុំបានធ្វើសកម្មភាពរហូតដល់ផ្អាកសង្គ្រាមនៅឆ្នាំ១៩៥៤។ ខែកុម្ភៈ ឆ្នាំ១៩៥៤ តាសេរីវុទ្ធីបានរៀបចំឱ្យខ្ញុំមានគ្រួសារ។ ក្រោយពីផ្អាកសង្គ្រាមអង្គការចាត់តាំងខ្ញុំជាជំហរលក់កាសែតបដិវត្តន៍ ឈ្មោះកាសែតប្រជាជន ដែលមានសមមិត្ត ឌឹម គឺជាអ្នកទទួលខុសត្រូវ។ ដល់ឆ្នាំ១៩៥៨ ខ្ញុំដាច់ខ្សែទាក់ទងបដិវត្តន៍ដោយបែកការណ៍ សមមិត្ត កែវ សំណាង គៀសខ្លួនបាត់មិនដឹងទៅណា ហើយតាសុជានូ គៀសខ្លួនទៅស៊ឹងត្រែង។ ដើមឆ្នាំ១៩៥៩ សមមិត្តឌឹម ត្រូវស្លាប់ដោយជំងឺរបេង ខ្ញុំដាច់ខ្សែរយៈ។ ខ្ញុំត្រូវរស់នៅរកស៊ីធម្មតា រហូតដល់ឆ្នាំ១៩៦២ ទើបមានខ្សែរយៈឡើងវិញ ដោយភ្ជាប់ជាមួយតាសេរីវុទ្ធី។ ឆ្នាំ១៩៦៣ ខ្ញុំបានធ្វើពាក្យលាចេញពីបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបង្កើតដោយ ហូជីមិញមុនដំបូងឈ្មោះបក្សកុម្មុយនីស្តវៀតណាម ហើយបន្តមកទៀតខ្ញុំបានសុំចូលក្នុងបក្សកុម្មុយនីស្តកម្ពុជាវិញមាន សមមិត្ត ម៉ៃ ផូវ និងសមមិត្ត ផាត គឺជាអ្នកទទួលស្គាល់។ ចាប់តាំងពីចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំបានទាក់ទងជាមួយសមមិត្ត ម៉ៃ ផូវ និង តាទឹកមាត់។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ភារកិច្ចបដិវត្តន៍ គឺនៅក្នុងឆ្នាំ១៩៧១ ខ្ញុំទទួលខាងវប្បធម៌។ ឆ្នាំ១៩៧២ ខ្ញុំទទួលតួនាទីជាលេខាស្រុកឆ្លូង តំបន់២១ និង ឆ្នាំ១៩៧៣ ខ្ញុំគឺជាសមាជិកអចិន្ត្រៃយ៍តំបន់២១ និងជាលេខាស្រុកឆ្លូង។ នៅខែមិថុនា ខ្ញុំបានរួមប្រជុំលើកផែនការក្បត់ មានឈ្មោះ ស្រេង អនុលេខាភូមិភាគឧត្តរ គឺជាអធិបតី។ ចំណែកទីតាំងប្រជុំនៅផ្ទះរបស់ឈ្មោះ យូរ នៅភូមិដើមជ្រៃ ឃុំក្រូចឆ្មារ។ អ្នកចូលរួមប្រជុំមាន៖ ខ្ញុំ, ផា អតីតលេខាស្រុកក្រូចឆ្មារ, ស្រ៊ិន ហៅ សៃ គណៈស្រុកពាមជីលាំង, ហ៊ីង ហៅ ហង់ ថាមពលរបស់អង្គការ, គ្រូស៊ាង ពីដើមធ្វើគ្រូបង្រៀននៅវត្តក្នុងភូមិទី៤ រការខ្នុរ។ ផែនការលើកឡើងគឺ ត្រូវរៀបចំកម្លាំងក្បត់ជាបណ្តើរៗ, ធ្វើការប្រឆាំងបដិវត្តន៍, បំផុសរបបកម្មសិទ្ធិឯកជន, បំផុសសីលធម៌ទី៦, បំផុសទំនាស់គ្រប់ទីកន្លែង, ត្រៀមកម្លាំងឱ្យបានសម្រាប់បម្រើសេចក្តីត្រូវការ។ ក្រោយមកនៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានចាប់មកសួរចម្លើយនៅក្រសួងសន្តិសុខតំបន់២១។

## ការចាត់តាំងគណៈភូមិភាគបូព៌ាក្បត់ទាក់ទង

បូ លេខាស្រុកពាមជីលាំង។ បូ ទទួលការអប់រំបំពាក់បំប៉នខាងនយោបាយពីខ្ញុំផ្ទាល់ តែការចាត់តាំងឈ្មោះ បូ បញ្ចូលជាសមាជិកភូមិភាគបូព៌ាក្បត់គឺ ស្រេង អ្នកប្រកាសចាត់តាំង។ កន្លងមកការទាក់ទងផ្លូវការក្បត់រវាងខ្ញុំនិងបូ គឺមានជាបន្តបន្ទាប់។ បូ ខស្សរាហ៍មករាយការណ៍ឱ្យខ្ញុំពីសកម្មភាពការងារក្បត់ជាបន្តបន្ទាប់។ ឯការប្រគល់ភារកិច្ចសំខាន់គឺធ្វើសកម្មភាពរាំងស្ទះចលនាបដិវត្តន៍គ្រប់ផ្នែកពិសេសចលនាបដិវត្តន៍សង្គមនិយម របស់បក្ស និង ការប្រមូលកម្លាំងឱ្យបានច្រើន។ បូ ខស្សរាហ៍ទៅក្រចេះតាមខ្ញុំក្តាប់បានគឺ បូ ទៅ ទាក់ទងដូរដំរី។ រឿងនេះខ្ញុំមិនចាត់តាំងទេ គ្រាន់តែឮថា បូ ទៅ ទាក់ទងជាផ្លូវការបដិវត្តន៍ដូរដំរីមកប្រើប៉ុណ្ណោះ។

បូរ ខាងសន្តិសុខ៥០៥ ភូមិភាគឦសានមាន ៦តំបន់គឺ១០១,១០២,១០៤,១០៥,១០៧ និង តំបន់៥០៥។ កន្លងមកខ្ញុំមិនបានទាក់ទងស៊ីជម្រៅទេ ដល់ការប្រគល់ភារកិច្ចគោលជំហរឬប្រគល់ភារកិច្ចក្បត់អ្វីទេ។ ខ្ញុំទាក់ទង បូរ ដើម្បីឱ្យស្គាល់គ្នាពេលមានសភាពការណ៍យ៉ាងម៉េចៗគឺផ្តល់ដំណឹងឱ្យគ្នាទៅវិញទៅមកប៉ុណ្ណោះ។ កន្លងមកខ្ញុំបានជួប បូរ ម្តងនៅផ្ទះខ្ញុំនៅស្រុកឆ្លូងក្នុងខែមីនា ឆ្នាំ១៩៧៧ កាលនោះ បូរ មកទាក់ទងតាមផ្លូវការបក្សជាមួយខ្ញុំ ដើម្បីទាក់ទងចាប់យុវជនដែលរត់ពីសាលាទូន្មាន៥០៥ ភូមិភាគឦសាន មកពួននៅក្នុងស្រុកឆ្លូង។ ពេល

*ជួបគ្នានោះ បូរ បានរាយការណ៍ឱ្យខ្ញុំពីសភាពការណ៍តាមព្រំដែនហើយខ្ញុំរាយការណ៍អំពីសភាពការណ៍បន្តបន្ទើនផលឱ្យឈ្មោះ បូរ វិញដែរ។*

*កែវ មាស ខ្ញុំបានជួបគាត់ម្តងក្រោយពេលដែលសន្និកឆ្នោតរូបនន្ត័លរបស់យើង ចាញ់សន្និកឆ្នោតសង្គមរាស្ត្រនិយមក្នុងឆ្នាំ១៩៥៥ គឺជួបនៅក្នុងព្រៃបារាយ ស្រុកក្រូចឆ្មារ។ ពេលជួបគ្នា កែវ មាស បំផុសសរសើរពីបដិវត្តន៍សូវៀតល្អ កសាងប្រទេសខស្សាហកម្មជឿនលឿនអារ្យធម៌បរទេសគេស៊ីវិល័យប្រទេសគេក្លាហានទៅជាប្រទេសសម្បូររុងរឿង។ អនាគតទៅប្រទេសយើងឈ្នះ យើងត្រូវបានសហភាពសូវៀត មកជួយកសាងប្រទេសយើង ឱ្យជឿនលឿនដូចប្រទេសគេ។ កែវ មាស គូរប្លង់ប្រទេសសូវៀតកសាងសង្គមនិយមជឿនលឿនពន្យល់ប្រាប់ខ្ញុំ។ កែវ មាស បន្តពន្យល់ទៀតថាកម្លាំងយុវជនយុវនារីមិនមែនជាកម្លាំងសម្រាប់ច្បាំងធ្វើសង្គ្រាមទេវីយនេះគឺសម្រាប់សប្បាយ។*

*នៃ សារ៉ាន់ ហៅ យ៉ា ខ្ញុំជួបបានម្តងកាលសម័យតស៊ូ៩ឆ្នាំ កាលនោះអនុគណៈជាតិមុត្តគាហាភូមិភាគបូព៌ា។ ខ្ញុំបានជួប យ៉ា នៅត្នោត-ក្រដាស ស្រុកពញាក្រែក តំបន់២០ ភូមិភាគបូព៌ា។ ពេលជួបខ្ញុំទទួលបានការអប់រំពី យ៉ា ឱ្យស្អិតរមួតជាមួយវៀតណាម ព្រោះវៀតណាមជាបង្អែករបស់យើងទៅអនាគត, អប់រំឱ្យមានទស្សនកុម្មុយនីស្តឥណ្ឌូចិន ដូច្នេះត្រូវឯកភាពជាមួយឥណ្ឌូចិន ដល់ពេលឈ្នះហូជីមិញនឹងប្រគល់ដីប៉ុន្មានខេត្តដែលបារាំងឱ្យយួនប្រគល់ឱ្យខ្មែរយើងវិញ។ ឆ្នាំ១៩៥៤ ក្រោយពីផ្អាកសង្គ្រាម មុនពេល យ៉ា ទៅភ្នំពេញបានផ្ញើសំបុត្រឱ្យខ្ញុំទាក់ទងជាមួយគាត់នៅភ្នំពេញ។ នៅឆ្នាំ១៩៧៣ ខ្ញុំទទួលសំបុត្រពី យ៉ា មួយច្បាប់តាមរយៈឈ្មោះ រុន គឺជានីសាររបស់ យ៉ា។ កាលនោះ យ៉ា ទទួលលេខាភូមិភាគឦសាននិងទទួលខាងគមនាគមន៍ ដឹកជញ្ជូនរបស់អង្គការ៨៧០។ សំបុត្រដែល យ៉ា ផ្ញើមកខ្ញុំគឺសុំកាណូត២ និងម៉ូតូ១គ្រឿង ខ្ញុំបានរៀបចំតាមការស្នើ។ ក្រោយមកក្នុងខែសីហា ឆ្នាំ១៩៧៣ ខ្ញុំទទួលបានសំបុត្រពី យ៉ា មួយច្បាប់ទៀតតាមរយៈឈ្មោះ រុន ដែលឱ្យខ្ញុំរកជាងឱ្យបាន៤នាក់ ដើម្បីធ្វើកាណូតចំណុះ១០តោន។ ចាប់តាំងពីពេលនោះមកខ្ញុំមិនដែលបានជួប យ៉ា ទេ ហើយជាងធ្វើកាណូត ខ្ញុំបានត្រៀមរួចហើយមិនឃើញ យ៉ា ទាក់ទងមករហូតដល់សព្វថ្ងៃនេះ (ឆ្នាំ១៩៧៨)។*

*កុយ ធួន ក្នុងឆ្នាំ១៩៧០ ខ្ញុំបានជួបគាត់នៅរកាខ្នុរ ភូមិទី៧ ស្រុកក្រូចឆ្មារ។ នៅឆ្នាំ១៩៧២ ពេលរៀននៅសាលា៨៧០ នៅក្នុងព្រៃក្បែរស្ទឹងសែន ភូមិភាគឧត្តរ ខ្ញុំបានជួបជាមួយ កុយ ធួន បានលើកអំពីផែនការក្បត់ឱ្យខ្ញុំអនុវត្ត។*

*ស្រេង នៅឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧១ ខ្ញុំទទួលការចាត់តាំងពី ស្រេង ធ្វើជាប្រធានភូមិភាគ និងចាត់តាំងខ្ញុំភ្ជាប់ខ្សែជិន្នួស កុយ ធួន។ រហូត កុយ ធួន និង ស្រេង ចាត់តាំងឈ្មោះ សៃ គណៈស្រុកពាមជីលាំង និងឱ្យនីសារភ្ជាប់ការទាក់ទងជាមួយខ្ញុំ។*

*ឈូក បានទាក់ទងជាច្រើនដងជាពិសេសពេលប្រជុំនៅភូមិភាគ។ ពេលជួបគ្នា ឈូក តែងលើកអំពីផែនការឱ្យខ្ញុំអនុវត្ត។ ខ្ញុំបានរាយការណ៍ឱ្យ ឈូក ពីការលំបាក និងងាយស្រួលនៃការកសាងកម្លាំងក្បត់។ ការទាក់ទងជាមួយ ឈូក ពេលជួបគ្នាគឺពេលឡើងប្រជុំការងារអង្គការភូមិភាគប៉ុណ្ណោះ មិនបានចាត់តាំងនីសារអ្វីសម្រាប់ទាក់ទងទេ។*

***កំណត់ចំណាំ៖ អត្ថបទដែលដកស្រង់ចេញពីចម្លើយសារភាពឯកសារ D១៦៦៨៤, D១៥១៩៥, D២១៤០៨ និង L០១៨៨០ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពខាងលើ ពិតប្រាកដណានោះទេ។***

# សិស្សអនុវិទ្យាល័យថ្នាត មកអានឯកសារនិងសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រ
## ខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ស្នួត វិចិត្រ



សិស្សអនុវិទ្យាល័យថ្នាត មកអានឯកសារ និងសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ សិស្សានុសិស្ស៦នាក់មកពីអនុវិទ្យាល័យថ្នាត បានមកអាន និងស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៨ ដើម្បីស្រាវជ្រាវ កន្លែងធ្វើសម្ភាសន៍អ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម កន្លែងប្រជុំ និងកន្លែងតម្កល់ឯកសារដែលមានចំនួនសរុប ២,៩០០ឯកសារ ស្មើនឹង៦៧,៨២៦ទំព័រ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏ជាកន្លែងអប់រំពីប្រវត្តិសាស្ត្រក្នុងតំបន់អន្លង់វែង សង្គ្រាម និង សន្តិភាពដល់យុវជនជំនាន់ក្រោយនៅក្នុងសហគមន៍ដែរ។

ជាកិច្ចចាប់ផ្តើមកម្មវិធី ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងលោក ស្នួត វិចិត្រ និង កញ្ញា មេក វិន បានបង្ហាញពីផ្ទាំងពិព័រណ៍រូបថតមេដឹកនាំចំនួន៥រូប រួមមាន៖ នួន ជា អនុលេខាបក្សកុម្មុយ-និស្តកម្ពុជា និងប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ, ខៀវ សំផន ជាប្រធាន

គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ, អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ, អៀង ធីរិទ្ធ គឺជារដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ និង កាំង ហ្កេចអ៊ាវ ហៅ ឌុច ប្រធានមន្ទីរសន្តិសុខ ស-២១ ដល់សិស្សានុសិស្ស។ មេដឹកនាំខ្មែរក្រហមទាំងនោះត្រូវបានសាលាក្តីខ្មែរក្រហមចោទប្រកាន់ និងជំនុំជម្រះទោសពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនកម្ពុជាប្រមាណ២លាននាក់។ ការធ្វើការងារដោយបង្ខំ ការធ្វើទារុណកម្ម ការស្លាប់ដោយជំងឺខ្វះការព្យាបាល ការបង្អត់អាហារ និងការសម្លាប់ជាប្រព័ន្ធសុទ្ធតែជាហេតុផលដែលតុលាការខ្មែរក្រហមឈានទៅរកការសម្រេចសាលក្រមថាជាអំពើប្រល័យពូជសាសន៍។ ក្រៅពីនេះ នៅមានបទឧក្រិដ្ឋកម្មដទៃផ្សេងទៀត។

បន្ទាប់មកទៀត ក្រុមការងារបង្ហាញពិព័រណ៍អំពីស្ថានភាពរស់នៅ និងសកម្មភាពការងាររបស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហមឆ្នាំ១៩៧៨, ការធ្វើដំណើររបស់កម្មាភិបាលខ្មែរក្រហមទៅកាន់ជំរំជនភៀសខ្លួននៅតាមជាយដែន, ការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនកម្ពុជាពីប្រទេសថៃទៅកាន់ទីក្រុងភ្នំពេញតាមរថភ្លើងនៅឆ្នាំ១៩៩២ (សម័យអ៊ុនតាក់), ការធ្វើមាតុភូមិនិវត្តន៍ពីជំរំប្ញទ្ធិសែនរបស់ប្រជាជនកម្ពុជា, ពិធីសមាហរណកម្មនៅតំបន់អន្លង់វែងឆ្នាំ១៩៩៨, ពិធីដង្ហែសព ឈិត ជឿន ហៅ តាម៉ុក (មេទ័ពខ្មែរក្រហមនៅតំបន់អន្លង់វែង) នៅឆ្នាំ២០០៦ ព្រមទាំងឯកសារបោះពុម្ពផ្សាយដែលតម្កល់ទុកនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅក្នុងឱកាសនោះដែរ សិស្សានុសិស្សបានអានឯកសារចម្លើយសារភាពរបស់អ្នកទោស ដែលមានរក្សាទុកនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

ចុងក្រោយសិស្សានុសិស្សទស្សនាខ្សែភាពយន្តឯកសារ «កុមារកម្ពុជា» ចាក់បញ្ចាំងដោយ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីធ្វើការពិភាក្សា។ បណ្ឌិត លី សុខឃាង បានលើកឡើងថា ភាពយន្តនេះនិយាយអំពីស្ថានភាពរបស់កុមារកម្ពុជានៅក្រោយឆ្នាំ១៩៧៩ បន្ទាប់ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំ។ កុមារកម្ពុជាមានស្ថានភាពរស់នៅយ៉ាងវេទនាជាមួយនឹងការអត់ឃ្លាន, កំព្រាឪពុកម្តាយ, គ្មានសម្លៀកបំពាក់សមរម្យ, កង្វះការអប់រំ, ពុំមានទីជម្រកត្រឹមត្រូវ, គ្មានអនាម័យ, ប្រឈមនឹងជំងឺ, ស្គមស្គាំង និងខ្វះភាពកក់ក្តៅ និងមានផលប៉ះពាល់លើប្រាជ្ញាស្មារតី ខណៈដែលកុមារនៃបណ្តាប្រទេសដែលមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍ រស់នៅមានអាហារូបត្ថម្ភគ្រប់គ្រាន់ មានការអប់រំ និងមានភាពកក់ក្តៅក្នុងក្រុមគ្រួសារ។ បន្ទាប់ពីទស្សនាខ្សែភាពយន្តចប់ សិស្សានុសិស្សលើកឡើងថា ខ្លួនពិតជាមើលឃើញភាពកម្សត់ និងការលំបាកវេទនារបស់កុមារកម្ពុជា។

**ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្ស៖**

***ពិសិដ្ឋ រាសី*** *ភេទស្រី អាយុ១៣ឆ្នាំ រៀបរាប់ថា «ខ្ញុំពិតជាត្រេកអរខ្លាំងដែលបានមកសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំបានយល់ដឹងពីទុក្ខវេទនារបស់ប្រជាជនខ្មែរនៅក្នុងរបបខ្មែរក្រហម។ ជាក់ស្តែងខ្ញុំបានទស្សនាភាពយន្តឯកសារ «កុមារកម្ពុជា» ដោយឃើញថាកុមារមិនទទួលបានការសិក្សារៀនសូត្រទេ។ កុមារខ្វះការមើលថែទាំពីឪពុកម្តាយ ដើរពាសវាលពាសកាលប្រៀបបានដូចជាក្មេងអនាថា។ ទិដ្ឋភាពទាំងអស់នេះបានធ្វើឱ្យខ្ញុំមានការអាណិតអាសូរទៅដល់កុមារកម្ពុជាដែលបានឆ្លងកាត់ទុក្ខលំបាកវេទនាក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ បន្ទាប់ពីខ្ញុំមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ខ្ញុំបានយល់ដឹងបន្ថែមអំពីកុមារដែលរស់នៅដោយគ្មានអាហារហូបចុក និងគ្មានសម្លៀកបំពាក់។ ជាចុងក្រោយ ខ្ញុំសំណូមពរឱ្យមានកម្មវិធីបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្សឱ្យបានច្រើនថែមទៀត»។*

***ឈុនណារី*** *ភេទស្រី លើកឡើងថា «នៅពេលដែលខ្ញុំបានសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ខ្ញុំមានអារម្មណ៍ភ័យផង*



សិស្សអនុវិទ្យាល័យថ្វាត មកអានឯកសារ និងសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងអរជង ពីព្រោះខ្ញុំមិនដែលបានចូលរួមការសិក្សាក្រៅថ្នាក់រៀនពីមុនមកទេ។ ខ្ញុំសប្បាយចិត្តដែលបានចូលរួមជាមួយមិត្តភក្តិដទៃទៀត និងបានស្គាល់ទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំឃើញថា ការរៀបចំនៅក្នុងការិយាល័យសាធារណៈរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានភាពខុសប្លែកពីកន្លែងផ្សេងៗទៀត ដោយសារនៅតាមជញ្ជាំងមានតាំងបង្ហាញពិព័រណ៍រូបថតរបស់មេដឹកនាំខ្មែរក្រហម រូបថតប្រជាជន រួមទាំងការធ្វើសមាហរណកម្មបញ្ចប់សង្គ្រាមរបស់អតីតកងទ័ពខ្មែរក្រហម នៅតំបន់អន្លង់វែង ទៅក្នុងរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨។ ក្រៅពីនេះ ខ្ញុំបានអានឯកសារទាក់ទងនឹងសកម្មភាពក្បត់របស់អ្នកទោស លេង ប៉ែន ដែលត្រូវបានឆ្មាំគុកខ្មែរក្រហមសួរចម្លើយ។ ខ្លឹមសារសំខាន់ក្នុងចម្លើយសារភាពនោះ គឺ លោក លេង ប៉ែន មានរបរជាកសិករ បានស្គាល់មិត្តម្នាក់ទៀតឈ្មោះ ហែង គួចលី ដែលមានតួនាទីជាប៉ូលិស។ ចំពោះការទស្សនាកុនឯកសារ ខ្ញុំចាប់អារម្មណ៍ជាងគេគឺទៅលើទិដ្ឋភាពប្រជាជនរស់នៅប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហមដួលរលំ និងទិដ្ឋភាពប្រជាជនក្នុងប្រទេសដទៃដែលមានភាពខុសគ្នាស្រឡះ ដោយសារប្រទេសកម្ពុជាមិនសូវរីកចម្រើនដូចទៅនឹងប្រទេសទាំងនោះ។ ជាក់ស្តែងនៅក្នុងភាពយន្តឯកសារ បង្ហាញអំពីការរស់នៅរបស់ប្រជាជនប្រទេសកម្ពុជាជាមួយនឹងការខ្វះខាតចំណីអាហារ និងស្គមស្គាំង។ ប្រសិនបើខ្ញុំជាកុមារនៅក្នុងរបបនោះ ខ្ញុំមិនអាចរស់នៅបានទេ ពីព្រោះខ្ញុំមិនអាចរស់នៅដោយគ្មានរបស់ប្រើប្រាស់ និងការហូបចុកគ្រប់គ្រាន់ឡើយ។ បន្ថែមលើនេះ ខ្ញុំចង់ដឹងពីការរៀបអាពាហ៍ពិពាហ៍ និងការធ្វើទារុណកម្មលើអ្នកទោសក្នុងរបបខ្មែរក្រហម។ ខ្ញុំនឹងនិយាយអំពីរឿងរ៉ាវដែលខ្ញុំបានដឹងក្នុងថ្ងៃនេះប្រាប់ទៅមិត្តភក្តិ និងឪពុកម្តាយរបស់ខ្ញុំ ជាពិសេសអំពីកិច្ចការរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងលើការសិក្សាស្រាវជ្រាវលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

**សេងលី សំណាង** ភេទស្រី បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា «ពីមុនខ្ញុំមិនដែលដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមទាល់តែសោះ។ ទើបតែថ្ងៃនេះ ខ្ញុំបានមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងបានដឹងរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមជាច្រើន។ ខ្ញុំបានដឹងពីស្ថានភាពរស់នៅរបស់កុមារកម្ពុជា ដែលមានរាងកាយស្គមស្គាំង កង្វះអាហារ និងគ្មានភាពកក់ក្តៅ ដោយសារស្ថានភាពកំព្រាឪពុកម្តាយ។ រូបភាពមួយចំនួនទៀត បានបង្ហាញពីកុមារស្លៀកសម្លៀកបំពាក់រហែក និងគ្មានស្បែកជើងពាក់។ ខ្ញុំមើលទៅគួរឱ្យសង្វេគ។ ប្រសិនបើបច្ចុប្បន្នខ្ញុំរស់នៅដោយគ្មានសម្លៀកបំពាក់ គ្មានស្បែកជើង សាប៊ូកក់សក់ និងគ្មានឪពុកម្តាយមើលថែ ខ្ញុំពិតជាមិនអាចរស់នៅបានទេ។ ក្នុងនាមខ្ញុំជាសិស្ស ខ្ញុំយល់ថាការរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាសំខាន់ណាស់ ព្រោះពេលយើងបានដឹងរឿងរ៉ាវប្រវត្តិសាស្ត្រទាំងនោះ យើងអាចយកទៅប្រាប់ បុបង្រៀនដល់ក្មេងៗជំនាន់ក្រោយៗទៀត។ ប្រសិនបើខ្ញុំទំនេរពីការសិក្សា ខ្ញុំនឹងមកអានឯកសារ និងសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងម្តងទៀត។

**ឡឿន ធីណា** ភេទស្រី បានឱ្យដឹងថា «ពីមុន ខ្ញុំមិនធ្លាប់ស្គាល់ និងបានដឹងថាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងផ្តោតសំខាន់ទៅលើការងារអ្វីនោះទេ គ្រាន់តែចាំថាខ្ញុំធ្លាប់ធ្វើដំណើរឆ្លងកាត់ទីនេះ។ នៅថ្ងៃនេះ ខ្ញុំមានឱកាសរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្វែងយល់ពីការរស់នៅរបស់ប្រជាជនក្រោមរបបខ្មែរក្រហម។ ប្រសិនបើខ្ញុំស្ថិតក្នុងរបបខ្មែរក្រហម ខ្ញុំមិនអាចរស់នៅក្នុងសភាពបែបនេះបានទេ ពីព្រោះមានការលំបាកច្រើន ហើយកុមារទាំងអស់ប្រាកដជាមិនអាចទទួលយកបាន។ ខ្ញុំចង់មកទីនេះម្តងទៀត ដើម្បីអានសៀវភៅ»។

**បូរ គឹមមឿយ** ភេទស្រី លើកឡើងថា «ខ្ញុំមានអារម្មណ៍កម្សត់ និងសោកសង្រេងយ៉ាងខ្លាំង បន្ទាប់ពីបានឃើញរូបភាពកុមាររស់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំចាប់អារម្មណ៍រូបថតមួយផ្ទាំងដែលបង្ហាញពីជនភៀសខ្លួននៅតាមព្រំដែនថៃ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅដូចៗគ្នា ដែលដាក់តាំងនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំពិតជាចង់ដឹងបន្ថែមទាក់ទងនឹងការធ្វើទារុណកម្មអ្នកទោស និងការធ្វើការងារប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។ ខ្ញុំយល់ថាការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាសំខាន់ណាស់សម្រាប់យុវជនជំនាន់ក្រោយ ពីព្រោះនៅពេលដែលយើងយល់ដឹងរឿងរ៉ាវកើតឡើងនៅក្នុងរបបនោះកាន់តែច្រើន យើងអាចផ្សព្វផ្សាយទៅកាន់មនុស្សជុំវិញខ្លួន។ ខ្ញុំនឹងជួយផ្សព្វផ្សាយពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដល់ឪពុកម្តាយ បងប្អូន និងមិត្តភក្តិរបស់ខ្ញុំឱ្យបានស្គាល់ពីទីនេះ»។

**ហួត សុរអេលីអាណា** ភេទស្រី យល់ឃើញថា «ភាពយន្តឯកសារដែលបង្ហាញស្ថានភាពកុមារកម្ពុជាក្រោយរបបខ្មែរក្រហម ធៀបទៅនឹងកុមារក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ គឺកុមារក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ទទួលការមើលថែពីអាណាព្យាបាល មានការអប់រំ សម្លៀកបំពាក់ស្អាតៗ និងរស់នៅស៊ីវិល័យ ស្របពេលកុមារនៅក្នុងប្រទេសកម្ពុជាជួបប្រទះនូវការលំបាក គ្មានអាណាព្យាបាលមើលថែ ខ្វះភាពកក់ក្តៅ មិនទទួលបានការអប់រំ សម្លៀកបំពាក់រហែក និងការហូបចុកគ្មានអនាម័យ។ បើមានឱកាសម្តងទៀត ខ្ញុំនឹងសិក្សាបន្ថែមទៀតលើការរស់នៅរបស់កុមារ និងហេតុផលដែលជំរុញឱ្យមានការកើតឡើងរបបខ្មែរក្រហម»។



សិស្សអនុវិទ្យាល័យថ្លាត មកអានឯកសារ និងសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គរុសិស្សឆ្នាំទី១ ជំនាញប្រវត្តិវិទ្យា
## នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

*លី ដេវីត និង ទូច វណ្ណាត*



គរុសិស្សឆ្នាំទី១ ជំនាញប្រវត្តិវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ គរុសិស្សឆ្នាំទី១ជំនាញប្រវត្តិវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ចំនួន៦នាក់ ចុះមកទស្សនកិច្ចសិក្សាស្រាវជ្រាវ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ចាម។ គោលបំណងនៃដំណើរទស្សនកិច្ច គឺដើម្បីធ្វើការស្វែងរកប្រភពឯកសារដ៏សម្បូរបែប ដែលត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ គរុសិស្សទាំង៦រូប ទើបតែបញ្ចប់ការអនុវត្តការបង្រៀននៅតាមវិទ្យាល័យ ដែលជាហេតុធ្វើឱ្យគរុសិស្សមានបំណងស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្វែងរកឯកសារ ក៏ដូចជាសៀវភៅ ទាក់ទងនឹងប្រវត្តិសាស្ត្រ សម្រាប់ជាឯកសារជំនួយរបស់ខ្លួន នាពេលចុះបំពេញភារកិច្ចជាគ្រូបង្រៀនមុខវិទ្យាប្រវត្តិសាស្ត្រ បន្ទាប់ពីបញ្ចប់ការសិក្សានៅពេលខាងមុខ។

ពេលចូលមកដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គរុសិស្សទាំងអស់បានចាប់អារម្មណ៍នៅក្នុងការអានឯកសារ និងសៀវភៅមួយចំនួន ដូចជា៖ បទសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង



គរុសិស្សឆ្នាំទី១ ជំនាញប្រវត្តិវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សៀវភៅវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងសៀវភៅមួយចំនួនទៀត។ បន្ទាប់មកលោក ទូច វណ្ណេត បុគ្គលិកប្រចាំនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានដឹកនាំគរុសិស្សទាំងអស់ឱ្យទស្សនាផ្ទាំងពិព័រណ៍អចិន្ត្រៃយ៍ចំនួន៥ផ្ទាំង ដែលបានតាំងបង្ហាញអំពី៖ ១) ទិវាជាតិនៃការចងចាំ ២០ ឧសភា ២) ដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ៣) ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម ៤) ទិដ្ឋភាពនានានៅតាមទីក្រុង និងទីប្រជុំជន និង៥) ប៉ុល ពត និងក្រុមគ្រួសារមេដឹកនាំខ្មែរក្រហម និងបក្ខពួក។ បន្ទាប់ពីទស្សនាផ្ទាំងពិព័រណ៍ខាងក្រៅរួចរាល់មក, គរុសិស្សទាំងអស់បន្តទៅស្វែងយល់អំពីឯកសារបទសម្ភាសន៍ និងអានសៀវភៅនៅបណ្ណាល័យរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលមាន បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមឈ្មោះសាំង ចាន់ធូ រង់ចាំទទួល និងពន្យល់ណែនាំបន្ថែម អំពីឯកសារបទសម្ភាសន៍ និងសៀវភៅដែលជាកិច្ចការងារចម្បងកំពុងអនុវត្ត។

ជាចុងបញ្ចប់នៃដំណើរទស្សនកិច្ច គរុសិស្សបានជួបជាមួយលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដើម្បីធ្វើការស្វែងយល់បន្ថែមទៀតទាក់ទងផ្ទាំងពិព័រណ៍ «ក្តីសង្ឃឹមកម្ពុជា» និងពិព័រណ៍អំពីសម្ភារប្រើប្រាស់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការពិភាក្សាអំពីកិច្ចការងារចងក្រងឯកសារ, ការធ្វើសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ការអប់រំ និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

**ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់គរុសិស្សដែលបានមកទស្សនកិច្ចសិក្សាស្រាវជ្រាវ ៖**

**លី សុគា** រៀនឆ្នាំទី១ ជំនាញប្រវត្តិវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម បានលើកឡើងថា៖ «ខ្ញុំយល់ថា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ពិតជាល្អខ្លាំងណាស់សម្រាប់រូបខ្ញុំដែលជាគរុសិស្សសម្រាប់ការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាសម័យខ្មៅងងឹត

ដែលប្រជាជនខ្មែរមិនអាចបំភ្លេចបាន។ ខ្ញុំឃើញមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម សម្បូរទៅដោយឯកសារជាច្រើន ដែលខ្ញុំអាចមកស្រាវជ្រាវនាពេលក្រោយបន្ថែមទៀត។ ខ្ញុំចាប់អារម្មណ៍រឿងរ៉ាវក្នុងរបបខ្មែរក្រហមជាងគេ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងគឺផែនទីតំបន់នានាដែលមានទីតាំងភូមិភាគទាំង៦នៃរបបខ្មែរក្រហម។ ខ្ញុំក៏ឃើញមានសម្ភាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

**ធ្លុច សុធ្ធារី** រៀនឆ្នាំទី១ ជំនាញប្រវត្តិវិទ្យានៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម បង្ហាញចំណាប់អារម្មណ៍ថា ៖ «ខ្ញុំបានស្ដាប់ការរៀបរាប់របស់លោកគ្រូមានទាំងសំណេរ និងរូបភាពដែលទាក់ទងនៅក្នុងរបបខ្មែរក្រហម។ មួយទៀតមានវត្ថុបុរាណបន្សល់ពីសម័យដើមដែលខ្ញុំជាក្មេងជំនាន់ក្រោយមិនធ្លាប់ឃើញ មិនធ្លាប់ស្គាល់ និងឯកសារដែលទាក់ទងរបបខ្មែរក្រហមជាច្រើនទៀត»។

**បោ ផានិត** រៀនឆ្នាំទី១ ជំនាញប្រវត្តិវិទ្យានៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ចែករំលែកបទពិសោធន៍របស់ខ្លួនថា៖ «ខ្ញុំមានការយល់ដឹងច្រើនជាងមុនអំពីឯកសារខ្មែរក្រហម។ ខ្ញុំបានឃើញទិដ្ឋភាព និងសៀវភៅមួយចំនួនបង្ហាញពីរបបខ្មែរក្រហម ដែលធ្វើឱ្យប្រជាជនខ្មែរចងចាំមិនអាចបំភ្លេចបាន មានភាពឃោរឃៅ និងការកាប់សម្លាប់ប្រជាជនខ្មែរ។ លើសពីនេះ ខ្ញុំបានឃើញមានសម្ភារនិងរបស់របរដែលបន្សល់ទុកពីសម័យសង្គ្រាម ឯកសារភស្តុតាងមួយចំនួន និងឯកសារបទសម្ភាសន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំពិតជាសប្បាយចិត្តដែលបានមកទីកន្លែងនេះ។ ទីតាំងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម យុវជន និងប្អូនៗសិស្សានុសិស្សអាចមកសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហមបាន និងផ្ដល់ជាចំណេះដឹង និងការចងចាំរបស់ជនជាតិខ្មែរ»។



គរុសិស្សឆ្នាំទី១ ជំនាញប្រវត្តិវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ថុន ស្រីពេជ្រ



សិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៥ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៩រសៀល ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានទទួលស្វាគមន៍សិស្សានុសិស្សកំពុងសិក្សានៅថ្នាក់ទី១១ ចំនួន១៥នាក់ ក្នុងនោះមានស្រី១០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ សិស្សានុសិស្សទាំងនេះមានបំណងចង់ស្វែងយល់ពីប្រវត្តិសាស្រ្តខ្មែរក្រហម និងទស្សនាផ្ទាំងពិព័រណ៍រូបថតដែលដាក់តម្កល់នៅ ខាងក្នុង និងខាងក្រៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។

ក្នុងរយៈពេលកន្លងមកសម្រាប់ឆ្នាំ២០២៥នេះ ក្រោមការចង្អុលបង្ហាញ និងណែនាំពីគ្រូបង្រៀនរបស់ខ្លួន សិស្សានុសិស្សនៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ជាច្រើននាក់ បានមកសិក្សារៀនសូត្រពីប្រវត្តិសាស្រ្តខ្មែរក្រហម តាមរយៈការទស្សនាខ្សែភាពយន្តឯកសារ ពិព័រណ៍រូបថត អានសៀវភៅ និងឯកសារ និងពិភាក្សាពីចម្ងល់ផ្សេងៗទាក់ទងនឹងប្រវត្តិសាស្រ្តខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានណែនាំក្រុមសិស្សទាំងអស់ឱ្យពិនិត្យមើលផ្ទាំងពិព័រណ៍រូបថត និងពន្យល់ពីខ្លឹមសារនៃផ្ទាំងពិព័រណ៍នីមួយៗ។ បន្ទាប់មក សិស្សមានពេលវេលាផ្ទាល់ខ្លួនខ្លះដើម្បីអានឯកសារខ្មែរក្រហមដែលតម្កល់នៅក្នុងការិយាល័យ។





សិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៥ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





បន្ទាប់មក សិស្សបានទៅកាន់ថ្នាក់រៀនដើម្បីរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានសំណេះសំណាលជាមួយសិស្សានុសិស្ស និងបានពិភាក្សាអំពីជំពូកមេរៀនដែលសិស្សចង់ពិភាក្សា។ សិស្សបានប្រាប់ថា ខ្លួនចង់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ដោយសារមិនមានពេលវែងដើម្បីពន្យល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមទាំងមូល លោក ផេង ពង្សរ៉ាស៊ី បានសម្រេចចិត្តដឹកនាំការពិភាក្សាអំពី «ថ្ងៃ២០ ឧសភា ឆ្នាំ១៩៧៥ និងរឿងរ៉ាវដែលបានកើតឡើងបន្ទាប់ពីថ្ងៃនោះ»។

មុនដំបូង លោក ផេង ពង្សរ៉ាស៊ី បានសួរសំណួរទៅកាន់សិស្សថា «តើថ្ងៃទី២០ ខែឧសភា ជារៀងរាល់ឆ្នាំ ជាថ្ងៃអ្វី?» និង «តើធ្លាប់បានចូលរួមក្នុងកម្មវិធី ឬធ្លាប់មើលការផ្សាយពីកម្មវិធីដែលត្រូវបានរៀបចំឡើងនៅថ្ងៃ២០ឧសភា ដែរឬទេ? សិស្សពិតជាមិនបានចងចាំឡើយថា តើថ្ងៃទី២០ ខែឧសភា ជាថ្ងៃអ្វី ហើយក៏មិនដែលបានចូលរួមក្នុងកម្មវិធីនេះពីមុនមកដែរ។ លោក ផេង ពង្សរ៉ាស៊ី បានពន្យល់ពី «ទិវាជាតិនៃការចងចាំ» និងមូលហេតុដែលប្រជាជនកម្ពុជាហៅថ្ងៃនេះថា «ទិវាចងកំហឹង» ព្រមទាំងព្រឹត្តិការណ៍ឃោរឃៅនានាដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ដូចជា ការជម្លៀសប្រជាជនដោយបង្ខំ ការបង្អត់អាហារ ការធ្វើការហួសកម្លាំង ការនិរាសព្រាត់ប្រាស ការធ្វើទារុណកម្ម និងការកាប់សម្លាប់។ អមជាមួយនឹងការបង្រៀននេះ លោក ផេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារមួយចំនួនឱ្យសិស្សទស្សនា បង្ហាញអំពីការកាប់សម្លាប់មនុស្ស ការធ្វើទារុណកម្មមនុស្ស ការបង្អត់អាហារ ការធ្វើការហួសកម្លាំង និងការនិរាសព្រាត់ប្រាស បន្ទាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥។

# សិស្សអនុវិទ្យាល័យលំទង អានឯកសារ និងស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម

## នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ស្វត ទិចិត្រ



សិស្សចំនួន៦នាក់ ដឹកនាំដោយនាយកអនុវិទ្យាល័យលំទង មកទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីស្វែងយល់ឯកសារប្រវត្តិសាស្ត្រសេសសល់ពីរបបខ្មែរក្រហម នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សចំនួន៦នាក់ ក្នុងនោះមានស្រីចំនួន៣នាក់ និងប្រុសចំនួន៣នាក់ ដឹកនាំដោយនាយកអនុវិទ្យាល័យលំទង បានធ្វើដំណើរជាង១០គីឡូម៉ែត្រមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីស្វែងយល់ឯកសារប្រវត្តិសាស្ត្រសេសសល់ពីរបបខ្មែរក្រហម នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥។ មជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែងមានតម្កល់ឯកសារសរុបចំនួន២៩០០ឯកសារ ស្មើនឹង៦៧,៤២៦ទំព័រ។ ក្រៅពីនេះនៅមានពិព័រណ៍រូបថត សៀវភៅដែលបោះពុម្ពផ្សាយ ខ្សែភាពយន្តឯកសារ និងអត្ថបទស្រាវជ្រាវជាច្រើនទៀត។

អ្នកគ្រូ និងសិស្សានុសិស្សមកពីវិទ្យាល័យលំទងបានមកដល់ការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅជាប់បឹងអន្លង់វែង កណ្តាលទីរួមស្រុកអន្លង់វែង នៅវេលាម៉ោង៩ព្រឹក និងត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅពីក្រុមការងារ។ សិស្សានុ

សិស្សបានទស្សនាពិព័រណ៍រូបថត រួមមាន៖ ការដង្ហែសព ឈិត ជឿន ហៅ តាម៉ុក, កម្មាភិបាលខ្មែរក្រហមរត់ឡើងភ្នំដងរែក, ពិធីសមាហរណកម្មរបស់កងទ័ពខ្មែរក្រហមចូលទៅក្នុងរាជរដ្ឋាភិបាលកម្ពុជា នៅតំបន់អន្លង់វែងក្នុងឆ្នាំ១៩៩៩, ការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនកម្ពុជាក្នុងសម័យអ៊ុនតាក់ និងមេដឹកនាំខ្មែរក្រហមចំនួន៥រូប ដែលជំនុំជម្រះទោសនៅសាលាក្តីខ្មែរក្រហម។ បន្ទាប់មក សិស្សានុសិស្សបានមកជុំគ្នានៅតុវែងដើម្បីស្តាប់ការធ្វើបទបង្ហាញ ដោយមានអ្នកគ្រូដឹកនាំចាំអង្កេត។ បទបង្ហាញនៅពេលនេះគឺនិយាយអំពីអង្គការចាត់តាំងរបស់ខ្មែរក្រហមនៅតំបន់អន្លង់វែង និងការដួលរលំនៃចលនាខ្មែរក្រហម។ អន្លង់វែងមានសេសសល់ស្លាកស្នាមសង្គ្រាម រួមមានទីតាំងប្រវត្តិសាស្ត្រ និងរឿងរ៉ាវរហូតដល់បច្ចុប្បន្ន។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានតួនាទីក្នុងការថែរក្សាឯកសារ និងរឿងរ៉ាវទាំងនោះ ដើម្បីជំរុញឱ្យមានការផ្សះផ្សា ការកសាងសន្តិភាព និងការអប់រំដល់ក្មេងៗជំនាន់ក្រោយ។ នៅក្នុងឱកាសនោះដែរ សិស្សានុសិស្សក៏បានសាកសួរអំពីប្រវត្តិរបស់ តាម៉ុក និងក្រុមគ្រួសារ ព្រមទាំងកេរដំណែលរបស់ តាម៉ុក ដែលមាននៅអន្លង់វែង។ ក្រៅពីនេះ សិស្សក៏ចង់ដឹងអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហមដែរ។

**នៅចុងបញ្ចប់នៃបទបង្ហាញ សិស្សានុសិស្សបានបង្ហាញចំណាប់អារម្មណ៍ដូចតទៅ៖**

**សុខ សុឈាត** ភេទប្រុស អាយុ១៦ឆ្នាំ យល់ថា «ការទស្សនា ឬរៀនសូត្រពីប្រវត្តិសាស្ត្រនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងគឺល្អ។ ទីតាំងនេះគឺជាកន្លែងសម្រាប់សិក្សា និងយល់ដឹងអំពីប្រវត្តិសាស្ត្រ ប៉ុល ពត និង តាម៉ុក និងឯកសារជាច្រើនទៀត។ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានពន្យល់ប្រាប់ខ្ញុំអំពីប្រវត្តិសាស្ត្រដែលខ្ញុំមិនធ្លាប់បានដឹងពីមុនមក និងធ្វើឱ្យខ្ញុំយល់ដឹងច្បាស់ជាងមុន»។

**ច័ននីកា** ភេទស្រីអាយុ១៨ឆ្នាំរៀបរាប់ថា«ការមកទស្សនកិច្ច ឬការមករៀនពីប្រវត្តិសាស្ត្រនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើខ្ញុំសប្បាយរីករាយ និងភ្ញាក់ផ្អើលនៅពេលដែលបានយល់ដឹងពីការរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។ ខ្ញុំបានឃើញរូបថតរបស់ តាម៉ុក ដែលខ្ញុំមិនធ្លាប់បានឃើញពីមុនមក។ ខ្ញុំបានដឹងព័ត៌មានអំពីកូនស្រី តាម៉ុក និងក្រុមគ្រួសារ តាម៉ុក។ នៅក្នុងបទបង្ហាញខ្ញុំបានដឹងពីការជីករូងក្រោមដីនៅផ្ទះលាក់ខ្លួនរបស់ ប៉ុល ពត និងរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហមដែលប្រជាជនខ្មែរចងចាំមិនភ្លេច»។

**នង សារិន** ភេទស្រី អាយុ១៥ឆ្នាំ លើកឡើងថា «របប ប៉ុល ពត គឺជារបបសាហាវព្រៃផ្សៃដែលបានធ្វើបាបប្រជាជនខ្មែរ និងធ្វើឱ្យប្រជាជនខ្មែរចងចាំមិនភ្លេច។ ខ្ញុំអាណិតអាសូរប្រជាជនកម្ពុជាដែលមិនមានអាហារហូបចុកគ្រប់គ្រាន់ធ្វើពលកម្មហួសកម្លាំង និងរងការធ្វើទារុណកម្មសួរចម្លើយរហូតដល់បាត់បង់ជីវិតយ៉ាងអណោចអាធ័មនៅក្នុងរបបខ្មែរក្រហម។

**គឿន សុនាង** ភេទប្រុស អាយុ១៥ឆ្នាំ រៀបរាប់ថា «ការមកទសន្សកិច្ច និងសិក្សាអំពីប្រវត្តិសាស្ត្រ ប៉ុល ពត នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងធ្វើឱ្យខ្ញុំដឹងថារបបនោះប្រព្រឹត្តព្រៃផ្សៃមកលើប្រជាជនស្លូតត្រង់ និងក្មេងៗ ដូចជា ការបង្ខំឱ្យធ្វើការហួសកម្លាំង។ របប ប៉ុល ពត បានសម្លាប់ប្រជាជនមិនគិតពីក្មេងចាស់ ដោយការចោទប្រកាន់ដែលមិនមានមូលហេតុច្បាស់លាស់។ របបនេះបានបង្ខំឱ្យប្រជាជនរៀបការ និងធ្វើឱ្យប្រទេសជាតិស្ទើរបាត់បង់ទាំងស្រុង។

**ឧត្តម ច័ន្ទនី** ភេទស្រី អាយុ១៦ឆ្នាំ ឱ្យដឹងថា «ខ្ញុំមានការអាណិតអាសូរប្រជាជនខ្មែរដែលរស់នៅឆ្លងកាត់របបខ្មែរក្រហម។ របបខ្មែរក្រហមបានបំបិទសិទ្ធិសេរីភាពប្រជាជន ហើយប្រជាជនរស់នៅទាំងវេទនា គោកយ៉ាក គ្មានអាហារហូបចុកគ្រប់គ្រាន់ គ្មានសម្លៀកបំពាក់សមរម្យ និងត្រូវធ្វើការងារដូចជាទាសករ។ ប្រជាជនរងនូវការកាប់សម្លាប់ដោយមិនរើសមុខ។ ខ្ញុំអរគុណបុព្វបុរសខ្មែរដែលក្រោកឈរដឹកនាំការតស៊ូប្រឆាំងនឹងរបបខ្មែរក្រហមដើម្បី

ទាមទារយុត្តិធម៌ បញ្ចប់សង្គ្រាម និងឈានទៅរកសន្តិភាពសម្រាប់ប្រជាជនខ្មែរទាំងមូល»។

**រិន ភាក់ទីន** ភេទប្រុស អាយុ១៨ឆ្នាំ លើកឡើងថា «ខ្ញុំយល់ថា នៅក្នុងរបបខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត ពិតជាសាហាវព្រៃផ្សៃខ្លាំងណាស់ ព្រោះប្រជាជនជួបប្រទះភាពអត់ឃ្លាន ទទួលរងការកាប់សម្លាប់ ការចោទប្រកាន់គ្មានកន្លែងស្នាក់នៅសមរម្យ និងគ្មានថ្នាំព្យាបាលជំងឺ។ ថ្ងៃនេះ ខ្ញុំបានយល់ដឹងពីប្រវត្តិសាស្ត្រដែលមាននៅអន្លង់វែង ជាពិសេសកេរដំណែលរបស់ តាម៉ុក។ ក្រៅពីនេះ ខ្ញុំបានដឹងពីរឿងរ៉ាវដែលធ្វើឱ្យតំបន់អន្លង់វែងក្លាយជាតំបន់តស៊ូចុងក្រោយ នៅពេល តាម៉ុក ចាប់ ប៉ុល ពត កាត់ទោសចំពោះមុខប្រជាជន»។





សិស្សចំនួន៦នាក់ ដឹកនាំដោយនាយកអនុវិទ្យាល័យលំទង មកទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីស្វែងយល់ឯកសារប្រវត្តិសាស្ត្រសេសសល់ពីរបបខ្មែរក្រហម នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# មជ្ឈមណ្ឌលឯកសារកម្ពុជាប្រារព្ធ "ទិវា ២០ ឧសភា" បង្សុកូលឧទ្ទិសកុសល

## ដល់អ្នកស្លាប់ដែលគ្មានសាច់ញាតិ នៅហោរអដ្ឋិធាតុ (បណ្ណាល័យធាតុ) វត្តលង្កា ព្រះកុសុមារាម ក្រុងភ្នំពេញ

*ភា រស្មី*





*មជ្ឈមណ្ឌលឯកសារកម្ពុជាប្រារព្ធ "ទិវា ២០ឧសភា" បង្សុកូលឧទ្ទិសកុសលដល់អ្នកស្លាប់ដែលគ្មានសាច់ញាតិ នៅហោរអដ្ឋិធាតុ (បណ្ណាល័យធាតុ) វត្តលង្កា ព្រះកុសុមារាម ក្រុងភ្នំពេញ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅវេលាម៉ោង ៧៖៣០នាទីព្រឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំប្រារព្ធ «ទិវាជាតិនៃការចងចាំ ២០ ឧសភា» បង្សុកូលឧទ្ទិសកុសលដល់អ្នកស្លាប់ដែលគ្មានសាច់ញាតិនៅហោរអដ្ឋិធាតុ(បណ្ណាល័យធាតុ) នៅវត្តលង្កា ព្រះកុសុមារាម ក្នុងក្រុងភ្នំពេញ។ ការរៀបចំកម្មវិធីនេះ គឺដើម្បីគោរពវិញ្ញាណក្ខន្ធ និងឧទ្ទិសកុសលដល់អ្នកស្លាប់ឱ្យបានទៅដល់សុគតិភព។

កម្មវិធីខាងលើមានការនិមន្តចូលរួមពីព្រះបវរសត្ថា ហួរ សារិទ្ធិ ព្រឹទ្ធបុរសរងមហាវិទ្យាល័យទស្សនវិជ្ជា និងសាសនា នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងជាព្រះគ្រូសូធ្យស្តាំវត្តលង្កាព្រះកុសុមារាម, ព្រះសង្ឃ៤អង្គ, ដូនជី តាជី, សាច់ញាតិរបស់អ្នកស្លាប់ និងបុគ្គលិករបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា។

ទិវា២០ ឧសភា គឺជាទិវាជាតិ។ ជាទូទៅមជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែជ្រើសរើសទីតាំងមួយ ឬកន្លែងមួយដើម្បីរំឭកដល់អ្នកដែលបានស្លាប់ទៅ តាមពិធីបង្សុកូល និងមានការចូលរួមពីអ្នករស់រានមានជីវិត នៅតាមមូលដ្ឋានដាច់ស្រយាល

ដើម្បីឱ្យប្រជាជនកម្ពុជាមកចូលរួមជាលក្ខណៈបុគ្គលដោយផ្ទាល់។ បើទោះបី ជាមានការរៀបចំពិធីនេះឡើងជារូបភាពតូចតាចក្តី ប៉ុន្តែវាមានសារសំខាន់ណាស់សម្រាប់ប្រជាជនខ្មែរដែលជឿលើព្រះពុទ្ធសាសនា កម្មផល បុណ្យបាប ផលានិសង្ស និងជឿលើការអហោសិកម្ម ដែលជាមូលដ្ឋានគ្រឹះនៅក្នុងជីវិតប្រចាំថ្ងៃ។

ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា «ទិវា ២០ ឧសភា» គឺជាការចងចាំរាល់ថ្ងៃ គឺជាការងារប្រចាំថ្ងៃ និងការជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតំបន់ឆ្ងាយៗ ដែលគ្មានលទ្ធភាព និងធនធានក្នុងការសាងសង់ទីកន្លែងជួបជុំគ្នា។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសាងសង់ចេតិយមួយចំនួននៅតាមភូមិ ឃុំ មានការចូលរួមពីអ្នករស់រានមានជីវិតដែលបានផ្តល់ជាទីតាំងនៅតាមវាលស្រែចម្ការរបស់ខ្លួនដើម្បីប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។

នៅក្នុងឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រេចធ្វើពិធីបង្សុកូលនៅវត្តលង្កា ជាទីតាំងមួយមានរក្សាទុកកោដ្ឋចំនួន៤៦៤ ដែលត្រូវបានបោះបង់ចោល និងគួរឱ្យសង្វេគ ហើយមិនត្រូវបានគេនឹកនាដល់។ កោដ្ឋចំនួន៤៦៤នេះ ត្រូវបានរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធ នៅក្នុងវត្តលង្កា កាលពី១០ឆ្នាំមុន។ កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ វត្តលង្កាសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកន្លែងទុកដាក់កោដ្ឋទាំងនេះ ទៅជាបណ្ណាល័យ ដែលប្រែជាភាសាបាលីគឺ «ហោអដ្ឋិធាតុ»។ ហោអដ្ឋិធាតុ គឺជាបណ្ណាល័យដែលសិក្សាអំពីកោដ្ឋ និងជាកន្លែងដែលឱ្យយើងគិតដល់អ្នកស្លាប់ និងអ្នកដែលនៅរស់។



មជ្ឈមណ្ឌលឯកសារកម្ពុជាប្រារព្ធ "ទិវា ២០ ឧសភា" បង្សុកូលឧទ្ទិសកុសលដល់អ្នកស្លាប់ដែលគ្មានសាច់ញាតិ នៅហោអដ្ឋិធាតុ (បណ្ណាល័យធាតុ) វត្តលង្កា ព្រះកុសុមារាម ក្រុងភ្នំពេញ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



តាមរយៈ ទំនៀមទម្លាប់ព្រះពុទ្ធសាសនា ប្រពៃណី និងរចនាបថរបស់កោដ្ឋចំនួន៨៦៤ បានបង្ហាញអំពីឋានៈ តួនាទី របស់បុគ្គលនីមួយៗដែលបានស្លាប់ និងបង្ហាញអំពីស្ថានភាពសង្គមរបស់បុគ្គលម្នាក់ៗដែលត្រូវបានគេបោះបង់ចោលតាំងពីសម័យសង្គ្រាមរហូតដល់សម័យ ប៉ុល ពត និងសព្វថ្ងៃនេះ។

ហោអដ្ឋិធាតុ គឺជាបណ្ណាល័យធាតុដំបូងគេនៅក្នុងទីក្រុងភ្នំពេញ។ ក្រៅពីអហោសិកម្ម និងជំនឿសាសនា គោលបំណងរៀបចំឱ្យមាន ហោអដ្ឋិធាតុនេះ គឺជំរុញឱ្យមានការសិក្សា អំពីហេតុ និងផលដែលនាំឱ្យកោដ្ឋចំនួន៨៦៤ត្រូវបានបោះបង់? តើនរណាខ្លះដែលជាបុគ្គលចំនួន៨៦៤នាក់? តើស្លាប់ដោយសារមូលហេតុអ្វី? តើស្លាប់នៅពេលណា? តើសាច់ញាតិនៅទីណា? តើយើងអាចរកឃើញអ្នករស់រានមានជីវិត ដែលជាសាច់ញាតិរបស់អ្នកស្លាប់ចំនួន៨៦៤នាក់នេះដែរឬទេ? វាក៏បានបង្ហាញអំពីវប្បធម៌នៅក្នុងព្រះពុទ្ធសាសនារបស់យើង អំពីការដែលយើងរៀបចំទុកដាក់អដ្ឋិធាតុអ្នកដែលបានស្លាប់ទៅ។

នៅក្នុងវត្តលង្កាទៀតសោត មានទីតាំងសម្រាប់ជួយដល់អ្នកក្រីក្រនៅពេលមានអាសន្នដែលត្រូវការកន្លែងតម្កល់សព ឬកន្លែងបូជាផ្សេងៗ។ វត្តលង្កាផ្តល់ជាទីតាំងសម្រាប់សមាធិ និងសិក្សារៀនសូត្រដល់ប្រជាជនកម្ពុជា និងភ្ញៀវទេសចរបរទេសថែមទៀតផង។

ការអភិរក្ស និងការពារកោដ្ឋទាំងអស់នេះ គឺស្របទៅតាមចក្ខុវិស័យរបស់អនុសញ្ញាក្នុងការរារាំងទប់ស្កាត់ និងផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាំងពីឆ្នាំ១៩៤៨ មកម្ល៉េះ ។ នៅមុនពេលដែលយើងសម្រេចកំណត់បាននិយមន័យផ្លូវច្បាប់នៃឧក្រិដ្ឋប្រល័យពូជសាសន៍ដូចសព្វថ្ងៃ លោក លេមឃីន បានកំណត់ថា ការបំផ្លិចបំផ្លាញលើវត្ថុ និងបេតិកភណ្ឌវប្បធម៌ គឺជាទង្វើមួយដែលចាត់ចូលជាអំពើប្រល័យពូជសាសន៍លើវប្បធម៌។ កិច្ចការដែលបម្រើដល់ការកំណត់អត្តសញ្ញាណ, ការគោរព និងការអភិរក្សកោដ្ឋទាំងអស់ ដែលស្ទើរតែបាត់បង់ដោយសារខ្មែរក្រហមបង្កឡើងកាលពី៥០ឆ្នាំមុនក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាកិច្ចការបំពេញបន្ថែមចំពោះការតស៊ូឥតឈប់ឈរ ក្នុងការឆ្លើយតបអំពើប្រល័យពូជសាសន៍លើវប្បធម៌ ដែលបានកើតមានពីអតីតកាល ព្រមទាំងបានបន្តរហូតមកដល់សព្វថ្ងៃ។

នៅក្នុងឆ្នាំ២០២៥នេះ គឺមានរយៈពេល៥០ឆ្នាំហើយ គិតចាប់តាំងពីរបបខ្មែរក្រហមឡើងកាន់កាប់អំណាចនៅប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដូច្នេះ កោដ្ឋទាំង៨៦៤ក៏នឹងក្លាយទៅជាសម្បត្តិបេតិកភណ្ឌរបស់មនុស្សជាតិដែលត្រូវការពារ និងថែរក្សាដែរ។





អដ្ឋិធាតុរបស់អ្នកស្លាប់ដែលគ្មានសាច់ញាតិ នៅហោអដ្ឋិធាតុ (បណ្ណាល័យធាតុ) វត្តលង្កា ព្រះកុសុមារាម ក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







អដ្ឋិធាតុរបស់អ្នកស្លាប់ដែលគ្មានសាច់ញាតិ នៅហោអដ្ឋិធាតុ (បណ្ណាល័យធាតុ) វត្តលង្កា ព្រះកុសុមារាម ក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សង្គ្រាមមួយថ្ងៃនៅលើកោះតាង

**សុខ វណ្ណះ**

នៅពេលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រដ្ឋាភិបាលនៅក្នុងរបបខ្មែរក្រហមបានបង្កើតកងពលថ្មីមួយឈ្មោះថា កងពល១៦៤ ដឹកនាំដោយមាស មុត (ត្រូវជាកូនប្រសារតាម៉ុក) មកពីភូមិភាគនិរតី។ កងពល១៦៤បង្កើតឡើងសម្រាប់ការពារដែនសមុទ្រនៅក្នុងប្រទេសកម្ពុជាទាំងអស់ដូចជា៖ ខេត្តកំពត, ខេត្តកោះកុង និងក្រុងព្រះសីហនុ (ខេត្តព្រះសីហនុសព្វថ្ងៃ)។ នៅក្នុងឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមកំពុងតែមានមោទនភាព នឹងជ័យជម្នះលើរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ មានការជួយគាំទ្រពីសហរដ្ឋអាមេរិក។ នៅពេលនោះមេដឹកនាំខ្មែរក្រហមបានគិតថាខ្លួនឯងខ្លាំងបានវាយឈ្នះអាមេរិក។ ដូចនេះប្រធានកងពលឈ្មោះ មាស មុត បានចាត់តាំងយោធាខ្មែរក្រហម ដែលមានតួនាទីយាមការពារនៅតាមបណ្ដាកោះនានាឱ្យមានទឹកចិត្តអង់អាចក្លាហាន ចាប់ទូកនេសាទថៃ និងវៀតណាម ដែលបានធ្វើចរាចរណ៍ចូលមកដោយខុសច្បាប់ត្រូវបានយោធាខ្មែរក្រហម ប្រចាំការនៅលើកោះឃើញចាប់យកមកទាំងអស់គ្មានការលើកលែង។ នៅក្នុងឆ្នាំ១៩៧៥ ដដែលមាននាវាដឹកទំនិញមួយគ្រឿងរបស់សហរដ្ឋអាមេរិកឈ្មោះម៉ាយ៉ាហ្គេស (Mayaguez) បានបើកបរឆ្លងកាត់តាមផ្លូវអន្តរជាតិត្រង់ចំណុចកោះពូលូវៃ យោធាខ្មែរក្រហមក្មេងៗទាំងនោះមិនបានសិក្សារៀនសូត្រពីច្បាប់ផ្លូវទឹកអន្តរជាតិបានឃើញនាវាដឹកទំនិញមួយគ្រឿង បើកបរឆ្លងកាត់តំបន់កោះពូលូវៃ ក៏ទៅចាប់មករក្សាទុកនៅកោះតាង និងមិនបានធ្វើការដោះលែងនាវាដឹកទំនិញរបស់អាមេរិកភ្លាមៗទេ ជាមូលហេតុឱ្យកើតមានសង្គ្រាម រយៈពេលខ្លីៗ បន្ទាប់មកយោធាខ្មែរក្រហម បានឃើញឧទ្ធម្ភាគចក្ររបស់សហរដ្ឋអាមេរិកជាច្រើនគ្រឿងបានមកទម្លាក់គ្រាប់នៅទីក្រុងព្រះសីហនុជាពិសេសនៅលើកោះតាង។ អតីតយោធាខ្មែរក្រហម ឈ្មោះ ញ៉ូង ជ្រោង ធ្លាប់មានប្រវត្តិតស៊ូនៅក្នុងសម័យសង្គ្រាមប្រាំឆ្នាំ និងបានបន្តចូលធ្វើជាយោធាខ្មែរក្រហម នៅក្នុងកងពលថ្មី១៦៤ ការពារដែនសមុទ្រ បានដឹងរឿងរ៉ាវមួយចំនួននៅលើកោះតាង និងកោះនានាក្នុងប្រទេសកម្ពុជា ដូចខាងក្រោម៖



ញ៉ូង ជ្រោង អតីតកងទ័ពជើងទឹកខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំកើតនៅឆ្នាំ១៩៥២ នៅភូមិត្រពាំងអំពាក់ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (ភូមិភាគនិរតី)។ ខ្ញុំមានឪពុកឈ្មោះ ញ៉ឹង ជ្រិន, ម្តាយឈ្មោះ ឃិត ខំ និងមានបងប្អូនបង្កើតចំនួន១១នាក់ គឺប្រុសចំនួន៥នាក់ និងស្រី៦នាក់។ ខ្ញុំជាកូនទី២ បានរៀនសូត្រនៅសាលាត្រពាំងគល់ត្រឹម ថ្នាក់ទី៩ (ពីសង្គមចាស់)។ ខ្ញុំឈប់រៀនដោយសារកើតមានរដ្ឋប្រហារនៅឆ្នាំ១៩៧០ ព្រោះសាលាបានបិទគ្មានគ្រូបង្រៀន និងស្របពេលមានយន្តហោះទម្លាក់គ្រាប់បែកពីកម្លាំងទាហានឧត្តមសេនីយ៍ លន់ នល់ នៅអង្គតាសោម និងកន្លែងមួយចំនួនទៀត។ បន្ទាប់មកនៅភូមិមួយចំនួនបានក្លាយជាតំបន់រំដោះគ្រប់គ្រងដោយខ្មែរក្រហម។

នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការជាមួយនារីម្នាក់រស់នៅភូមិក្បែរគ្នាឈ្មោះ កែម ខន រហូតបានកូនប្រុសម្នាក់។ នៅឆ្នាំ១៩៧៣ ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាកងឈ្លបឃុំត្រពាំងធំ បានរយៈពេលបីខែ និងបានបន្តចូលធ្វើជាយោធាខ្មែរក្រហម នៅតំបន់១៣ ខេត្តតាកែវ។ ខ្ញុំនៅក្នុងវរសេនាតូចលេខ៤ ដែលមានប្រធានឈ្មោះ សុវ និងឈ្មោះ ហន។ នៅពេលនោះសង្គ្រាមជាមួយទាហានឧត្តមសេនីយ៍ លន់ នល់ កាន់តែខ្លាំងឡើង។ ខ្ញុំបានផ្លាស់ចូលយោធាភូមិភាគនិរតីវិញ នៅក្នុងកងពលទី៣ ដែលមាន មាស មុត ជាប្រធាន។ នៅពេលនោះ ខ្ញុំបានចូលសមរភូមិវាយប្រយុទ្ធជាមួយទាហានឧត្តមសេនីយ៍ លន់ នល់ គ្រប់ទីកន្លែងសំដៅដណ្តើមយកទីក្រុងភ្នំពេញឱ្យបាននៅក្នុងឆ្នាំ១៩៧៥ តាមផែនការ។ នៅឆ្នាំចុងឆ្នាំ១៩៧៤ ខ្ញុំត្រូវរបួសសម្រាកព្យាបាលនៅមន្ទីរពេទ្យយោធានៅតាមព្រៃមិនបានចូលរួមវាយយកទីក្រុងភ្នំពេញទេ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ចប់រាល់ការជ្រៀតជ្រែកពីសំណាក់បរទេស ការទម្លាក់គ្រាប់បែក និងការប្រឈមអាវុធដាក់គ្នា នៃសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ ដែលអូសបន្លាយពេលប្រាំឆ្នាំនៅកម្ពុជា។ នៅពេលរបបខ្មែរក្រហម បានឡើងកាន់អំណាច ក្រសួងការពារជាតិបានរៀបចំបង្កើតកងពលថ្មី១៦៤ ដឹកនាំដោយមាស មុត។ កងពលនេះបង្កើតឡើងសម្រាប់ការពារដែនសមុទ្រនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំជាយោធានៅក្នុងកងពល១៦៤ អង្គការបានបញ្ជូនខ្ញុំតាមរថយន្តសំដៅក្រុងកំពង់សោម ដែលមុនដំបូងមកស្នាក់នៅដែក្រុងព្រះសីហនុ ទំនប់រលកបានមួយរយៈពេលខ្លី។ អង្គការបានបែងចែកកម្លាំងយោធាទាំងនោះជាក្រុមៗបន្តទៀត។ ខ្ញុំបានទទួលបញ្ជាពីថ្នាក់លើ មកស្នាក់នៅអង្គភាពដែរាម ជាប់ព្រលានយន្តហោះកងកេង។ បន្ទាប់មកទៀត ខ្ញុំបានដឹងព័ត៌មានថា យោធាខ្មែរក្រហម ដែលឈរយាមការពារកោះពូលូវៃ បានទៅចាប់នាវាដឹកទំនិញមួយគ្រឿងឈ្មោះ (Mayaguez) ដែលបើកបរលើផ្លូវអន្តរជាតិមករក្សាទុកនៅកោះតាង។ លុះដល់ពេលយប់ ខ្ញុំបានស្តាប់តាមវិទ្យុផ្សាយសំឡេងពីសហរដ្ឋអាមេរិកបានដឹងថា បើទីក្រុងភ្នំពេញ មិនដោះលែងនាវាឱ្យត្រឡប់ទៅវិញទេ នៅក្នុងប្រទេសកម្ពុជាត្រូវអាមេរិកមកទម្លាក់គ្រាប់បែកកម្ទេច។ នៅថ្ងៃបន្ទាប់ នាវាក៏ត្រូវបានដោះលែងទៅវិញ ប៉ុន្តែជៀសមិនផុតពីការវាយប្រហារពីសំណាក់ទាហានអាមេរិកដដែល។

កាលនោះមានការទម្លាក់គ្រាប់នៅក្រុងព្រះសីហនុ រោងចក្រប្រេងកាត និងនៅដែរាម ជាប់ព្រលានខូចខាតយន្តហោះអស់មួយចំនួន ជាពិសេសនៅលើកោះតាង។ សង្គ្រាមបានកើតឡើងរយៈពេលមួយថ្ងៃ ចាប់ពីម៉ោងប្រហែល៩ព្រឹក រហូតដល់ម៉ោង៦ល្ងាច នៅលើកោះតាង។ ខ្ញុំត្រូវអង្គការបញ្ជូនទៅកាន់កោះតាងភ្លាមៗ បន្ទាប់ពីមានព្រឹត្តិការណ៍កើតឡើង។ ខ្ញុំបានជិះនាវាឈ្មោះ៩២០ មានយោធាទាំងអស់ប្រហែលជា៤០០នាក់ ចេញដំណើរពីដែរាមនៅម៉ោង៧ព្រឹក ទៅដល់កោះតាងនៅម៉ោង៣រសៀល ដោយសារនាវាមានល្បឿនយឺត។ ខ្ញុំបានទៅដល់កោះតាងនៅឆ្នេរខាងកើតឃើញមានខ្សាច់ពណ៌សស្អាតមានដើមដូងច្រើន និងនៅលើភ្នំមានដើមឈើធំៗ បន្ទាប់មកទៀត ខ្ញុំបានឃើញឧទ្ធម្ភាគចក្រមួយគ្រឿងធ្លាក់នៅឆ្នេរខាងកើតជាប់មាត់សមុទ្រ និងមួយគ្រឿងទៀតនៅឆ្នេរខាងលិចទល់មុខកោះព្រីង និងបានឃើញសាកសព

ទាហានអាមេរិកស្លាប់នៅលើកោះតាង និងបានដឹងពីមិត្តភក្តិប្រាប់បន្ថែមទៀតថា ទាហានអាមេរិកនៅរស់រានមានជីវិតបន្ទាប់ពីសង្គ្រាមបានបញ្ចប់ តែក្រោយមកមិនបានដឹងថា អង្គការយកទៅណាទេ ឮសូរថាបាញ់សម្លាប់នៅលើកោះតាង។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំបានចេញពីកោះតាង ត្រឡប់មកដីគោកនៅអង្គភាពស្ទាប់ដែង ដើម្បីសម្រាកព្យាបាលជំងឺគ្រុនចាញ់។

នៅឆ្នាំ១៩៧៦ ប្រពន្ធកូនខ្ញុំត្រូវអង្គការឱ្យរស់នៅអង្គភាពយោធាជាមួយគ្នានៅស្ទាប់ដែងស្រុកព្រៃនប់។ នៅឆ្នាំ១៩៧៨ យោធាខ្មែរក្រហម នៅក្នុងកងពល១៦៤ ត្រូវបានដកកម្លាំងមួយចំនួនទៅសមរភូមិមុខខាងភូមិភាគបូព៌ា ពីព្រោះសង្គ្រាមជាមួយកងទ័ពវៀតណាមនៅតាមព្រំដែនកាន់តែខ្លាំងឡើង តែខ្ញុំមិនបានទៅសមរភូមិទេ។

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនជាបន្តបន្ទាប់។ ខ្ញុំបានរត់កៀសខ្លួនបែកពីប្រពន្ធកូនរត់កាត់ស្ទឹងហាវចូលព្រៃរហូតដល់ទឹកដីជីផាត ខេត្តកោះកុង បានជួបប្រពន្ធកូនទៅទីនោះវិញ ក៏បាននាំគ្នារត់ចូលព្រៃបន្តទៀតដោយគ្មានអាហារហូបគ្រប់គ្រាន់ គឺហូបតែផ្លែឈើ មើមក្តួចជាដើម ទម្រាំទៅដល់ជាយដែនថៃប្រើរយៈពេលជាង១ខែ។ មុនដំបូងខ្ញុំទៅដល់ជំរំខាវអ៊ីដាង មានអាហារហូបគ្រប់គ្រាន់។ ក្រោយមកខ្ញុំបានត្រឡប់មករស់នៅលើទឹកដីខ្មែរវិញ ជាមួយខ្មែរក្រហម នៅម្តុំ ែឡូម ក៏ជួបការលំបាកវេទនា គ្មានអាហារគ្រប់គ្រាន់ ក៏រត់ត្រឡប់ទៅនៅជំរំម៉ៃរូតប្រទេសថៃវិញ និងបន្តទៅរស់នៅជំរំសាយប៊ី រួចបន្តទៅរស់នៅអូរស្ទាប់ ជាមួយក្រុមទាហានប៉ារ៉ា និងជាមួយក្រុមតាអ៊ុនតាំ។

នៅឆ្នាំ១៩៩៣ មានជំនួយពីអង្គការសហប្រជាជាតិ ខ្ញុំបានធ្វើមាតុភូមិនិវត្តន៍មករស់នៅស្រុកកំណើត ខេត្តតាកែវ បានរយៈពេលបីឆ្នាំ ប៉ុន្តែដោយសារគ្មានដីធ្វើស្រែចម្ការប្រកបមុខរបររកស៊ីនៅឆ្នាំ១៩៩៦ ខ្ញុំរួមទាំងក្រុមគ្រួសារប្រពន្ធកូននាំគ្នាមករស់នៅស្ទាប់ដែង ដោយនឹកឃើញថា តំបន់ធ្លាប់រស់នៅជំនាន់ខ្មែរក្រហម សម្បូរដីច្រើនងាយស្រួលប្រកបមុខរបរដាំដំណាំផ្សេងៗ។ នៅឆ្នាំ២០២២ ខ្ញុំបានមករស់នៅភូមិតាឡាស់ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រកបមុខរបរធ្វើចម្ការជាមួយប្រពន្ធកូន និងមានជីវភាពខ្វះខាតក្រលំបាក ពីព្រោះខ្លួនកាន់តែចាស់។



កោះតាង នៅឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជីវិតកុមារក្នុងរបបខ្មែរក្រហម

**ឡុង ដានី**

នៅក្នុងរបបខ្មែរក្រហម (១៩៧៥ - ១៩៧៩) មិនមានសាលារៀនផ្លូវការសម្រាប់កុមារឡើយ។ កុមារត្រូវបញ្ជូនឱ្យរៀនសូត្រនៅក្រោមដើមឈើ ឬក្រោមផ្ទះប្រជាជនក្នុងរយៈពេលប្រមាណជា២ម៉ោងក្នុងមួយថ្ងៃ។ ចំណែកគ្រូបង្រៀនកុមារ គឺជាកសិករដែលអាចចេះអាន និងសរសេរបានបន្តិចបន្តួចប៉ុណ្ណោះ។ កុមារភាគច្រើនត្រូវបានខ្មែរក្រហមបង្ខំឱ្យរស់នៅក្នុងកងកុមារ បែកចេញពីឪពុកម្ដាយ និងធ្វើការងារពលកម្មផ្សេងៗដូចជាកាប់ដើមទន្រ្ទានខែត្រមកចិញ្រ្ចាំលាយជាមួយលាមកសម្រាប់ធ្វើជីដាក់ស្រែ កើបអាចម៍គោ ជួយធ្វើការងារពលកម្មតាមវាលស្រែ និងជញ្ជូនអាវុធទៅសមរភូមិជាដើម។



លោក ខួច ធី អាយុ៥៩ឆ្នាំ គឺជាបង្រៀននៅអនុវិទ្យាល័យ ហ៊ុន សែន ថ្មដា។ សព្វថ្ងៃគាត់រស់នៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកគ្រូ ខួច ធី អាយុ៥៩ឆ្នាំ បង្រៀននៅអនុវិទ្យាល័យ ហ៊ុន សែន ថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ បានរៀបរាប់អំពីកុមារភាពរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដូចខាងក្រោម៖

ខ្ញុំមានស្រុកកំណើតនៅភូមិពុទ្ធិសាំ ឃុំស្រងែ ស្រុកទ្រាំង ខេត្តតាកែវ។ សព្វថ្ងៃខ្ញុំរស់នៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានបងប្អូនចំនួន៧នាក់ ក្នុងនោះស្រី៥នាក់ និងប្រុស២នាក់។ ឪពុករបស់ខ្ញុំឈ្មោះ មាស ធង (ស្លាប់នៅឆ្នាំ១៩៨៤) និងម្ដាយឈ្មោះ ផង់ សាន់។ ខ្ញុំមានប្រពន្ធឈ្មោះ ហេង សុផុន និងមានកូនចំនួន៥នាក់ គឺកូនស្រីចំនួន៤នាក់ និង ប្រុសម្នាក់។

កាលពីតូចខ្ញុំមិនបានរៀនសូត្រទេ ពីព្រោះនៅឆ្នាំ១៩៧០ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិ។ ភូមិខ្ញុំគឺជាតំបន់សមរភូមិ ជាខ្សែត្រៀមរវាងកងទ័ពខ្មែរក្រហម និងទាហានលន់ នល់។ នៅខណៈពេលនោះ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីភូមិ ពីព្រោះពេលមានការប្រយុទ្ធគ្នាម្ដងៗ ទាល់តែប្រជាជនចេញផុតពីភូមិប្រមាណ១០គីឡូម៉ែត្រទៅ១៥គីឡូម៉ែត្រទើបមានសុវត្ថិភាព។ នៅពេលមានការប្រយុទ្ធគ្នាម្ដងៗ ក្រុមគ្រួសារខ្ញុំមិនបាននៅជុំគ្នាទេ ជួនកាលឪពុកនៅស្រែ កូននិងម្ដាយនៅផ្ទះ ពេលខ្មែរក្រហមជម្លៀសម្ដងៗ ម្ដាយនិងកូនទៅមុន។ ចំណែកឪពុកទៅតាមក្រោយ ពេលធ្វើដំណើរទៅតាមផ្លូវ ទើបសួររកសមាជិកក្រុមគ្រួសារ។ ប្រជាជននៅភូមិពុទ្ធិសាំទាំងអស់ត្រូវជម្លៀសទៅរស់នៅឃុំសំឡាញ ស្រុកអង្គរជ័យ (ក្នុងសម័យនោះស្រុកអង្គរជ័យ ស្ថិតនៅក្នុងខេត្តតាកែវ)។ ពេលទៅដល់ឃុំសំឡាញ ទើបប្រជាជននាំគ្នាសង់ខ្ទម

រស់នៅ និងធ្វើស្រែលើដីណាដែលទំនេរ។ ចំណែកនៅស្រុកកំណើតវិញ គឺមានការទម្លាក់គ្រាប់បែកប៉េ-៥២ ត្រូវចំផ្ទះរបស់ជីតាខ្ញុំ និងត្រូវចំរបស់របរ និងសម្ភារផ្សេងៗទៀតពុកសំឡេងត្រឹមៗចេញពីក្នុងភូមិ។ ពេលគ្រួសារខ្ញុំរស់នៅក្នុងឃុំសំឡាញ ខ្ញុំបានជួយឃ្វាលគោឪពុក គឺនៅពេលព្រឹកព្រលឹមឡើងដឹកគោយកទៅចងឱ្យស៊ីស្មៅនៅក្នុងព្រៃក្បែរភូមិ។ នៅក្នុងភូមិកាលនោះក៏មានចងជាក្រុមដើម្បីបង្រៀនកុមារដែរ តែខ្ញុំរៀនមិនសូវចេះទេ។

ក្រោយមកនៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំឱ្យត្រឡប់មកខេត្តតាកែវវិញ តែមិនបានមកដល់ភូមិកំណើតវិញទេ គឺត្រូវរស់នៅភូមិរូង ឃុំអង្គខ្នុរ ស្រុកទ្រាំង រយៈពេល២ឆ្នាំ។ នៅទីនោះគឺធ្វើស្រែមិនសូវបានផលទេ ព្រោះតែជាតំបន់សង្គ្រាម ពេលខ្លះរត់ចោលស្រូវនៅក្នុងស្រែ ហើយមានអ្នកភូមិខ្លះបានធ្វើដំណើរទៅ ខាំងទន្លេបាសាក់ក្នុងស្រុកកោះធំទៅរកពោត ព្រោះនៅខាងស្រុកកោះធំ គឺជាតំបន់សន្តិភាព។

នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ ក៏មានការជម្លៀសប្រជាជនម្តងទៀត គឺជម្លៀសពីឃុំអង្គខ្នុរ ទៅស្រុកកំណើតខ្ញុំវិញ គឺនៅភូមិពុទ្ធសាំ ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ។ ពេលទៅដល់ភូមិដំបូងមិនទាន់មានការបែងចែកវណ្ណៈទេ ទល់តែនៅឆ្នាំ១៩៧៦ ទើបមានការបែងចែកវណ្ណៈ។ គ្រួសារខ្ញុំ ត្រូវបានខ្មែរក្រហមចាត់ទុកជាប្រជាជនបញ្ញើ។ នៅក្នុងជំនាន់ខ្មែរក្រហមមានការបែងចែកប្រជាជនជា៣ថ្នាក់ គឺ ប្រជាជនពេញសិទ្ធិ, ប្រជាជនត្រៀម និងប្រជាជនបញ្ញើ។ ខ្មែរក្រហមចាត់ទុកក្រុមគ្រួសារខ្ញុំជាប្រជាជនបញ្ញើ ពីព្រោះនៅមុនរបបខ្មែរក្រហមក្រុមគ្រួសារខ្ញុំធ្វើស្រែ និងលក់អីវ៉ាន់ចាប់ហួយ ហេតុនេះត្រូវបានខ្មែរក្រហមចាត់ទុកជាក្រុមគ្រួសារនាយទុន។ ពេលនោះប្រធានឃុំឈ្មោះ ក្រិល និងប្រធានភូមិឈ្មោះ ផុន ជាអ្នកបែងចែកវណ្ណៈឱ្យប្រជាជន។

នៅក្នុងជំនាន់ខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យនៅក្នុងកងកុមារ និងផ្លាស់ទៅនៅឃុំបារាយណ៍ បែកចេញពីឪពុកម្តាយ ដើម្បីកាប់ដើមទន្ទ្រានខែត្រ និងកាប់ដីដំបូក។ នៅពេលនោះអង្គការខ្មែរក្រហមក៏បានបើកបង្រៀនកុមារ គឺមានរយៈពេល ១ទៅ២ម៉ោងក្នុងមួយថ្ងៃ ប៉ុន្តែខ្ញុំរៀនមិនសូវចេះទេ។

នៅក្នុងកងកុមារមានសមាជិកប្រមាណ២០ទៅ៣០នាក់។ ចំណែកការហូបចុកគឺមិនគ្រប់គ្រាន់ទេ និងធ្វើការងារពលកម្មលំបាក ប៉ុន្តែខ្ញុំហាក់មានសំណាងបន្តិច ដោយសារប្រធានភូមិនៅទីនោះធ្លាប់រស់នៅក្បែរផ្ទះខ្ញុំ និងមានការរាប់អានជាមួយឪពុកម្តាយខ្ញុំ ។ គាត់តែងតែប្រាប់ប្រធានកងកុមារឱ្យជួយមើលខ្ញុំ។ ដោយសារការហូបចុកមិនគ្រប់គ្រាន់ ខ្ញុំក៏លួចរត់ទៅរកជីតាដែលមើលថែទាំពពែនៅភូមិព្រៃផ្តៅ។ នៅពេលបាត់ខ្ញុំ ប្រធានកងកុមារបានតាមរក និងជួបខ្ញុំនៅជាមួយជីតា ក៏យកខ្ញុំមកវិញ។ ប្រធានកងកុមារបានដាក់ពិន័យឱ្យទៅនៅលើកោះមួយ បើចង់រត់មកវិញគឺត្រូវហែលឆ្លងទឹក។ នៅខណៈពេលនោះខ្មែរក្រហមបានដាក់ពិន័យខ្ញុំ ដោយឱ្យកងឈ្លប២នាក់ ជិះកង់ហើយឱ្យខ្ញុំរត់ពីមុខកង់ចម្ងាយប្រហែល១៧ ទៅ១៨ គីឡូម៉ែត្រ។ នៅលើកោះ ការងារដែលត្រូវធ្វើ គឺនៅរដូវទឹកសម្រកគឺត្រូវកាត់ស្មៅប្រមូលដាក់ម្តុំ។ នៅលើកោះមានកងយុវជន កងនារី និងកងកុមារ។ បន្ទាប់មកខ្មែរក្រហមយកខ្ញុំមកនៅកងកុមារវិញ។ ខ្ញុំបានលួចរត់ម្តងទៀត គឺរត់ទៅនៅជាមួយឪពុកខ្ញុំដែលខ្មែរក្រហមចាត់តាំងឱ្យនៅក្នុងកងភ្ជួរ។ ឪពុកខ្ញុំបានទៅសុំអង្វរប្រធានភូមិដែលរាប់អានជាមួយឪពុកខ្ញុំ ទើបខ្ញុំអាចរស់នៅជាមួយគាត់ និងជួយឃ្វាលគោ ហើយមេកងកុមារឈប់មកតាមរកខ្ញុំទៀត។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រុមគ្រួសារខ្ញុំបានរត់ទៅជាមួយខ្មែរក្រហម ពីព្រោះនៅក្នុងភូមិខ្ញុំមានយន្តហោះហោះមកក្រវែល។ អ្នកភូមិមានការភ័យខ្លាចក៏នាំគ្នារត់តាមខ្មែរក្រហមមកដល់ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ក៏បានជួបកងទ័ពវៀតណាម។ កងទ័ពវៀតណាមបានប្រាប់អ្នកភូមិឱ្យត្រឡប់មកស្រុកកំណើតវិញ។ ពេលមកដល់ស្រុកកំណើតទើបខ្ញុំបានចូលរៀនសូត្រ។ នៅឆ្នាំ១៩៩៧ ខ្ញុំបានរៀនចប់ និងចេញធ្វើគ្រូឯកទេសភូមិ-ប្រវត្តិនៅអនុវិទ្យាល័យបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ នៅឆ្នាំ២០០៨ ខ្ញុំបានផ្លាស់មកបង្រៀននៅអនុវិទ្យាល័យ ហ៊ុនសែនថ្មដា ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ។

# ចូលរៀនពេទ្យនៅប្រទេសវៀតណាម បន្ទាប់ពីរត់គេចខ្លួនពីរបបខ្មែរក្រហម

**សោម ប៊ុនថន**

ខ្ញុំឈ្មោះ គង់ សារ៉េត កើតនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៥០ នៅភូមិខាងកើតវត្ត ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិកៀនសាំង សង្កាត់កៀនសាំង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ខ្ញុំមានឪពុកឈ្មោះ គង់ សន និងម្ដាយឈ្មោះ ប៊ិន តឿយ។ ឪពុកម្ដាយរបស់ខ្ញុំស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ក្នុងនោះស្លាប់អស់២នាក់។ សព្វថ្ងៃបងប្អូនខ្ញុំនៅរស់តែ៤នាក់តែប៉ុណ្ណោះ គឺ២នាក់រស់នៅខេត្តព្រៃវែង និង២នាក់រស់នៅខេត្តស្វាយរៀង។



គង់ សារ៉េត គឺជាបុគ្គលិកពេទ្យចូលនិវត្តន៍ សព្វថ្ងៃរស់នៅភូមិកៀនសាំង សង្កាត់កៀនសាំង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីក្មេងខ្ញុំរៀនដល់ថ្នាក់ទី៨ពីសង្គមចាស់ក៏ឈប់រៀន។ បន្ទាប់មក ខ្ញុំបានរៀបការជាមួយប្ដីឈ្មោះ ស្រី ដួង ធ្វើជាអនុរក្សពន្ធនាគារ (តេ៣) នៅទីក្រុងភ្នំពេញ។ ខ្ញុំចាំថា នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ នៅក្នុងភូមិកំណើតរបស់ខ្ញុំមានយន្តហោះចម្បាំងកងទ័ពធីវគី (វៀតណាមខាងត្បូង) ដែលគាំទ្រដោយសហរដ្ឋអាមេរិក ហោះមកទម្លាក់គ្រាប់បែកលើកងទ័ពវៀតកុង (វៀតណាមខាងជើង) ដែលលាក់ខ្លួននៅតាមបណ្ដោយព្រំដែនក្នុងទឹកដីប្រទេសកម្ពុជា ដូចជាឃុំចន្ទ្រា ក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង ស្ថិតនៅជាប់នឹងឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដូច្នេះធ្វើឱ្យប្រជាជននៅក្នុងភូមិរបស់ខ្ញុំភ័យខ្លាចយ៉ាងខ្លាំង។ នៅវេលាម៉ោងពារសៀល ឪពុម្ដាយម្ដាយខ្ញុំនិងប្រជាជនក្នុងភូមិនាំគ្នាដាំបាយហូបគ្រប់គ្នា ព្រោះភ័យខ្លាចពេលយន្តហោះចម្បាំងកងទ័ពធីវគីហោះមកទម្លាក់គ្រាប់បែកម្ដងៗយើងត្រូវរត់គេចខ្លួន និងមិនមានពេលដាំបាយហូប។ ការទម្លាក់គ្រាប់បែកពេលនោះបានបណ្ដាលឱ្យមនុស្សរងរបួស ស្លាប់ ឆេះផ្ទះសម្បែង និងខូចទ្រព្យសម្បត្តិប្រជាជនអស់ជាច្រើន។ បន្ទាប់ពីកងទ័ពធីវគីទម្លាក់គ្រាប់រួច កងទ័ពវៀតកុងបានចូលមកជួយសង្គ្រោះ និងព្យាបាលប្រជាជនដែលរងរបួសនៅតាមភូមិ ដែលស្ថិតនៅឆ្ងាយពីមន្ទីរពេទ្យ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ធ្វើ

ឱ្យស្ថានភាពនៅក្នុងភូមិកាន់តែច្របូកច្របល់ ហើយក្រោយមកខ្ញុំក៏ផ្លាស់មករស់នៅជាមួយប្តីនៅទីក្រុងភ្នំពេញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយចូលដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ និងបានជម្លៀសប្រជាជនទៅរស់នៅជនបទ ស្រុកស្រែចម្ការ និងឱ្យធ្វើការជាទម្ងន់ៗ ខ្ញុំនិងគ្រួសារត្រូវខ្មែរក្រហមជម្លៀសមកស្រុកកំណើត នៅឃុំត្នោត ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀងវិញ។ នៅពេលនោះ ប្រជាជនមូលដ្ឋានរើសអើងគ្រួសារខ្ញុំខ្លាំងណាស់ ព្រោះគ្រួសារខ្ញុំគឺជាប្រជាជនថ្មី។ ខ្មែរក្រហមនៅមូលដ្ឋានដែលស្គាល់ឪពុកខ្ញុំបានចោទប្រកាន់ឪពុកខ្ញុំថា អតីតភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់ លន់ នល់ ហើយបានហៅឪពុកខ្ញុំទៅរៀនសូត្រ និងបាត់រហូតមកសព្វថ្ងៃ។ ចំណែកខ្ញុំ និងប្តីត្រូវបានខ្មែរក្រហមចាត់តាំងឱ្យទៅនៅកងចល័ត ធ្វើការងារលើកទំនប់ និងធ្វើស្រែ។ ក្រោយមក ប្រធានកងបានបញ្ជូនប្តីខ្ញុំឱ្យទៅនៅ និងធ្វើការនៅម្តុំវត្តពេជ្រមន្ត្រី ហៅវត្តខត្តុង្គ ក្នុងឃុំប្រសូត្រ ស្រុកប្រសូត្រ ដែលជាកន្លែងលត់ដំរបស់ខ្មែរក្រហម។ ពេលនោះ ខ្ញុំបានសុំប្រធានកងយកអាហារបន្តិចបន្តួចទៅឱ្យប្តីរបស់ខ្ញុំ ហើយមុនពេលត្រឡប់មកកងរបស់ខ្ញុំវិញ ខ្ញុំបានលួចខ្សឹបប្រាប់ប្តីខ្ញុំថា ប្រសិនបើបងមិនឃើញខ្ញុំនៅក្នុងភូមិ គឺខ្ញុំរត់ភៀសខ្លួនទៅប្រទេសវៀតណាមហើយ។ ក្រោយមកខ្មែរក្រហមបញ្ជូនប្តីរបស់ខ្ញុំទៅឃុំឃាំងនៅមន្ទីរសន្តិសុខព្រៃធ្លក ស្ថិតនៅក្នុងវត្តព្រៃធ្លក ភូមិព្រៃធ្លក ឃុំស្វាយតាយាន ស្រុកកំពង់រោទ៍។ នៅទីនោះប្តីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ រាកធ្ងន់ធ្ងរ។ កូន និងប្អូនរបស់ខ្ញុំបានទៅសួរសុខទុក្ខប្តីរបស់ខ្ញុំ និងបានលួចយកដំឡូងដុតមួយមើមឱ្យគាត់។ បន្ទាប់ពីប្តីរបស់ខ្ញុំហូបដំឡូងរួចគាត់ក៏ស្លាប់នៅខែតុលា ឆ្នាំ១៩៧៧។ ខ្ញុំដឹងថាមានអ្នកភូមិរបស់ខ្ញុំដែលជាប់ឃុំឃាំងជាមួយប្តីរបស់ខ្ញុំនៅក្នុងមន្ទីរសន្តិសុខព្រៃធ្លក នៅរស់រានមានជីវិតតែពីរនាក់ប៉ុណ្ណោះគឺឈ្មោះ ម៉ាន់ ទន់ ក្រោយមកធ្វើពេទ្យផ្នែកឫសដូងបាត សព្វថ្ងៃរស់នៅខេត្តកំពង់ធំ និងឈ្មោះ វ៉ិត ក្រោយមកធ្វើការនៅក្រសួងដឹកជញ្ជូន និងគមនាគមន៍។

រយៈពេល៤ខែបន្ទាប់ពីប្តីរបស់ខ្ញុំស្លាប់ គឺនៅខែមករា ឆ្នាំ១៩៧៨ ខ្ញុំបានរត់គេចខ្លួនទៅនៅតាមជំរំក្នុងប្រទេសវៀតណាម។ ពេលចូលទៅដល់ដំបូង ខ្ញុំត្រូវដើរកាប់ដើមឈើតូចៗដើម្បីសង់រោងស្នាក់នៅបណ្តោះអាសន្នដោយខ្លួនឯង។ ចំណែករបបអាហារពេលនោះ អាជ្ញាធរវៀតណាមបានបើកអង្ករឱ្យខ្ញុំប៉ុន្តែមានកំណត់ ដូច្នេះខ្ញុំត្រូវដាំត្រកួន ដំឡូងត្រាវ សាគូ នៅជុំវិញជំរំទុកហូបបន្ថែម។ នៅទីនោះប្រជាជនភៀសខ្លួនខ្មែរដែលចេះក្រងកន្ទេលបានទៅដកអញ្ចូតតាមវាល និងតាមព្រៃយកមកក្រងលក់។ ប្រជាជនខ្លះទៀតដើររើសក្តួរស្រូវតាមវាលស្រែមកបុកហូប ដោយឡែកខ្ញុំបានទៅធ្វើការងារបម្រើប្រជាជនវៀតណាមនៅតាមផ្ទះ ដោយទទួលបានប្រាក់២ដុងក្នុងមួយថ្ងៃ។ ក្រោយមក អាជ្ញាធរវៀតណាមសង្កេតឃើញខ្ញុំចេះសរសេរអក្សរខ្មែរ ក៏ឱ្យខ្ញុំកត់ឈ្មោះ, អាយុ, ទីកន្លែងកំណើត, ភូមិឃុំស្រុកខេត្តរបស់ជនភៀសខ្លួនខ្មែរដែលមករស់នៅក្នុងជំរំជនភៀសក្នុងទឹកដីប្រទេសវៀតណាម។ ខ្ញុំធ្វើការខាងកត់ត្រាបញ្ជីឈ្មោះជនភៀសខ្លួនបានមួយរយៈ មេឃុំវៀតណាមបានបញ្ជូនខ្ញុំឱ្យទៅរៀនភាសាវៀតណាម បន្ទាប់មកទើបចាត់តាំងខ្ញុំរួមទាំងស្ត្រីជនភៀសខ្លួនខ្មែរ៥នាក់ទៀត ទៅរៀនពេទ្យទូទៅនៅមន្ទីរពេទ្យឌឹកវ៉ា (ប្អុមុខវ៉ា) រយៈពេល៣ខែ។ មន្ទីរពេទ្យនេះស្ថិតនៅក្នុងស្រុកឌឹកវ៉ា ខេត្តឡុងអាង និងមានចម្ងាយប្រមាណ៦៥គីឡូម៉ែត្រពីស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។ អំឡុងពេលខ្ញុំរៀនពេទ្យនៅប្រទេសវៀតណាម មានទឹកជំនន់លិចទីតាំងជាច្រើនក្នុងខេត្តឡុងអាន រួមទាំងមន្ទីរពេទ្យខ្ញុំដែរ ដូច្នេះអាជ្ញាធរវៀតណាមក៏បានជម្លៀសជនភៀសខ្លួនខ្មែរមួយចំនួនពីជំរំឱ្យទៅនៅប៊ិនឡឹប គួធឿ និងតាន់ប៊ិនៗ ដោយឡែកខ្ញុំមិនបានជម្លៀសទៅណាទេ គឺនៅអង្គភាពពេទ្យដដែល។ ដោយសារទឹកលិចជ្រៅត្រឹមក ដូច្នេះពេលដេកខ្ញុំត្រូវកល់គ្រែឱ្យផុតពីទឹក។ ទោះបីយ៉ាងណាការរស់នៅរបស់ខ្ញុំមិនសូវលំបាកទេ

ព្រោះអាជ្ញាធរវៀតណាមបានផ្តល់អាហារឱ្យខ្ញុំបានហូបគ្រប់គ្រាន់ និងផ្តល់ប្រាក់ឱ្យខ្ញុំក្នុងមួយខែ៣៦ដុង ប៉ុន្តែត្រូវកាត់ចេញ៣០ដុងសម្រាប់ថ្លៃអាហារ ដូច្នេះនៅសល់តែ៦ដុងប៉ុណ្ណោះ។

ក្រោយមកនៅក្នុងចំណោមអ្នករៀនពេទ្យទាំង ៥នាក់ដែលវៀតណាមបានជ្រើសរើស នៅសល់តែ៣នាក់ប៉ុណ្ណោះរួមទាំងខ្ញុំ ចំណែកនារីពីរនាក់ទៀតបានឈប់រៀនដោយសារម្នាក់វិលត្រឡប់ទៅនៅជាមួយកូនតូច និងម្នាក់ទៀតចេញទៅរស់នៅជាមួយប្តី។ អំឡុងពេលខ្ញុំកំពុងរៀន ខ្ញុំក៏ទទួលដំណឹងពីជនភៀសខ្លួនខ្មែរដែលចូលមករស់នៅវៀតណាមថា ប្រជាជនខ្មែរស្លាប់ច្រើនព្រោះត្រូវខ្មែរក្រហមជម្លៀសទៅខេត្តភាគខាងលិច និងពាយ័ព្យរួមមាន ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ហើយគ្មានអាហារហូបគ្រប់គ្រាន់ និងការយកទៅសម្លាប់។



គង់ សារ៉េត និងប្តីឈ្មោះ ស្រី ដួង ថតរូបបន្ទាប់ពីរៀបការរួច នៅទសវត្សរ៍ឆ្នាំ១៩៧០។

នៅខែឧសភា ឆ្នាំ១៩៧៩ បន្ទាប់ពីកងទ័ពវៀតណាមរំដោះប្រទេសកម្ពុជា បានរយៈពេល៥ខែ ទើបខ្ញុំវិលត្រឡប់មករស់នៅស្រុកកំណើត នៅខេត្តស្វាយរៀងវិញ។ ខ្ញុំបានស្នើសុំរដ្ឋអំណាចចូលបម្រើការងារនៅមន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង រហូតដល់ឆ្នាំ២០០៥ ទើបខ្ញុំចូលនិវត្តន៍។

រហូតមកដល់សព្វថ្ងៃខ្ញុំនៅតែមានកំហឹង និងឈឺចាប់ជាមួយខ្មែរក្រហម ព្រោះរបបនេះបានធ្វើឱ្យខ្ញុំបាត់បង់ឪពុករបស់ខ្ញុំប្តីរបស់ខ្ញុំរួមទាំងសាច់ញាតិមួយចំនួន។ សព្វថ្ងៃខ្ញុំរំសាយកំហឹងបានខ្លះដោយសារតែខ្ញុំមានវ័យកាន់តែចាស់ជរា និងឈឺសន្លាក់ពុំរើ ចំណែកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនក៏បានស្លាប់ហើយដែរ។



ស្រី ដួង ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។

# នាង មាន ៖ ខ្ញុំពិការ តែខ្ញុំមិនសោកស្តាយទេ

**លី សុខឃាង**

នាង មាន ភេទស្រី អាយុ៦៧ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិស្រែជា ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត។ បច្ចុប្បន្ន នាង មាន រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ នាង មាន បានរៀបរាប់ថា ៖ «ខ្ញុំជាកូនទី២ក្នុងចំណោមបងប្អូនចំនួន៦នាក់ (ស្រី៣នាក់ និងប្រុស៣នាក់)។ កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រនោះទេ។ មុនសម័យខ្មែរក្រហម ក្រុមគ្រួសាររបស់ខ្ញុំមានជីវភាពធូរធារ ពីព្រោះឪពុកម្តាយរបស់ខ្ញុំមិនដែលខ្វះស្រូវ និងខ្វះបុលអ្នកណានោះទេ។ ក្រុមគ្រួសាររបស់ខ្ញុំមានផ្ទះនៅសមរម្យ និងមានចិញ្ចឹមសត្វគោ។ ខ្ញុំចូលបម្រើជាកងដឹកជញ្ជូនខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧២ ដែលកាលណោះខ្ញុំទើបតែមានអាយុ១៨ឆ្នាំ។ ខ្មែរក្រហមមិនឱ្យយើងរស់នៅជួបជុំក្រុមគ្រួសារទៀតទេ។ ខ្មែរក្រហមបានបែងចែកមនុស្សគ្រប់រូបឱ្យមានការងារទៅតាមក្រុម និងតាមពួក ដោយអ្នកខ្លះចូលទៅក្នុងកងនារីដឹកជញ្ជូន និងកងទ័ពនារី។ ខ្ញុំត្រូវចូលរួមក្នុងចលនាបដិវត្តន៍បែបនេះ ដោយសារតែយើងម្នាក់ៗត្រូវបានអំពាវនាវឱ្យចូលព្រៃម៉ាគីដើម្បីដណ្តើមអំណាចឱ្យសម្តេចព្រះ នរោត្តម សីហនុ។ ប៉ុន្តែផ្ទុយទៅវិញ យើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។

បន្ទាប់ពីរបបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ខ្ញុំមិនហ៊ានវិលត្រឡប់ទៅផ្ទះវិញទេ ពីព្រោះពុំពាក្យចចាមអារ៉ាមថា កងទ័ពវៀតណាមនឹងអារកសម្លាប់យើងនឹងធាងត្នោត។ ខ្ញុំត្រូវភៀសខ្លួនមកតាមព្រំដែនខ្មែរថៃ និងធ្វើជាកងដឹកជញ្ជូនអាហារ។ ខ្ញុំទទួលបានរបបអាហារហូបចុកចំនួនបីពេលក្នុងមួយថ្ងៃ។ បើមិនដូច្នោះទេ យើងមិនមានកម្លាំងដឹកជញ្ជូននោះទេ។



នាង មាន អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាទូទៅ ខ្ញុំដឹកជញ្ជូនគ្រាប់បេ៤០ គ្រាប់កាំភ្លើងអាកា (១កេស) និងមីនគោន(១គ្រាប់) ពីព្រំដែនថៃទៅកាន់សមរភូមិសៀមរាប។ ក្រៅពីនេះ យើងក៏ដឹកជញ្ជូនអង្ករ ប្រហុក អំបិល និងថ្នាំពេទ្យ ដែលយើងម្នាក់ៗប្រៀបបានទៅនឹងឡានដឹកជញ្ជូនដូច្នោះដែរ។ ជីវិតជាកងនារីដឹកជញ្ជូនថ្វីត្បិតតែគ្រោះថ្នាក់ក៏ពិតមែន ប៉ុន្តែខ្ញុំមើលឃើញថាការហូបចុកហាក់ប្រសើរជាងប្រជាជនរស់នៅក្នុងសហករណ៍ឆ្ងាយណាស់។ កងទ័ពនៅត្រង់ណា កងនារីនៅពីក្រោយរហូត។

ក្រោយមក ខ្ញុំក៏ពិការជើងម្ខាងដោយសារជាន់មីននៅត្រង់ចំណុចអូរខ្សាច់។ កម្លាំងដឹកជញ្ជូនរបស់ខ្ញុំបានសែងខ្ញុំទៅមន្ទីរពេទ្យ ដោយនៅពេលនោះខ្ញុំមានស្មារតីនៅឡើយ។ រហូតទៅដល់មន្ទីរពេទ្យ ក្រុមគ្រូពេទ្យបានចាក់ថ្នាំសន្លប់ ហើយខ្ញុំក៏បាត់បង់ស្មារតីប្រមាណជាង១ម៉ោង។ ឪពុកម្តាយរបស់ខ្ញុំមិនបានដឹងរឿងពិការភាពនេះទេ រហូតទល់តែបញ្ចប់សង្គ្រាមនៅអន្លង់វែងក្នុងឆ្នាំ១៩៩៨ ទើបខ្ញុំបានទៅជួបជុំគ្នាវិញ។

បន្ទាប់ពីជាសះស្បើយ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅរស់នៅជំរំជនពិការ យន់យុត។ នៅទីនោះ យើងទទួលបានការផ្គត់ផ្គង់ស្បៀងអាហារប្រចាំថ្ងៃដូចជា អង្ករ ត្រីខ ស្ករស និងទឹកត្រីជាដើម។ ពេលខ្លះយើងក៏មានការខ្វះខាតដែរ ដោយសារស្ថានភាពរស់នៅ គឺពឹងតែបាយស៊ុបទ្ធសាធរួមផ្សំនឹងការចិញ្ចឹមសត្វ។ នៅពេលខ្ញុំធ្លាក់ខ្លួនពិការ ខ្ញុំមិនមានការសោកស្តាយនោះទេ។ វាជាកំហុសរបស់ខ្ញុំ ដែលចូលរួមក្នុងចលនាបដិវត្តន៍ខ្មែរក្រហម។ យុវជន យុវនារីមួយចំនួនបានដើរជាន់មីនស្លាប់នៅក្នុងព្រៃជារឿយៗ។ នៅពេលធ្លាក់ខ្លួនពិការ ខ្ញុំក៏មិនមានចេតនាចង់សម្លាប់ខ្លួននោះទេ។ ខ្ញុំចង់រស់នៅតាមដំណើរជីវិតរបស់ខ្ញុំ។ ខ្ញុំប្រឈមមុខនឹងពិការភាពត្រង់ថា ខ្ញុំធ្វើអ្វីមិនកើតនោះទេ ហើយក៏មិនដឹងធ្វើយ៉ាងណាដែរ។

ខ្ញុំបានរៀបការនៅមុនពេលខ្ញុំពិការភាព ដោយរៀបជាគូ។ កាលនោះ យើងរៀបការរួមគ្នាចំនួន១២គូ។ ជាដំបូង ខ្មែរក្រហមបានឱ្យយើងគោរពវិញ្ញាណក្ខន្ធ ហើយខ្ញុំមើលឃើញមានទង់ក្រហម រូបញញួរ និងកូរស្រូវ។ ខ្មែរក្រហមបានឱ្យយើងគោរពទង់នោះ បន្ទាប់ពីយើងត្រូវឡើងប្តេជ្ញាចិត្ត។ នៅពេលនោះ ខ្ញុំប្រកែកថា ខ្ញុំមិនចាំបាច់ប្តេជ្ញាទេ។ ខ្ញុំស្រឡាញ់គ្នាចិត្តនឹងចិត្ត។ ខ្ញុំមិនដែលរត់ទៅណាចោលប្តីទេ។ យើងមិនទាន់បានរួមរស់ជាមួយគ្នាទេ ដោយសារខ្មែរក្រហមបានបញ្ជូនប្តីរបស់ខ្ញុំទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅសមរភូមិខាងក្នុងប្រទេស។ រយៈពេលប្រមាណជា៧ខែក្រោយមក ទើបខ្ញុំបានជួបគ្នាវិញ។ កាលដែលខ្ញុំនៅមូលដ្ឋានខាងក្រោយ ខ្ញុំទទួលបានអាហារហូបចុកពីអង្គការសហប្រជាជាតិ ដូចជា ត្រីខ ត្រីកាម៉ុង។

ទោះខ្ញុំក្រលំបាកដល់កម្រិតណាក៏ដោយ ក៏ខ្ញុំមិនទៅសុំទាននោះដែរ។ ខ្ញុំគិតថា ខ្ញុំថោក។ ខ្ញុំសុខចិត្តលូនរនាលកាប់ព្រៃធ្វើចម្ការដើម្បីចិញ្ចឹមជីវិតវិញ។ នៅពេលសមាហរណកម្មនៅតំបន់អន្លង់វែងលើកដំបូង ខ្ញុំធ្លាប់ជួបប្រទះការរើសអើងនៅពេលទៅទិញអីវ៉ាន់ពីចិននៅផ្សារអន្លង់វែង។ ក្រោយមក នៅពេលខ្ញុំទទួលបានប្រាក់បៀវត្សរ៍ជនពិការ ទើបការរើសអើងនេះបានធូរស្រាលឡើងវិញ។ យ៉ាងណាក៏យើងតាំងចិត្តថា អ្នកមើលងាយយើង មិនបានចិញ្ចឹមយើងនោះទេ។ ខ្ញុំបានចុះមករស់នៅតំបន់អន្លង់វែងនៅក្នុងឆ្នាំ១៩៩០ ដោយចាប់ដីធ្លី និងកាប់ព្រៃលំនៅឋានដោយខ្លួនឯង ដោយប្រឈមនឹងគ្រាប់មីនជាច្រើននៅក្នុងដី»។




ចម្ការមីនមួយកន្លែងកំពុងត្រូវបានបោសសម្អាត ស្ថិតនៅក្នុងភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅខែឧសភា ឆ្នាំ២០២១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម្តាយរបស់ គុល ត្រូវបានខ្មែរក្រហមបង្ខំឱ្យលើកប្រឡាយរហូតដល់ស្លាប់

**ចាន់ ណារិទ្ធ**

ក្នុងឆ្នាំ១៩៧៦ ម្តាយរបស់ គុល ត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការយ៉ាងធ្ងន់ធ្ងរ និងមិនផ្តល់អាហារឱ្យហូបគ្រប់គ្រាន់ រហូតធ្វើឱ្យម្តាយរបស់ គុល ដួលស្លាប់ក្នុងអំឡុងពេលកំពុងលើកប្រឡាយ។ ប៉ូ គុល បានរៀបរាប់ពីរឿងរ៉ាវដូចខាងក្រោម៖



ប៉ូ គុល អាយុ៦០ឆ្នាំ ប្រកបមុខរបរធ្វើចម្ការ សព្វថ្ងៃរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ូ គុល ភេទប្រុស អាយុ៦០ឆ្នាំ សព្វថ្ងៃមានមុខរបរធ្វើចម្ការ។ គុល មានស្រុកកំណើតនៅភូមិតាម៉ាន់ ឃុំគងជ័យ ស្រុកដើងព្រៃ ខេត្តកំពង់ចាម។ បច្ចុប្បន្នរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ គុល មានឪពុកឈ្មោះ ប៉ូ វ៉ែន (ស្លាប់ក្នុងរបបលន់នល់) និងម្តាយឈ្មោះ សុំ វ៉ែន (ស្លាប់ក្នុងឆ្នាំ១៩៧៧ នៅសម័យខ្មែរក្រហម)។ គុល មានបងប្អូនចំនួន៥នាក់ (ស្រី២នាក់ និងប្រុស៣នាក់)។ គុល ជាកូនទី៤នៅក្នុងគ្រួសារ។ គុល មានប្រពន្ធចំនួន២នាក់។ ប្រពន្ធទីមួយ ឈ្មោះ ឈឿន នាង និងមានកូនប្រុសម្នាក់។ ប្រពន្ធទីពីរឈ្មោះ លឹម វ៉ែម អាយុ៦១ឆ្នាំ មានកូន៤នាក់ (ប្រុស២នាក់ និងស្រី២នាក់)។ សព្វថ្ងៃ គុល រស់នៅជាមួយកូនទី២ និងកូនទី៤ ហើយប្រកបរបរធ្វើចម្ការ។

កាលពីវ័យកុមារ គុល មិនបានចូលរៀនទេព្រោះសាលានៅឆ្ងាយ បើចង់ទៅរៀនលុះត្រាតែទៅស្នាក់នៅក្នុងវត្ត។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែង។ ក្នុងអំឡុងពេលនោះ គុល រស់នៅស្រុកកំណើតជាមួយឪពុកម្តាយមិនបានជម្លៀសទៅណាទេ។ បន្ទាប់ពីទម្លាក់សម្តេចព្រះនរោត្តម សីហនុ មិនបានប៉ុន្មានថ្ងៃ គុល បានឃើញប្រជាជនជាច្រើនបានធ្វើដំណើរថ្មើរជើងឡើងទៅធ្វើបាតុកម្មនៅទីរួមខេត្តកំពង់ចាម។ ប្រជាជនទាំងអស់ក្នុងដៃមានកាន់សម្ភារដូចជា ដំបង កាំបិត លំពែង និងពូថៅជាដើម។ ប្រជាជនដែលឡើងទៅធ្វើបាតុកម្មភាគច្រើនត្រូវបានទាហាន លន់ នល់ បាញ់សម្លាប់ ហើយមួយចំនួនទៀតបានរងរបួស និងមួយចំនួនទៀតត្រូវបានចាប់យកទៅធ្វើទាហាន លន់ នល់ ដើម្បី

បង្កើនកម្លាំងទាហានបន្ថែម។ នៅក្នុងឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ស្ថានភាពក្នុងភូមិរបស់ គុល មានភាពធូរស្បើយវិញ ប្រជាជនអាចប្រកបរបរធ្វើស្រែចម្ការបានធម្មតា។

នៅឆ្នាំ១៩៧៣ ខាងទាហាន លន់ នល់ ចាប់ផ្តើមធ្វើការទម្លាក់គ្រាប់បែកមកលើភូមិ គុល ដែលកំពុងរស់នៅ។ ពេលមានសំឡេងយន្តហោះ ប្រជាជនក្នុងភូមិតែងតែនាំគ្នារត់ពួនក្នុងត្រង់សេ ចំណែកអ្នកដែលត្រូវចុះទៅធ្វើស្រែក៏លែងហ៊ានធ្វើស្រែបន្ត។

នៅក្នុងខែតុលា ឆ្នាំ១៩៧៤ ទាហាន លន់ នល់ ចាប់ផ្តើមជម្លៀសប្រជាជនឱ្យទៅរស់នៅខេត្តកំពង់ធំ និងបានបោះជាជំរំមួយដោយដាក់ឈ្មោះថា ជំរំស្មោង។ គុល រស់នៅជំរំស្មោងបានរយៈពេលមួយខែ ក៏មានកងទ័ពខ្មែរក្រហមវាយចូលមករំដោះ និងបានវាយបណ្តេញទាហាន លន់ នល់ ចេញពីជំរំស្មោង។ បន្ទាប់ពីទទួលបានជ័យជម្នះទៅលើទាហាន លន់ នល់ កងទ័ពខ្មែរក្រហមបានអំពាវនាវឱ្យប្រជាជនដែលរស់នៅជំរំស្មោងធ្វើដំណើរត្រឡប់ទៅខេត្តកំពង់ធំវិញ។ ពេលដែលត្រឡប់មកដល់ខេត្តកំពង់ធំ គុល និងកុមារចំនួន៨នាក់ទៀត ត្រូវអង្គការខ្មែរក្រហមចាត់តាំងឱ្យឃ្វាលគោ ក្របី តាមក្រុមកងភ្ជួរ។ ក្នុងមួយថ្ងៃក្រុម គុល ត្រូវធ្វើការរយៈពេល៦ម៉ោង ចាប់ពីម៉ោង១១រហូតដល់ម៉ោង៥ល្ងាច។ ពេលដែលដើរជាមួយក្រុមកងភ្ជួរ សម្រាប់អាហារហូបចុករបស់ គុល ក្នុងមួយថ្ងៃហូបបានតែពីរពេល គឺពេលព្រឹក និងពេលល្ងាច។ ចំណែកម្តាយ គុល និងប្រជាជនផ្សេងទៀត ខ្មែរក្រហមចាត់តាំងឱ្យធ្វើស្រែប្រវាស់ដៃគ្នា។ បន្ទាប់មក ខ្មែរក្រហមចាប់ផ្តើមបង្កើតសហករណ៍ ហើយខ្មែរក្រហមបានដើរប្រមូលស្រូវដែលបានចែកឱ្យប្រជាជន និងប្រមូលចានឆ្នាំងដាក់រួម ហូបរួម និងធ្វើការរួមគ្នា។

នៅឆ្នាំ១៩៧៦គុល និងកុមារនៅក្នុងភូមិប្រហែល៦០នាក់ ក្នុងនោះមានទាំងប្រុសទាំងស្រី ត្រូវបានខ្មែរក្រហមប្រមូលឱ្យចូលធ្វើការងារក្នុងកងកុមារ។ ការងារដែលខ្មែរក្រហមប្រើឱ្យ គុល ធ្វើ គឺពេលព្រឹកត្រូវដើរកាប់ទន្ទ្រានខែត្រឱ្យបានមួយបាច់ ហើយយកមកចិញ្រ្ចាំដាក់ក្នុងអាង ពេលថ្ងៃរសៀលត្រូវដើររកកាប់ដីដំបូក ក្នុងម្នាក់ពូតដីឱ្យបាន៤ដុំ និងដើរកើបលាមកតាមផ្ទះ ឬតាមវាលដើម្បីលាយបញ្ចូលគ្នាផ្អាប់ទុកដើម្បីដាក់ស្រែនៅរដូវវស្សា។ ក្នុងឆ្នាំដដែលខ្មែរក្រហមចាប់ផ្តើមយកប្រជាជនទៅសម្លាប់ ប្រជាជនដែលខ្មែរក្រហមយកទៅសម្លាប់ភាគច្រើនសុទ្ធតែអ្នកចេះដឹងមានដូចជា គ្រូបង្រៀន និស្សិត សាស្ត្រាចារ្យ បញ្ញវន្ត និងអ្នកខុសសីលធម៌។ អ្នកដែលយកប្រជាជនទៅសម្លាប់ភាគច្រើនគឺជាឈ្លប។ ក្នុងឆ្នាំដដែល ខ្មែរក្រហមចាប់ផ្តើមបង្ខំឱ្យធ្វើការកាន់តែធ្ងន់ធ្ងរគ្មានពេលវេលាសម្រាក ថែមទាំងមិនមានអាហារហូបគ្រប់គ្រាន់ ទើបធ្វើឱ្យម្តាយរបស់ គុល អស់កម្លាំងខ្លាំងស្លាប់នៅអំឡុងពេលកំពុងលើកប្រឡាយ។

ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ គុល ត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យចូលហ៊ឹកហាត់ផ្នែកយោធានៅខេត្តកំពង់ចាម។ អ្នកគ្រប់គ្រងខាងផ្នែកហ៊ឹកហាត់ឈ្មោះ ភាព (សព្វថ្ងៃស្លាប់)។ ក្នុងមួយថ្ងៃ គុល ហ៊ឹកហ៊ឺនរយៈពេល៥ម៉ោង គឺពេលព្រឹកចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង៩ព្រឹក។ ចំណែកពេលរសៀលចាប់ពីម៉ោង១ រហូតដល់ម៉ោង៤រសៀល។ ពេលយប់ ប្រសិនបើមានការប្រកាសអាសន្នត្រូវហ៊ឹកហ៊ឺនថែម២ម៉ោងទៀត។ គុល បាននិយាយរៀបរាប់ពីការលំបាក ពេលដែលចូលធ្វើជាកងទ័ពហ៊ឹកហាត់ខាងផ្នែកយោធា អាហារហូបចុកមិនបានគ្រប់គ្រាន់ នៅពេលឈឺថ្កាត់ម្តងៗគ្មានថ្នាំព្យាបាលមានតែគ្រាប់ស្វែងដែលពេទ្យឱ្យលេប។

នៅឆ្នាំ១៩៧៨ ពេលដែលកំពុងតែហ៊ឹកហាត់ស្រាប់តែកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយចូលមកក្នុងទីរួមខេត្តកំពង់ចាម។ ពេលនោះ គុល មានអារម្មណ៍ភិតភ័យជាខ្លាំង រួចបានលួចរត់ពីកន្លែងហ៊ឹកហាត់ត្រឡប់មកស្រុកកំណើតវិញជាមួយបងស្រី រួចប្រកបមុខរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។

# យិត ភឿន៖ កម្មផលរបស់ខ្ញុំ

## សួត វិចិត្រ

យិត ភឿន អាយុ៦៣ឆ្នាំ មានទីកន្លែងកំណើត នៅក្នុងស្រុកលំផាត់ ខេត្តរតនៈគិរី។ បច្ចុប្បន្ន ភឿន រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ភឿន បាននិយាយថា៖ «ខ្ញុំបានចូលគស៊ូក្នុងចលនាបដិវត្តន៍ខ្មែរក្រហមតាំងពីអាយុ១៥ឆ្នាំ។ ខ្ញុំបានរសាត់អណ្តែតមកកាន់តំបន់អន្លង់វែង ចាប់ពីឆ្នាំ១៩៧៩ ដោយសារកងទ័ពវៀតណាមបានបណ្តេញខ្មែរក្រហមចេញពីអំណាច។ ខ្ញុំបានបន្តដំណើរជាមួយកងទ័ពខ្មែរក្រហមមកកាន់ព្រំដែនភាគខាងជើងប្រទេសកម្ពុជារហូតមកដល់តំបន់អន្លង់វែង នៅដើមឆ្នាំ១៩៩០។



យិត ភឿន អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំមានអាយុ១៧ឆ្នាំក៏ត្រូវពិការភ្នែកម្ខាងដោយសារជំងឺ។ នៅពេលនោះ ខ្ញុំស្ថិតនៅកងចល័តរបស់ខ្មែរក្រហម ដោយត្រូវជីកប្រឡាយ និងលើកភ្លឺស្រែ។ ខ្ញុំចាប់ផ្តើមធ្លាក់ខ្លួនឈឺភ្នែកបន្តិចម្តងៗ រហូតដល់ហើមខ្លាំងមើលអ្វីលែងឃើញ។ ខ្ញុំមិនហ៊ានសុំច្បាប់អង្គការសម្រាក ដើម្បីទៅព្យាបាលភ្នែកទេ ដោយខ្ញុំនៅតែបន្តធ្វើការងារដោយភ្នែកធ្មេចម្ខាង។ នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមខ្ញុំមិនហ៊ានប្រកែក ឬតវ៉ាឡើយ ដោយសារខ្លាចអង្គការយកទៅសម្លាប់ចោល។ ខ្ញុំត្រូវរស់នៅជាមួយនឹងការតស៊ូ ហើយជាទូទៅ ខ្ញុំតែងតែប្រកាន់ក្នុងចិត្តថា ខ្មែរក្រហមគឺជាអ្នកឱ្យខ្ញុំរស់ ឬឱ្យខ្ញុំស្លាប់នៅពេលណាក៏បាន។

ខ្ញុំបានធ្វើការងារនៅក្រោមកម្តៅថ្ងៃ ជាមួយនឹងអាហារហូបចុកមិនគ្រប់គ្រាន់។ របបអាហារដែលខ្ញុំទទួលបានក្នុងមួយពេល បានត្រឹមអង្ករមួយក្តាប់តែប៉ុណ្ណោះក្នុងម្នាក់។ កងចល័តម្នាក់ៗបានលួចលាក់ហូបរុក្ខជាតិនៅក្បែរខ្លួនក្នុងការដ្ឋានដើម្បីហូបបន្ថែម ដូចជាដើមត្រែង ខ្ចីឬរុក្ខជាតិដទៃផ្សេងទៀតដែលអាចហូបបាន។ ចំពោះអ្នកឯទៀតក៏បានលួចលាក់ដាំទឹកក្តៅដោយបន្ថែមស្មៅរបំណីផ្សេងៗ។ ខ្ញុំបានយកជីវិតរបស់ខ្ញុំទៅប្រថុយប្រថាននឹងការហូបចុក ដើម្បីឱ្យបានរស់ពីមួយថ្ងៃទៅមួយថ្ងៃ។

ខ្ញុំត្រូវក្រោកទៅធ្វើការចាប់ពីម៉ោង៤ទៀបភ្លឺរហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបអាចត្រឡប់មកហូបបាយ។ មនុស្សម្នាក់ៗមិនអាចសម្រាកបានលើសពី១៥នាទីទេ បន្ទាប់ពីហូបបាយរួច ដោយសារសំឡេងជួងនឹងបន្ទរឡើងបញ្ជាក់ថាប្រជាជនទាំងអស់ត្រូវតែចុះទៅបន្តការងារ។ មិនមានអ្នកណាហ៊ានទម្រន់នឹងការងារទេ ដោយសារខ្លាចខ្មែរក្រហមយកទៅវាយចោល។ ដូចអ្វីដែលប្រជាជនទូទៅជឿថា ការចូលរួម

ក្នុងចលនាខ្មែរក្រហម គឺជាការលះបង់មួយដ៏ធំធេង សូម្បីតែក្រុមគ្រួសារ និងអាយុជីវិត។ រហូតដល់កងទ័ពវៀតណាមចូលក្នុងប្រទេសកម្ពុជា ទើបកងចល័តរបស់ខ្ញុំរត់ខ្ចាត់ខ្ចាយ។

ក្រោយមក ដោយសារភ្នែករបស់ខ្ញុំមានសភាពធ្ងន់ធ្ងរពេក ខ្ញុំក៏បានខ្នះខ្នែងទៅព្យាបាលនៅមន្ទីរពេទ្យខ្មែរក្រហមដោយខ្លួនឯង។ នៅទីនោះ ខ្ញុំបានសម្រាកអស់រយៈពេល៣ខែទើបជាសះស្បើយ។ ខ្ញុំបានចូលរួមក្នុងចលនាបដិវត្តន៍ខ្មែរក្រហមដោយលះបង់គ្រប់បែបយ៉ាង ហើយរហូតមកទល់បច្ចុប្បន្ននេះខ្ញុំធ្លាក់ខ្លួនពិការភ្នែកម្ខាង។

ខ្ញុំបានរៀបការជាមួយប្តីជាជនពិការដោយសារសង្គ្រាម។ គាត់បានពិការនៅពេលខ្ញុំមានកូនចំនួន៣នាក់ទៅហើយ។ ខ្ញុំបានឮស្គរគ្រាប់មីនផ្ទុះ ប៉ុន្តែភ្លាមៗនោះខ្ញុំមិនដឹងថា តើជានរណាដែលត្រូវស្លាប់ឬរងរបួសនោះទេ។ ខ្ញុំខំធ្វើនំ ធ្វើម្ហូបរង់ចាំប្តីដោយសារគិតថាប្តីមកពីហត់។ លុះក្រោយមក នៅពេលដឹងថាប្តីរបស់ខ្ញុំត្រូវរបួស ខ្ញុំ និងអ្នកភូមិផ្សេងទៀតបានទ្រហោយំនៅមន្ទីរពេទ្យតាម៉ុក។ ខ្ញុំបានទៅមើលគ្រូពេទ្យដែលកំពុងកាត់ជើងប្តីរបស់ខ្ញុំ។ ខ្ញុំបានឃើញគ្រូពេទ្យយករណារអារឆ្អឹងជើងរបស់ប្តីខ្ញុំ។ បន្ទាប់មក គ្រូពេទ្យបានលើកគាត់ទៅដាក់នៅលើគ្រែនៅពេលកាត់ហើយ។ ប្តីរបស់ខ្ញុំត្រូវសម្រាកព្យាបាលអស់រយៈពេល៣ខែបន្ថែមទៀត។ ក្រោយមក គាត់អាចធ្វើដំណើរជាមួយនឹងឈើច្រត់បាន ហើយមកលេងប្រពន្ធកូន។ ពេលនោះ គាត់បានរអិលដួលដោយជើងបុកនឹងដីទៀតធ្វើឱ្យមានការឈឺចាប់ម្តងទៀត។

ប្រវត្តិរបស់ខ្ញុំកម្សត់ខ្លាំងណាស់ ហើយកូនៗរបស់ខ្ញុំមិនសូវជឿទៅលើបទពិសោធន៍ឆ្លងកាត់ក្នុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហមទាំងនេះទេ។ ខ្ញុំចងចាំវិន័យរបស់ខ្មែរក្រហមថា៖ «ម្ទេសមួយផ្លែ សម្តីមួយម៉ាត់»។ ខ្មែរក្រហមបានឱ្យយើងទន្ទេញពាក្យនេះរហូតទាល់តែយើងចាំ ហើយមិនត្រូវប្រព្រឹត្តឡើយ។ ខ្ញុំបានធ្វើដំណើរជាមួយអង្គភាពកងទ័ពខ្មែរក្រហមឆ្លងកាត់ទន្លេមេគង្គទៅកាន់ព្រំដែនប្រទេសឡាវ។ ខ្ញុំបានហែលទឹកមួយយប់រហូតដល់ម៉ោង៥ទៀបភ្លឺទើបយើងបានឆ្លងផុត។ ប្តីរបស់ខ្ញុំចងដៃរបស់ខ្ញុំភ្ជាប់ជាមួយគាត់។ នៅពេលខ្ញុំពិបាកម្តងៗ ខ្ញុំស្ទើរតែប្រលែងខ្សែចោលដោយសារត្រជាក់ខ្លាំងពេក។ ប៉ុន្តែប្តីខ្ញុំបានឱ្យខ្ញុំតស៊ូឡើង ពីព្រោះបើមិនដូច្នោះទេ ខ្ញុំប្រាកដជាលង់ទឹកស្លាប់មិនខាន។ ប្តីរបស់ខ្ញុំជាអតីតកងទ័ពខ្មែរក្រហម។ គាត់មកជាមួយនីរសាររបស់គាត់។ នៅពេលយើងទៅដល់ច្រាំងម្ខាងទៀត ខ្ញុំត្រូវរងារញ័ររញាក់ និងរីងខ្លួនអស់ទៅហើយ។ នីរសាររបស់ប្តីខ្ញុំបានបង្កាត់ភ្លើងដើម្បីកម្តៅខ្លួនឱ្យខ្ញុំ។ នៅពេលខ្ញុំចាប់ផ្តើមក្តៅខ្លួនបន្តិចហើយ យន្តហោះស៊ើបការណ៍របស់កងទ័ពវៀតណាមបានបើកឆ្លងកាត់កន្លែងដែលយើងលាក់ខ្លួននៅត្រង់ចំណុចព្រៃឃ្វាលគោក្របី ខណៈមេឃភ្លឺល្អះៗ។ នៅពេលនោះ កងទ័ពលាវក៏មិនបានសួរយើងដែរ ដោយសារតែយើងបានប្រគល់ភួកដរី២គូឱ្យកងទ័ពលាវទាំងនោះ។ កងទ័ពលាវថែមទាំងបាននាំផ្លូវយើងថែមទៀតផង។ ប្រសិនបើមិនមានកងទ័ពលាវនាំផ្លូវទេ យើងនឹងវង្វេងក្នុងព្រៃជាមិនខាន។

ក្រោយមក យើងបានមកដល់ភ្នំដងរែក។ យើងចាប់ផ្តើមមានអាហារហូបចុកឡើងវិញ។ ទោះជាយ៉ាងនេះក្តី យើងបានប្រឈមទៅនឹងជំងឺហើមដៃជើង។ ដោយសារឆ្លងកាត់ការធ្វើដំណើរជាច្រើនខែ សម្លៀកបំពាក់របស់យើងនៅល្អតែខាងមុខប៉ុណ្ណោះ ចំណែកឯខាងក្រោយបានដាច់រហែកអស់ទៅហើយ ដោយសារតែទាក់ជាមួយព្រៃ និងរំកិលនៅលើថ្ម។

ក្រោយមក យើងបានទៅរស់នៅក្នុងជំរំអូរត្រាវ ដែលគ្រប់គ្រងដោយកម្លាំងកងទ័ពខ្មែរក្រហម។ ខ្ញុំទទួលបានរបបអាហារហូបចុកដោយមិនបាច់ធ្វើស្រែចម្ការនោះឡើយ។ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ យើងចាប់ផ្តើមរស់នៅតំបន់អន្លង់វែង ក្រោមការគ្រប់គ្រងរបស់តាម៉ុក។ នៅអន្លង់វែង យើងទទួលបានរបបអាហារផ្តល់ដោយតាម៉ុក។ យើងចាប់ផ្តើមកាប់ព្រៃធ្វើស្រែចម្ការ។ ខ្ញុំបានឆ្លងកាត់ភ្លើងសង្គ្រាមជាច្រើនដំណាក់បន្ថែមទៀត និងពេលខ្លះត្រូវដុតផ្ទះ និងជង្រុកស្រូវរបស់ខ្លួនឯងថែមទៀតផង។

មកទល់បច្ចុប្បន្ននេះក៏ខ្ញុំនៅតែលំបាកដោយសារពិការភាព និងជរាភាព។ ក្រោយពេលខ្ញុំធ្លាក់ខ្លួនពិការមក ខ្ញុំក៏មានអារម្មណ៍តូចចិត្តដែរ ប៉ុន្តែមិនដឹងធ្វើយ៉ាងណា បើនេះគឺជាកម្មផលរបស់ខ្ញុំ។ ខ្ញុំខំប្រឹងរស់ជាមួយមនុស្សជុំវិញខ្លួន។ ខ្ញុំមានតែខំកសាងបុណ្យកុសលទៅថ្ងៃមុខក្រែងបានប្រសើរជាងនេះ»។

# «អតីតកម្មាភិបាលជនជាតិដើមភាគតិចទំពួន ដែលធ្លាប់បម្រើការងារជាកងដឹកជញ្ជូននៅមន្ទីរ៨៧០»

ឡុង ដានី

មន្ទីរ៨៧០ គឺជាអង្គភាពដែលមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមរួមមាន៖ ប៉ុល ពត, នួន ជា និង ខៀវ សំផន បានជឿជាក់លើភាពស្មោះត្រង់ជនជាតិដើមភាគតិចនៅភូមិភាគឦសានៗ ដោយភាពជឿជាក់ ថ្នាក់ដឹកនាំខ្មែរក្រហមបានជ្រើសរើសយុវជនជនជាតិដើមភាគតិចនៅភូមិភាគឦសានមួយចំនួនមកបម្រើការងារនៅមន្ទីរ៨៧០ ជាកងការពាររបស់មេដឹកនាំជាន់ខ្ពស់តាំងពីតស៊ូប្រជាជាតិប្រជាធិបតេយ្យមុនឆ្នាំ១៩៧៥ អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការតស៊ូប្រឆាំងនឹងកងទ័ពវៀតណាមនៅតាមព្រំដែនកម្ពុជា-ថៃនៅក្រោយឆ្នាំ១៩៧៩។ អតីតកម្មាភិបាលជនជាតិដើមភាគតិចទំពួន នៅខេត្តរតនគិរី ដែលធ្លាប់បម្រើការងារជាកងដឹកជញ្ជូននៅមន្ទីរ៨៧០ម្នាក់ បានរៀបរាប់ពីការចូលបម្រើបដិវត្តន៍ខ្មែរក្រហម និងការជ្រើសរើសមកធ្វើការងារនៅមន្ទីរ៨៧០ នៃរបបខ្មែរក្រហមដូចខាងក្រោម៖



លី គេង អាយុ៧៦ឆ្នាំ គឺជាជនជាតិទំពួន សព្វថ្ងៃរស់នៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបាទឈ្មោះ លី គេង អាយុ៧៦ឆ្នាំ ជាជនជាតិទំពួនកើតនៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកអណ្ដូងមាស ខេត្តរតនគិរី។ ឪពុករបស់ខ្ញុំឈ្មោះ អៀយ និងម្ដាយឈ្មោះ អឿន ហើយខ្ញុំមានបងប្អូនចំនួនបួននាក់ គឺស្រីបីនាក់ និងប្រុសម្នាក់។ សព្វថ្ងៃនៅសល់តែពីរនាក់ប៉ុណ្ណោះ។ ប្រពន្ធខ្ញុំឈ្មោះ ហង្ស សាន មានស្រុកកំណើតនៅខេត្តព្រះវិហារ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ «ចាស់» (បច្ចុប្បន្នថ្នាក់ទី២)។ មុនពេលមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ខ្ញុំធ្វើជានីរសារឱ្យមេភូមិម៉ាលិក បានរយៈពេល២ទៅ៣ខែ។ បន្ទាប់ពីកើតមានរដ្ឋប្រហារឆ្នាំ១៩៧០ ខ្មែរក្រហមប្រកាសជ្រើសរើសកងទ័ព ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ព។ នៅពេលនោះក្នុងភូមិមានសភាពច្របូកច្របល់ទាហាន លន់ នល់ នៅខាងរតនគិរី, មណ្ឌលគិរី, ស្ទឹងត្រែង, ក្រចេះ បាក់ទ័ព។ ពេលនោះខ្មែរក្រហមបញ្ជូនខ្ញុំមកជាមួយកងទ័ពវៀតកុងដើម្បីវាយទាហាន លន់ នល់ នៅកំពង់ធំ។ សមរភូមិនៅកំពង់ធំ ហៅថា ចេនឡាទី១ និងចេនឡាទី២។ កាលនោះខ្ញុំមាននាទីត្រឹមតែជាយុទ្ធជននៅក្នុងអង្គភាព៣៩ ដែលមានបងសាន និងបងជ័យ គឺជាប្រធាន និងអនុប្រធាន។

បងសានគឺជាខ្មែរតស៊ូមកពីហាណូយ (ខ្មែរដែលត្រូវចាត់តាំងទៅបណ្តុះបណ្តាលនៅវៀតណាមខាងជើងក្នុងឆ្នាំ១៩៥៤) ដែលត្រឡប់មកដឹកនាំកងទ័ពអង្គភាព៣៩។

នៅចន្លោះឆ្នាំ១៩៧២ និង១៩៧៣ ពេលវាយនៅសមរភូមិចេនឡា ឈ្មោះ ខ្ញុំត្រូវបានខ្មែរក្រហមផ្លាស់មកខាងកងដឹកជញ្ជូនក្នុងអង្គភាព៨១ ចំណុះឱ្យមន្ទីរអង្គភាពខ្មែរក្រហមប្រចាំនៅតាមដងស្ទឹងជីនិតជាប់ព្រំប្រទល់ខេត្តកំពង់ចាម និងកំពង់ធំ។ អង្គភាព៨១មានបងវ៉ឹងជាប្រធាន។ ទីតាំងដឹកជញ្ជូនរបស់អង្គភាព៨១ នៅលើភ្នំតាមដងស្ទឹងជីនិត ទីតាំងនោះធ្លាប់មានយន្តហោះសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកម្តងនិងឆេះឃ្លាំងអស់។ ខ្ញុំនៅកងដឹកជញ្ជូន គឺមានឡានដែលជាជំនួយរបស់ចិន ប្រើសម្រាប់ដឹកសម្ភារ ពីព្រែកប្រសព្វមកចំណុចភ្នំបឹងកេត ស្រុកស្ទឹងត្រង់។ កងដឹកជញ្ជូនអង្គភាព៨១ ស្ថិតនៅក្នុងតំបន់រំដោះ។ ចំណែកទាហានលន់ នល់ មានតែនៅតាមទីរួមខេត្តកំពង់ចាម និងកំពង់ធំ។ ចំណែកនៅតាមជនបទមិនមានទាហានលន់ នល់ទេ។ នៅក្នុងអង្គភាពដឹកជញ្ជូន៨១ គឺមានកម្លាំងប្រមាណ២០០ទៅ៣០០នាក់ និងប្រើឡានដឹក ១០០គ្រឿង។ ទិសដៅដឹកជញ្ជូនមកពីខាងភូមិភាគបូព៌ា, កំពង់ចាម, ស្ទឹងត្រែង គឺដឹកជញ្ជូនមកពីព្រំដែនវៀតណាមទាំងអស់ ហើយរបស់ដែលដឹក រួមមានគ្រាប់កាំភ្លើងសម្រាប់យកមកវាយនៅភ្នំពេញ។ ពេលដឹកជញ្ជូនមកដាក់នៅទីស្នាក់ការ ប-២០នៅគីឡូលេខ ១០ (ក្នុងស្រុកស្ទឹងត្រង់)។ កន្លែងនោះក៏មានការបង្កបង្កើនផល ដូចជាដាំចេក, ដាំសណ្តែកដី, សណ្តែកសៀង និងដំឡូងជាដើម។ ខ្ញុំនៅក្នុងកងដឹកជញ្ជូនអង្គភាព ៨១ រហូតដល់ឆ្នាំ១៩៧៥ ក៏បានស្នើទៅអង្គការលើរៀបការជាមួយនារីដឹកជញ្ជូនដូចគ្នា តំណាងដោយប៉ង់ ជាប្រធានរៀបការឱ្យពួកខ្ញុំទាំងពីរនាក់។

នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពដឹកជញ្ជូន៨១ របស់ខ្ញុំ បានបែងចែកមួយចំនួនទៅខាងដឹកជញ្ជូនផ្លូវគោក ខ្លះទៅសេនាធិការ និងទៅតាមអង្គភាពផ្សេងៗ។ ចំណែកខ្ញុំ ត្រូវចាត់តាំងមកនៅមន្ទីរអង្គការ (មន្ទីរ៨៧០)។ ខ្ញុំបម្រើការងារនៅក្នុងមន្ទីរក-១២ (កងបើកបរ, ដឹកជញ្ជូន) ចំណុះឱ្យមន្ទីរ៨៧០ នៅទីក្រុងភ្នំពេញ ដែលមានឈ្មោះ មៀល ជាប្រធានមន្ទីរក-១២។ មន្ទីរក-១២ មានតួនាទីដឹកភ្ញៀវ ដឹកអីវ៉ាន់របស់មន្ទីរ៨៧០ នៅទីក្រុងភ្នំពេញទៅតាមភូមិភាគសម្រាប់ខាងសំណង់ធ្វើរោងចក្រ, ធ្វើអាង និងធ្វើទំនប់ប្រឡាយ ខ្មែរក្រហមត្រូវការសម្ភារអ្វី ខ្ញុំត្រូវដឹកទៅតាមការបញ្ជារបស់អង្គការ។ រាល់គ្រឿងសំណង់ទាំងអស់គឺមានកងទ័ពខ្មែរក្រហមដឹកពីកំពង់សោម យកមកភ្នំពេញ ហើយបានកងរបស់ខ្ញុំចែកចាយទៅតាមខេត្តផ្សេងៗ។

នៅក្នុងឆ្នាំ១៩៧៨ អង្គការចាប់ខ្លួន មៀល បន្ទាប់មកខ្មែរក្រហមផ្លាស់ខ្ញុំឱ្យទៅចិញ្ចឹមជ្រូកនៅតំបន់ព្រែកប្រា ក្រោយមកទៀតផ្លាស់ទៅនៅអរិយក្សត្រ និងជ្រោយចង្វារធ្វើការងារដាំបន្លែ។ ខ្ញុំបានដឹកនាំក្មេងៗដាំបន្លែសម្រាប់យកមកផ្គត់ផ្គង់ក្រសួងការបរទេស, តាមមន្ទីរផ្សេងៗ ជួនកាលហូបខ្លួនឯង ជួនកាលអង្គការបំផុសបំផុលថា អង្គការឱ្យដាំដុះខ្លួនឯង អង្គការឱ្យរស់នៅឯករាជ្យម្ចាស់ការ គឺការដាំតាំងពីថ្នាំជក់ គឺដាំខ្លួនឯងមួយចប់។ ប្រធានកងដាំបន្លែមានឈ្មោះ មួន (ស្រី)។ ខ្ញុំនៅដាំបន្លែរហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក៏រត់តែម្តង។ ពេលរត់នៅឆ្នាំ១៩៧៩ ខ្ញុំ និងប្រពន្ធបានរត់បែកគ្នា ព្រោះយើងទាំងពីរមិនបាននៅធ្វើការកន្លែងតែមួយ ដោយប្រពន្ធរបស់ខ្ញុំ និងកូន២នាក់ ត្រូវវៀតណាមកៀរយកទៅស្រុកកំណើត។ ប្រពន្ធខ្ញុំធ្វើការងារនៅកន្លែងមើលកុមារ ពេលរត់ទៅតាមផ្លូវ កូនខ្ញុំម្នាក់បានស្លាប់។ ចំណែកខ្ញុំជាប់នៅក្នុងព្រៃ ហើយរត់រហូតទៅដល់ស្រុកលាច។ ពេលធ្វើដំណើរមកពាក់កណ្តាលផ្លូវក៏អស់អង្ករ ខ្ញុំក៏បានដើររកត្រាវដូរមកស្ងោរហូប។ ពេលដែលរត់មកដល់ស្រុកលាច និងធ្លាក់ចូលទៅដល់ដីថៃខ្លងយ៉ៃ ក្រោយមកបានថៃដឹកយកមកឡូម ហើយក៏បានរៀបចំជាកងកម្លាំងឡើងវិញ។ ខ្ញុំស្ថិតនៅក្នុងកងការពាររបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមមាន៖

ប៉ុល ពត, នួន ជា និងខៀវ សំផន។ ចំណែកកងពលទី២ របស់តាវ៉ែន(កូនប្រសារតាម៉ុក) នៅការពារខ្សែត្រៀមខាងក្រោ។

នៅឆ្នាំ១៩៨១ ខ្ញុំត្រូវខ្មែរក្រហមឱ្យទៅនៅការពារឃ្លាំងលើភ្នំដងរែក។ ពេលនោះក៏បានទទួលដំណឹងថាប្រពន្ធរបស់ខ្ញុំរស់នៅស្រុកកំណើត។ ខ្ញុំបានឱ្យកម្លាំងរបស់ខ្ញុំចូលទៅភូមិកំណើតរបស់ប្រពន្ធខ្ញុំនៅខេត្តព្រះវិហារ ដើម្បីនាំប្រពន្ធខ្ញុំមក។ ពេលនោះប្រពន្ធខ្ញុំបានឱ្យបងប្អូនជូនមកជួបខ្ញុំ។ យើងបានជួបគ្នាក៏ត្រឡប់មករស់នៅអន្តភាពដឹកជញ្ជូននៅច-១ ក្បែរស្ទឹងមេទឹក (កាលពីមុននៅក្នុងទឹកដីកោះកុងបច្ចុប្បន្ននៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់)។ ខ្ញុំ និងទូ(ជនជាតិដើមភាគតិចព្រៅម្នាក់ទៀត) គឺជាអ្នកទទួលខុសត្រូវរួមក្នុងកងដឹកជញ្ជូន ដែលមានយុទ្ធជន យុទ្ធនារីចំនួន៧០០ទៅ៨០០នាក់។ ខ្ញុំនៅកងដឹកជញ្ជូនរហូតដល់ពេលសមាហរណកម្មក្នុងឆ្នាំ១៩៩៦។ បន្ទាប់ពីសមាហរណកម្មជាមួយរាជរដ្ឋាភិបាលរួច ខ្ញុំបានមករស់នៅប៉ៃលិន។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចូលខ្ញុំទៅក្នុងកងពល១៨ ដែលមានឈ្មោះ សុខ ឈាន គឺជាប្រធានកងពល។ បន្ទាប់មកខ្ញុំបានផ្លាស់មកជាមេបញ្ជាការរងកងពលតូចលេខ៥២ ប្រចាំនៅខេត្តប៉ៃលិន។



កងដឹកជញ្ជូននៅសហករណ៍ ដឹកជញ្ជូនគ្រាប់រំសេវតាមរទេះសេះយកទៅឱ្យកងទ័ពបដិវត្តន៍ខ្មែរក្រហមនៅសមរភូមិ ដែលកំពុងវាយតទល់ជាមួយកងទ័ពវៀតណាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សួស សារឿន ៖ កងសែងអ្នករបួស និងសាកសពកងទ័ពខ្មែរក្រហម

## សោម ប៊ុនថន

នៅអំឡុងឆ្នាំ១៩៧៧ ខ្មែរក្រហមមានជម្លោះជាមួយវៀតណាម និងមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅព្រំដែន ស្រុករមាសហែក ខេត្តស្វាយរៀង។ នៅពេលនោះ ប្រធានអង្គភាពរបស់ខ្ញុំបានជ្រើសរើសខ្ញុំ និងនារីផ្សេងទៀតពីកងចល័តជាបន្ទាន់ឱ្យជញ្ជូន គ្រាប់រំសេវផ្តល់ឱ្យកងទ័ពនៅសមរភូមិមុខ និងសែងកងទ័ពដែលរងរបួស និងស្លាប់ត្រឡប់មកសមរភូមិក្រោយវិញ។



សួស សារឿន សព្វថ្ងៃរស់នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សួស សារឿន កើតនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦០ នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែកខេត្តស្វាយរៀង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩នាក់ គឺប្រុស៣នាក់ និងស្រី៦នាក់។ នៅពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើការនៅកងចល័តនៅភូមិសេរីអោ ក្នុងឃុំត្រស់ ស្រុករមាសហែក។ ក្រោយមក ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យដឹកប្រឡាយនៅស្រុកស្វាយរៀង រហូតចប់ផែនការ ទើបដកខ្ញុំមកធ្វើការនៅឃុំអង្គប្រស្រែ និងឃុំអណ្តូងពោធិ៍ ស្រុករមាសហែកវិញ។ នៅឃុំអង្គប្រស្រែ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើជីលេខ១ គឺប្រមូលលាមកមនុស្សមកហាលឱ្យស្ងួត រួចហើយប្រមូលច្រកបាវទុកធ្វើជីដាក់ស្រែនៅឃុំគគីរ។ ក្រោយពីនោះ ខ្ញុំត្រូវដើរកាត់ដើមទន្ទ្រានខែត្រតាមព្រៃមកចិញ្ច្រាំដាក់ចូលក្នុងឡដើម្បីលាយធ្វើជីបន្ថែមទៀត។ នៅពេលរុកព្រៃកាត់ដើមទន្ទ្រានខែត្រម្តងៗ ខ្ញុំភ័យខ្លាចយ៉ាងខ្លាំង ព្រោះសម្បុរដង្កូវធំៗដែលតោងលើស្លឹកឈើ ហើយពេលឮស្នូរមនុស្សដើរម្តងៗវាបម្រះខ្លួននិងងើបឡើងយ៉ាងរហ័ស។ ដោយឡែកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឱ្យទៅរស់នៅ និងធ្វើការនៅភូមិតាម៉ិញ ឃុំក្រសាំង ស្រុករមាសហែក និងឪពុករបស់ខ្ញុំទៅធ្វើស្រែនៅស្រុកចន្ទ្រា ខេត្តស្វាយរៀង បន្ទាប់មកទើបផ្លាស់ទៅធ្វើការនៅស្រុកពញាក្រែក ខេត្តកំពង់ចាមវិញ។ ចំណែកប្អូនប្រុសរបស់ខ្ញុំពីរនាក់គឺឈ្មោះ សួស ហឿន អាយុ១២ឆ្នាំ និងឈ្មោះ សួស យឿន អាយុ១៥ឆ្នាំ បានចូលធ្វើកងទ័ពបដិវត្តន៍ខ្មែរក្រហម ហើយប្អូនតូចៗផ្សេងទៀតនៅកងកុមារ។

មិនយូរប៉ុន្មាន ប្រធានកងចល័តខ្មែរក្រហមបានហៅខ្ញុំ និងនារីកងចល័តឃុំគគីរមកប្រជុំ រួចហើយ

បញ្ជូនខ្ញុំ រួមជាមួយសមាជិកកងចល័តនៅឃុំគគីរ ប្រមាណ៣០នាក់ទៀតឱ្យទៅធ្វើការនិងទៅនៅតាមម្ដាយរបស់ខ្ញុំនៅឃុំក្រសាំង។ នៅវេលាម៉ោង៣រសៀល ខ្មែរក្រហមបានដឹកនាំកងចល័តរបស់ខ្ញុំដើរពីឃុំអណ្ដូងពោធិ៍ ទៅដល់វត្តក្រសាំងឃុំក្រសាំង នៅវេលាម៉ោង១រំលងអធ្រាត្រ។ ខ្ញុំដេកនៅវត្តក្រសាំងមួយយប់ ហើយព្រឹកបន្ទាប់ខ្មែរក្រហមបានជូនខ្ញុំទៅរកម្ដាយនៅតាមការដ្ឋានការងារ។ ខ្ញុំបានជួបម្ដាយរបស់ខ្ញុំនិងស្នាក់នៅជាមួយគាត់មួយយប់។ បន្ទាប់មកប្រធានសហករណ៍បានចាត់តាំងខ្ញុំឱ្យចូលធ្វើការនៅតាមអង្គភាពកងចល័តដែលខុះខាតកម្លាំងនៅក្នុងឃុំក្រសាំង។ ការងាររបស់ខ្ញុំគឺបាចទឹកបញ្ចូលស្រែ វែកកណ្ដាប់ និងដកស្ទូង។ ថ្ងៃមួយ ពេលដើរទៅធ្វើការ ខ្ញុំបានជួបប្អូនប្រុសពីរនាក់ដែលធ្វើជាកងទ័ពបដិវត្តន៍ខ្មែរក្រហមប្រចាំការនៅភូមិស្នាច់ ឃុំក្រសាំង ស្រុករមាសហែក។ ខ្ញុំបានសួរសុខទុក្ខប្អូន ប៉ុន្តែយើងមិនបានជជែកគ្នាយូរទេព្រោះខ្ញុំត្រូវទៅធ្វើការ។ ចាប់តាំងពីពេលនោះខ្ញុំបាត់ដំណឹងប្អូនប្រុស ទាំងពីរនាក់រហូត។

នៅឆ្នាំ១៩៧៦ ប្រធានអង្គភាពកងចល័តបានដកខ្ញុំចេញពីសហករណ៍ឃុំក្រសាំងឱ្យមកធ្វើការនៅទួលអង្គុញ, ព្រៃផ្ដៀក និង ភូមិពពេល ភូមិសេរីអោ ក្នុងឃុំត្រស់ វិញ។ ខ្ញុំនៅចាំថា នៅរដូវប្រាំង ខ្ញុំជីកប្រឡាយនៅការដ្ឋានម្រាក់ទាបរហូតដល់ម៉ោង១ភ្លឺ ហើយដោយសារហត់នឿយខ្លាំងពេកខ្ញុំដេកនៅលើភ្លឺប្រឡាយតែម្ដង។ នៅពេលការងារបន្ទាន់នៅរដូវធ្វើស្រែ ខ្ញុំត្រូវងើបទៅស្ទូងនៅវេលាម៉ោង៣ទៀបភ្លឺ ហើយសម្រាកនៅវេលាម៉ោង១១ព្រឹក។ ទោះបីធ្វើការច្រើនយ៉ាងណាក៏ដោយ ក៏ខ្ញុំទទួលបានរបបអាហារពីពេលតែប៉ុណ្ណោះគឺពេលថ្ងៃត្រង់ និងពេលល្ងាច។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនកងទ័ពមកពីខាងភូមិភាគនិរតីកាត់តាមឃុំត្រស់ សំដៅទៅកំពង់រការ និងកំពង់ក្ដី ព្រំដែនរវាងកម្ពុជា និងវៀតណាម ព្រោះខ្មែរក្រហមកំពុងមានជម្លោះព្រំដែនជាមួយវៀតណាម។ ដំបូងខ្ញុំសង្កេតឃើញកងទ័ពខ្មែរក្រហមទាំងនោះក្លៀវក្លាខ្លាំងណាស់ និងបានកាប់បុស្សីធ្វើជាក្បូនដិះឆ្លងស្ទឹងទៅវាយតទល់ជាមួយកងទ័ពវៀតណាមក្នុងទឹកដីវៀតណាមតែម្ដង។ នៅពេលនោះខ្មែរក្រហមក៏បានជ្រើសរើសខ្ញុំ និងនារីនៅកងចល័តឱ្យចូលក្នុងអង្គភាពដឹកជញ្ជូនគ្រាប់រំសេវ សម្ភារ ស្បៀងអាហារឱ្យកងទ័ពនៅសមរភូមិ។ ប៉ុន្តែមួយរយៈក្រោយមក កងទ័ពវៀតណាមបានវាយបកលើកងទ័ពខ្មែរក្រហម និងចូលដល់កំពង់រការ បណ្ដាលឱ្យកងទ័ពខ្មែរក្រហមរបួសនិងស្លាប់ជាច្រើននាក់ស្ទើររាល់ថ្ងៃ ដូច្នេះ ខាងអង្គភាពទ័ពបានបំពាក់កាំភ្លើងឱ្យខ្ញុំរួចហើយចាត់តាំងខ្ញុំឱ្យទៅសែងកងទ័ពខ្មែរក្រហមដែលរងរបួស និងស្លាប់នៅសមរភូមិមុខត្រឡប់មកសមរភូមិក្រោយវិញ។ ខ្ញុំទៅដល់វត្តត្រស់នៅពេលយប់ជ្រៅទៅហើយក៏នាំគ្នាឈប់សម្រាក។ មួយសន្ទុះក្រោយមក ខ្ញុំឮសំឡេងគ្រាប់ផ្លោង និងគ្រាប់កាំភ្លើងផ្ទុះឡើងយ៉ាងសន្ធាប់នៅសមរភូមិកំពង់រការ និងកំពង់ក្ដី។ ស្រាប់តែនៅវេលាម៉ោង១រំលងអធ្រាត្រ ខ្ញុំឃើញកងដឹកជញ្ជូនបានសែងកងទ័ពខ្មែរក្រហមដែលរងរបួស និងស្លាប់ប្រមាណ១០នាក់ពីសមរភូមិមកដល់វត្តត្រស់ដែរ។ បន្ទាប់មកប្រធានអង្គភាពដឹកជញ្ជូនបានស្នើខ្ញុំ និងនារីៗនៅក្នុងអង្គភាពឱ្យសែងសាកសព និងកងទ័ពរងរបួសទាំងនោះបន្តមកដាក់នៅវត្តត្រពាំងបន្ទាយ ក្នុងភូមិសេរីអោ ឃុំត្រស់ ស្រុករមាសហែក។ ខណៈនោះនារី៉ែន ដែលនៅវ័យក្មេងនៅឡើយ ហើយមានឈ្មោះសែងសាកសពកងទ័ពទាំងនោះភ័យខ្លាចខ្លាំងណាស់ ក៏ស្នើសុំប្រធានអង្គភាពនារីឱ្យប្ដូរខ្ញុំមកសែងសាកសពវិញព្រោះខ្ញុំមានវ័យច្រើន ហើយគាត់ទៅសែងកងទ័ពដែលរងរបួសវិញ។ ខ្ញុំបានយល់ព្រមជាមួយសំណើរនេះទាំងបង្ខំចិត្តព្រោះយប់ជ្រៅហើយខ្ញុំក៏ភ័យខ្លាចដែរ។ ខ្ញុំសែងសាកសពបណ្ដើរញ័រខ្លួនបណ្ដើរ។ ខ្ញុំសែងសពយកទៅកប់នៅខាងលិចវត្តត្រពាំងបន្ទាយ ស្ថិតនៅក្នុងឃុំត្រស់ ដោយនៅផ្នូរសាកសពនីមួយៗត្រូវបានអង្គភាពយោធាសរសេរឈ្មោះអ្នកស្លាប់ ភូមិឃុំស្រុកកំណើតលើក្ដារដើម្បី

ចំណាំ ប៉ុន្តែបច្ចុប្បន្នមិនមានសេសសល់ផ្ទះទាំងនោះទេ ព្រោះប្រជាជននាំគ្នាកាប់គាស់រុករានដីធ្វើស្រែអស់ហើយ ចំណែកកងទ័ពដែលរងរបួសត្រូវបានសែងទៅដាក់នៅមន្ទីរពេទ្យត្រពាំងបន្ទាយដើម្បីព្យាបាល។

រយៈពេលមួយសប្តាហ៍ក្រោយមក ខ្មែរក្រហមបានដកកងទ័ពពីសមរភូមិកំពង់រការ និងកំពង់ក្តី ជាប់ព្រំដែនវៀតណាម មកឈរជើងនៅក្នុងឃុំត្រស់វិញ រីឯវៀតណាមក៏ដកកងទ័ពថយចូលទៅក្នុងវិញដែរ ទើបការប្រយុទ្ធគ្នាស្ងប់ស្ងាត់។ បន្ទាប់មក អង្គភាពទ័ពរបស់ខ្មែរក្រហមក៏រំសាយ ខ្ញុំពីកងដឹកជញ្ជូនឱ្យមកធ្វើស្រែ និងលើកទំនប់នៅឃុំត្រស់។ ខ្ញុំធ្វើការនៅឃុំត្រស់រហូតដល់កងទ័ពវៀតណាមវាយចូលមកនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំរត់ភៀសខ្លួនសំដៅទៅអ្នកលឿងក្នុងខេត្តព្រៃវែងបានមួយរយៈខ្លី ក៏ត្រឡប់មកភូមិកំណើតវិញ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ កែវ ជឿន។ កាលនោះភ្ញៀវដែលចូលរួមពិធីមង្គលការខ្ញុំគ្មានលុយចងដៃទេ គឺមានតែអង្ករយកមកចងដៃប៉ុណ្ណោះ។ ខ្ញុំនិងប្តីបានប្រកបរបរធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ចំណែកកូនៗរបស់ខ្ញុំមានប្តីនិងប្រពន្ធ ហើយទៅរស់នៅកន្លែងផ្សេងៗ។



ផ្ទះរបស់ សួស សារឿន នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហែម ហ៊ិន ៖ ជនជាតិដើមភាគតិចព័រ និងជានីរសារប្រធានតំបន់៦ ភូមិភាគពាយ័ព្យ

ឡុង ដានី



ហែម ហ៊ិន និងប្រពន្ធ សព្វថ្ងៃរស់នៅក្នុងភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហែម ហ៊ិន ជនជាតិដើមភាគតិចព័រ និងជានីរសារ តាយ៉ន ប្រធានតំបន់៦ ភូមិភាគពាយ័ព្យនៃរបបខ្មែរក្រហម។ ហែម ហ៊ិន ចូលធ្វើនីរសារប្រធានតំបន់៦ តាមរយៈបងជីដូនមួយឈ្មោះ តាហង្ស មានតួនាទីជាគណៈឃុំពាមព្រួស នៅឆ្នាំ១៩៧៣។ នៅចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៥ មន្ទីរតំបន់៦ ស្ថិតនៅក្នុងព្រៃក្នុងភូមិព្រែកខាងត្បូង ឃុំលាច ស្រុកលាច តំបន់៦ ភូមិភាគពាយ័ព្យ។ ហែម ហ៊ិន បានផ្ដល់បទសម្ភាសន៍ និងចែករំលែកការងារជានីរសារនៅក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

## ប្រវត្តិក្រុមគ្រួសារ

ហែម ហ៊ិន ភេទប្រុស អាយុ៧១ឆ្នាំ ជាជនជាតិដើមភាគតិចព័រ និងមានស្រុកកំណើតនៅក្នុងភូមិទួលគ្រួស ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ បច្ចុប្បន្នរស់នៅក្នុងភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ហ៊ិន មានឪពុកឈ្មោះ ហ៊ូ ហែម អតីតទាហានបារាំង និងបានស្លាប់ដោយសារជំងឺនៅក្នុងឆ្នាំ១៩៦៤ និងម្ដាយឈ្មោះ ញឹក សាត់ ស្លាប់ក្នុងឆ្នាំ១៩៧៦ ដោយសារជំងឺ និងអត់អាហារ។ ហ៊ិន មានបងប្អូនបង្កើតចំនួន៤នាក់ ក្នុងនោះមានស្រី៣នាក់ ប៉ុន្តែបងប្អូនរបស់ ហ៊ិនស្លាប់ទាំងអស់នៅសល់តែ ហ៊ិន ម្នាក់។ ហ៊ិន ជាកូនទី៣នៅក្នុងគ្រួសារ។ ហ៊ិន មានប្រពន្ធទី១ឈ្មោះ ហ៊ួយ សារ៉ាន់ (ស្លាប់ដោយសារជំងឺនៅឆ្នាំ២០០២) និងប្រពន្ធទី២ឈ្មោះ ថៃ និន អាយុ៥៤ឆ្នាំ។ ហ៊ិន មានកូនសរុបចំនួន៩នាក់ ក្នុងនោះមានកូនស្រី៦នាក់។

## ប្រវត្តិសង្ខេបភូមិទួលគ្រួស និងឃុំស្រែតាំងយ៉

នៅក្នុងរបបសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ភូមិទួលគ្រួស គឺជាភូមិមួយក្នុងចំណោមភូមិទាំង៨ ទី១) ភូមិស្វែងប្រើស ទី២) ភូមិប្រកព្រាល ទី៣) ភូមិទួលគ្រួស ទី៤) ភូមិកំពង់ឡី ទី៥) ភូមិស្រែពាំង ទី៦) ភូមិអន្លង់ក្រូច ទី៧) ភូមិមាត់ព្រះ និងទី៨) ភូមិពាមព្រួស) នៃឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ឃុំស្រែតាំងយ៉ គឺជាទីកន្លែងដែលជនជាតិដើមភាគតិចព័ររស់នៅធ្វើចម្ការ អាស្រ័យអនុផលព្រៃឈើ បេះផ្លែក្រវាញ និងបរបាញ់សត្វដើម្បីចិញ្ចឹមជីវិតតាំងពីយូរលង់ណាស់មកហើយ។ ឃុំស្រែតាំងយ៉ គឺមានសុទ្ធតែប្រជាជនជនជាតិដើមភាគតិចព័ររស់នៅ។ បើតាមការប៉ាន់ប្រមាណរបស់ ហ៊ិន គឺឃុំស្រែតាំងយ៉ មានប្រជាជនដែលជាជនជាតិដើមភាគតិចព័រប្រមាណ៧០០គ្រួសារ និងចំនួនប្រជាជនសរុបចន្លោះពី៣០០០ ដល់៣៥០០នាក់។ ចំណែកភូមិទួលគ្រួស មានប្រជាជនជាជនជាតិភាគតិចព័រប្រមាណ៥០គ្រួសារ និងមានប្រជាជនសរុបចន្លោះពី១៥០ ទៅ ២០០ នាក់។

បន្ទាប់ពីសង្គ្រាមស៊ីវិលឆ្នាំ១៩៧០ ខ្មែរក្រហមបានប្តូរឈ្មោះឃុំស្រែតាំងយ៉ ទៅជាឃុំគិរីមានជ័យ និង ឃុំពាមព្រួស នៃស្រុកពាមព្រួស តំបន់៦ ភូមិភាគពាយ័ព្យ។ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនដែលជាជនជាតិដើមភាគតិចព័រទាំងអស់ចេញពីស្រុកពាមព្រួសទៅរស់នៅស្រុកលាចជំនួសវិញ។ ចំណែកស្រុកពាមព្រួស និងស្រុកផ្សេងៗនៃតំបន់៦ ត្រូវបានរំសាយចោលទាំងស្រុង។ បន្ទាប់ពីខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ឃុំស្រែតាំងយ៉បានក្លាយជាសមរភូមិក្តៅ រវាយប្រយុទ្ធគ្នារវាងភាគីខ្មែរក្រហម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម។ បន្ទាប់ពីកងទ័ពខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា និងទទួលបានសុខសន្តិភាពពេញលេញនៅក្នុងខែធ្នូ ឆ្នាំ១៩៩៨ ឃុំស្រែតាំងយ៉ និងភូមិទួលគ្រួសបានក្លាយជាចំណុចទួលគ្រួស និងចំណុចស្រែតាំងយ៉ នៃភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ រហូតមកដល់បច្ចុប្បន្ននេះ។

## ទាហាននៃរបបសង្គមរាស្ត្រនិយមប្រចាំនៅក្នុងឃុំស្រែតាំងយ៉

បន្ទាប់ពីទទួលឯករាជ្យពីអាណានិគមនិយមបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ សម្តេចព្រះ នរោត្តម សីហនុ បានបញ្ជូនទាហានមួយកងវរសេនាតូចដែលមានទាហានប្រមាណ៧០០នាក់ មកឈរជើងប្រចាំការការពារព្រំដែនកម្ពុជា-ថៃ ស្ថិតនៅក្នុងឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ មេបញ្ជាការកងវរសេនាតូចកាលនោះមានឈ្មោះ អ៊ុត សំអ៊ុល ពាក់ស័ក្តិ៤កន្ទុះ។ ទាហានក្នុងកងវរសេនាតូចទាំងអស់ត្រូវបានដាក់ពង្រាយតាមទីតាំងមួយចំនួនដូចជា៖ ទីបញ្ជាការកងវរសេនាតូចស្ថិតនៅក្នុងភូមិទួលគ្រួស និងភូមិប្រកព្រាល, ទាហានកងអនុសេនាធំត្រូវបានដាក់ឱ្យឈរជើងនៅភូមិក្រាំងម្កាក់ (វាលវែងអូរសោម) និង ទាហានមួយកងអនុសេនាធំប្រចាំការនៅភូមិពាមព្រួស និងភូមិអន្លង់ក្រូច។ ចំណែកមួយកងអនុសេនាធំទៀតបោះទីតាំងឈរជើងនៅភូមិក្រសាំងភ្លោ។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទាហានទាំងអស់ក្នុងកងវរសេនាតូចនេះត្រូវបានដកត្រឡប់មកទីរួមខេត្តពោធិ៍សាត់វិញ។

## ជីវិតកុមារភាព

នៅឆ្នាំ១៩៦៤ ហែម ហ៊ិនរស់នៅក្នុងភូមិទួលគ្រួស និងបានចូលរៀននៅសាលាបឋមសិក្សាភូមិទួលគ្រួស។ ខណៈពេលនោះ ហែម ហ៊ិន និងកូនចៅអ្នកភូមិទួលគ្រួស រៀនសូត្រ ក៏មានកូនចៅទាហានដែលមកឈរជើងប្រចាំការនៅឃុំស្រែតាំងយ៉ ចូលរៀនជាមួយដែរ។ នៅឆ្នាំ១៩៦៩ ហែម ហ៊ិន រៀនថ្នាក់ទី៧ (សង្គមចាស់) និងបានសម្រេចចិត្តឈប់រៀន ពីព្រោះត្រូវផ្លាស់ទៅរៀនបន្តនៅកន្លែងផ្សេងទៀត។ នៅក្នុងឆ្នាំ១៩៧០ ហែម ហ៊ិន បានចូលបួសក្នុងវត្តកែវជុំ ដែលមានព្រះចៅអធិការវត្ត

ព្រះនាម សាគតិ ស្ថិតក្នុងភូមិទួលគ្រួសរយៈពេលបួនវស្សា។ នៅចុងឆ្នាំ១៩៧៣ ហែម ហ៊ិនបានលាចាកសិក្ខាបទ និងស្ម័គ្រចិត្តចូលរួមចលនាខ្មែរក្រហម។

## ចលនាខ្មែរក្រហមបានចូលមកក្នុងភូមិទួលគ្រួស និងឃុំស្រែតាំងយ៉

បន្ទាប់ពីឧត្តមសេនីយ៍ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ ទាហានទាំងអស់ត្រូវបានដកចេញពីភូមិទួលគ្រួស និងឃុំស្រែតាំងយ៉ ទៅទីរួមខេត្តពោធិ៍សាត់វិញ។ នៅឆ្នាំ១៩៧១ កម្មាភិបាល និងកងទ័ពខ្មែរក្រហមជាច្រើននាក់បានចូលមកក្នុងភូមិទួលគ្រួស។ នៅខណៈពេលនោះ ខ្មែរក្រហមបានរៀបចំរចនាសម្ព័ន្ធភូមិឃុំសារជាថ្មី។ ភូមិទួលគ្រួស ស្ថិតនៅក្នុងឃុំពាមព្រួស ស្រុកពាមព្រួស តំបន់៦។ ប្រធានតំបន់៦ របស់ខ្មែរក្រហមដំបូងមានឈ្មោះតាទូច។ ពេលនោះតំបន់៦មានស្រុកចំនួន៣ ជាចំណុះ គឺស្រុកពាមព្រួស ស្រុកលាច និងស្រុកគរនម (បច្ចុប្បន្នស្រុកភ្នំក្រវាញ)។ គណៈស្រុកពាមព្រួសមានឈ្មោះ តាកើន មកពីស្រុកមោងឫស្សី ខេត្តបាត់ដំបង ជាជនជាតិខ្មែរ។ ស្រុកពាមព្រួសមានឃុំគិរីមានជ័យ និងឃុំពាមព្រួស។ មេឃុំពាមព្រួសមានឈ្មោះ សយ ផែន ជាជនជាតិដើមភាគតិចព័រ បន្ទាប់មក គណៈឃុំពាមព្រួសមានឈ្មោះ ហង្ស ជាជនជាតិដើមភាគតិចព័រ ត្រូវជាបងជីដូនមួយរបស់ ហែម ហ៊ិន ។ រីឯគណៈស្រុកលាច មានឈ្មោះ តាថោង ។ ស្រុកលាចមាន ឃុំរវៀង ចំណែកគណៈស្រុកគរនមមានឈ្មោះ តាបិន។ គណៈតំបន់៦ បន្ទាប់ពី តាទូច មានឈ្មោះ តាជូ។ ទីតាំងតំបន់៦ នៅអំឡុងពេល តាទូច និង តាជូ គ្រប់គ្រងស្ថិតក្នុងភូមិរវៀង ឃុំលាច ស្រុកភ្នំក្រវាញ។

នៅអំឡុងឆ្នាំ១៩៧១ ដល់ចុងឆ្នាំ១៩៧២ ខ្មែរក្រហមបានចាប់ផ្តើមរៀបចំចាត់ចែងឱ្យប្រជាជនជនជាតិដើមភាគតិចព័រជាក្រុមធ្វើស្រែប្រវាស់ដៃកម្រិតទាប ដោយឱ្យប្រជាជនយកវេនគ្នា គឺជួយធ្វើស្រែចម្ការដាំស្រូវទៅវិញទៅមក ប៉ុន្តែប្រមូលផលស្រូវ និងហូបបាយនៅតាមផ្ទះរៀងៗខ្លួន។ អំឡុងពេលជាមួយគ្នាក៏មានយន្តហោះសហរដ្ឋអាមេរិកបើកមកក្រវែលលើភូមិទួលគ្រួស លាន់ឮពេញភូមិជាញឹកញាប់ ហើយប្រជាជនក៏នាំគ្នាជីកត្រង់សេនៅតាមព្រៃសម្រាប់លាក់ខ្លួន។

ឆ្នាំ១៩៧៣ ឈ្មោះ តាយ៉ែនបានឡើងធ្វើប្រធានតំបន់៦ ជំនួស តាជូ។ តាយ៉ែន ជាជនជាតិលាវមកពីស្រុកសំឡូត ខេត្តបាត់ដំបង។ នៅពេលនោះមន្ទីរតំបន់៦ បានផ្លាស់ពីភូមិរវៀងមកស្ថិតនៅក្នុងព្រៃនៃភូមិព្រែកខាងត្បូង ឃុំលាច ស្រុកលាច តំបន់៦ ភូមិភាគពាយ័ព្យវិញ។

## ការចូលរួមជាមួយចលនាខ្មែរក្រហម

បន្ទាប់ពីផ្សឹកបានប្រហែលពីរសប្តាហ៍ ហែម ហ៊ិន បានស្ម័គ្រចិត្តចូលធ្វើជានីរសារ និងកងការពារ តាយ៉ែន នៅតំបន់៦ ក្នុងភូមិព្រែកខាងត្បូង (បច្ចុប្បន្នភូមិព្រែក២) ស្រុកភ្នំក្រវាញ។ នីរសារ និងកងការពារ តាយ៉ែន មានចំនួន៦នាក់រួមមាន៖ វឹត, លិប, ហឿន (ជនជាតិជង), ហ៊ិន និងអ្នកផ្សេងទៀតភ្លេចឈ្មោះ។ ការងារជានីរសារ និងកងការពារ គឺដាំបាយ ដាំទឹក តែ យាមល្បាត និងអមដំណើរ តាយ៉ែន ទៅត្រួតមើលកងទ័ពខ្មែរក្រហមប្រហែល៥០នាក់ ដែលប្រចាំការនៅភូមិទួលម្កាក់ និងអូរសោម (តំបន់វាលវែង) ព្រោះប្រទេសថៃមានបំណងចង់ចូលមកតំបន់វាលវែង។ នៅចន្លោះឆ្នាំ១៩៧៣ ដល់ដើមឆ្នាំ១៩៧៥ រៀងរាល់៦ខែម្តង ហែម ហ៊ិន និងនីរសារ ទាំងអស់បានធ្វើដំណើរថ្មើរជើងទៅជាមួយ តាយ៉ែន ដើម្បីទៅប្រជុំជាមួយគណៈភូមិភាគពាយ័ព្យ ដែលមានប្រធានភូមិភាគពាយ័ព្យឈ្មោះ តាកៅ (រស់ ញឹម) និងអនុភូមិភាគពាយ័ព្យឈ្មោះ តាប៉ែត (ហេង ទាវ) នៅក្រសាំងញោ ចន្លោះខ្នងភ្នំទាត់សី និងភ្នំក្រពើពីរ។ ក្នុងពេលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ តាយ៉ែន តែងតែជិះដំរី។ ចំណែក ហែម ហ៊ិន និងកងការពារផ្សេងៗទៀត គឺធ្វើដំណើរដោយថ្មើរជើង។ ពេលនោះ ហែម ហ៊ិន និងកងការពារមានកាំភ្លើងអឹមស៊ី និងកាំភ្លើងអាកាស្មាយបត់។

## ការផ្លាស់ប្តូរការងារ និងការរៀបការក្នុងរបបខ្មែរក្រហម

បន្ទាប់ពីខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដកតាយ៉ែន ចេញពីតំបន់៦ ឱ្យទៅកាន់អង្គភាពកងទ័ពភូមិភាគពាយ័ព្យនៅខាងប៉ៃលិន។ នៅពេលនោះនីរសារ និងកងការពារទាំងអស់ត្រូវបញ្ជូនទៅនៅក្នុងអង្គភាពយោធានៅប៉ៃលិនទាំងអស់ ប៉ុន្តែ ហែម ហ៊ិន បានសុំអនុញ្ញាតពី តាយ៉ែន ប្តូរទៅធ្វើការងារក្នុងរោងចក្រជួសជុល ឡានភូមិភាគពាយ័ព្យនៅពោធិ៍សាត់ជំនួសវិញ។ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ហែម ហ៊ិន នៅធ្វើជាងកូនជ្រុកម៉ាស៊ីន និងជួសជុលរថយន្តក្នុងរោងចក្រ ដែលមានមេជាងជាកម្មករចាស់ឈ្មោះ តាអាង គ្រូបង្រៀនផ្នែកជួសជុលរថយន្ត។ ប្រធានរោងចក្រជួសជុលរថយន្តភូមិភាគពាយ័ព្យនៅពោធិ៍សាត់មានឈ្មោះតាសាម។ នៅគ្រាដំបូងក្នុងរោងចក្រមានយុវជនប្រហែល៤០០នាក់ បានរៀនជួសជុល និងបើកបររថយន្ត។ បន្ទាប់ពីបានរៀនជួសជុល និងបើកបរចេះស្ទាត់ យុវជនទាំងនោះបានវិលត្រឡប់ទៅអង្គភាពដើមរៀងៗខ្លួនវិញ។ លុះក្រោយមករោងចក្រជួសជុលរថយន្តភូមិភាគពាយ័ព្យនៅពោធិ៍សាត់ នៅសល់យុវជនប្រមាណតែ៧០នាក់ប៉ុណ្ណោះ។

នៅពេលនោះគណៈភូមិភាគពាយ័ព្យរួមមាន៖ រស់ ញឹម តាកនហៅ តាគី និងប្រធានយុវជនឈ្មោះតាអាត។ នៅឆ្នាំ១៩៧៧ តាសាម ដែលជាប្រធានរោងចក្រជួសជុលរថយន្តត្រូវបានខ្មែរក្រហមចាប់ខ្លួននិងសម្លាប់ចោល។ បន្ទាប់មកឈ្មោះ ភឿន បានមកគ្រប់គ្រងនៅរោងចក្រជួសជុលរថយន្តជំនួស តាសាម។ ភឿន គឺជាអតីតនីរសារ របស់ តាកនហៅ តាគី។

នៅចុងឆ្នាំ១៩៧៧ ហែម ហ៊ិន ត្រូវបានខ្មែរក្រហមរៀបចំឱ្យមានគ្រួសារឈ្មោះ ហ៊ួយ សារ៉ាន់ គឺកម្មករនៅរោងចក្រកាត់ដេរនៅក្រុងពោធិ៍សាត់។ នៅក្នុងឆ្នាំ១៩៧៨ ប្រពន្ធរបស់ ហែម ហ៊ិន ត្រូវខ្មែរក្រហមបញ្ជូនមកធ្វើស្រែនៅសហករណ៍តាតាក្នុងក្រុងពោធិ៍សាត់។ អំឡុងពេលជាមួយគ្នា ហែម ហ៊ិន ធ្លាប់បានទៅចូលរួមប្រជុំជាមួយ តាកនហៅ តាគី នៅទីរួមខេត្តពោធិ៍សាត់។ តាកនហៅ តាគីបាននិយាយផ្តាំថា «យើងបន្តិចទៀត ត្រូវធ្វើសង្គមនិយមម្តងទៀត គឺបោសសម្អាតខ្មាំងចេញទាំងអស់» និងបានបន្តថា «ឡាវ និងវៀតណាមសុទ្ធតែស៊ីកន្ទក់ទេបងប្អូនកុំជឿយួនស៊ីកន្ទក់ដុះកន្ទុយ»។ ក្រោយពីបាត់ខ្លួន តាកនហៅ តាគី មានឈ្មោះ តាសារុន មកគ្រប់គ្រងតំបន់ពោធិ៍សាត់ និងរោងចក្រជួសជុលរថយន្តជំនួសវិញ។ តាសារុន គឺជាកម្មាភិបាលខ្មែរក្រហមដែលបានផ្លាស់មកពីតំបន់៣១ (ខេត្តកំពង់ឆ្នាំង) ភូមិភាគបស្ចិម មកគ្រប់គ្រងនៅតំបន់ពោធិ៍សាត់ នៅចុងឆ្នាំ១៩៧៧។

បន្ទាប់ពីតាសារុនមកដឹកនាំនៅពោធិ៍សាត់ក្នុងរោងចក្រជួសជុលរថយន្តមានការរឹតបន្តឹង និងបានប្រជុំប្រាប់ថា «សូមបងប្អូនប្រយ័ត្នកង់ប្រវត្តិសាស្ត្រវិល គឺមិនត្រឡប់ក្រោយវិញទេ»។ បន្ទាប់មក ហែម ហ៊ិនបានបើក ឡានទៅដឹកត្រីនៅទន្លេសាប ម្តុំឫស្សីមួយរយគុម្ពក្នុងស្រុកកណ្តៀង យកដាក់ក្នុងរោងចក្រជួសជុលរថយន្តខេត្តពោធិ៍សាត់ និងដឹកបន្តចេញទៅចែកតាមសហករណ៍ថែមទៀត។ ចុងក្រោយ ហែម ហ៊ិន បានប្តូរមកបើកឡានដឹកអំបិលដាក់តាមសហករណ៍វិញ។

## ការរត់គេចខ្លួនចេញពីអង្គភាព

នៅខែមិថុនា ឆ្នាំ១៩៧៨ ហែម ហ៊ិន បាននាំប្រពន្ធរត់ចេញពីអង្គភាពរោងចក្រជួសជុលរថយន្តនៅពោធិ៍សាត់ ទៅរស់នៅភូមិប្រហាល (បច្ចុប្បន្នស្រុកតាលោសែនជ័យ) ខេត្តពោធិ៍សាត់រយៈពេល៦ខែ។ នៅពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហែម ហ៊ិន និងភរិយាបានរត់ចេញពីភូមិប្រហាល ទៅរស់នៅស្រុកកំណើតខាងប្រពន្ធនៅឃុំរាំងទិល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់វិញ។ បន្ទាប់មក ហែម ហ៊ិន និងប្រពន្ធ បានចាកចេញពីឃុំរាំងទិល ត្រឡប់មករស់នៅឃុំតាលោ ឃុំផ្ទះរ៉ុង

វិញ។ បន្ទាប់មកទៀត ហែម ហ៊ិន បានបន្តនាំប្រពន្ធទៅរស់នៅភូមិបាក់ម៉ែក ឃុំថ្នាលទទឹង ស្រុកបាកាន។ នៅទីនោះ ហែម ហ៊ិន បានចូលធ្វើប្រធានកងឈ្លបឃុំថ្នាលទទឹង។

## ការចូលបម្រើកងទ័ព និងមន្ត្រីរដ្ឋការក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្រោយឆ្នាំ១៩៧៩

ឆ្នាំ១៩៨០ ហែម ហ៊ិន បានចេញពីកងឈ្លបឃុំថ្នាលទទឹងមកចូលបម្រើកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញ។ ហែម ហ៊ិន ស្ថិតនៅក្នុងកងវរសេនាតូចលេខ៣៧ ប្រចាំខេត្តពោធិ៍សាត់។ ប្រធានកងវរសេនាតូចលេខ៣៧មានឈ្មោះ គង់ ប៊ុនធឿន និងអនុប្រធានឈ្មោះ ខៀវ ឆេន។ នៅឆ្នាំ១៩៨២ ហែម ហ៊ិន បានសម្រេចឈប់ធ្វើកងទ័ព និងត្រឡប់មកផ្ទះរស់នៅជាមួយប្រពន្ធ និងកូននៅភូមិបាក់ម៉ែកវិញ។ ក្រោយមក ហែម ហ៊ិន បាននាំប្រពន្ធកូនត្រឡប់មករកបងប្អូននៅស្រុកភ្នំក្រវាញ និងបានជួបបងជីដូនមួយឈ្មោះ ហាក់ ហង្ស ធ្វើការនៅសាលាឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ។ នៅឆ្នាំ១៩៨៤ ហែម ហ៊ិន បានចូលធ្វើនគរបាលនៅភូមិព្រែក១ រយៈពេល៣ខែ។ ក្រោយមក ហែម ហ៊ិន បានប្តូរទៅធ្វើអនុប្រធាននគរបាលឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់រហូតដល់ឆ្នាំ១៩៩០។

នៅឆ្នាំ២០០០ ហែម ហ៊ិន បានត្រឡប់មករស់នៅចំណុចទួលគ្រួស ទួលកកោះបានរយៈពេលមួយឆ្នាំ ក៏ត្រូវត្រឡប់ទៅរស់នៅភូមិភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញវិញ។

នៅឆ្នាំ២០០២ ហែម ហ៊ិន បានឈរឈ្មោះធ្វើសមាជិកក្រុមប្រឹក្សាឃុំសំរោង ស្រុកភ្នំក្រវាញ រហូតមកដល់បច្ចុប្បន្ន។



ហែម ហ៊ិន អាយុ៧១ឆ្នាំ ជាជនជាតិដើមភាគតិចព័រ សព្វថ្ងៃរស់នៅក្នុងភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍

## គំនិតផ្តួចផ្តើមនៃការសះស្បើយៈ កន្លះសតវត្សរ៍បន្ទាប់ពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំ

## ក្មេងៗជំនាន់ក្រោយកម្ពុជា ៦០០,០០០ នាក់ សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ជារៀងរាល់សប្តាហ៍នៅក្នុងថ្នាក់រៀនរបស់ខ្លួន

ផេង ពងរ៉ាស៊ី



*លោក ផេង ពង្សរ៉ាស៊ី បង្រៀនសិស្សនៅតាមវិទ្យាល័យអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមវេទិកាអប់រំសាធារណអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាមួយសហគមន៍ចាមនៅក្នុងខេត្តកំពត ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៥ គឺជាខួបទី៥០ឆ្នាំ នៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ កាលពី៥០ឆ្នាំមុន ប្រជាជនកម្ពុជាប្រមាណ៧ លាននាក់ មិនត្រឹមតែបានជួបប្រទះទុក្ខលំបាកឥតឧបមា និរាសព្រាត់ប្រាស ធ្វើការហួសកម្លាំង ឈឺគ្មានថ្នាំព្យាបាល ហូបចុកមិនគ្រប់គ្រាន់ រងទារុណកម្ម និងសម្លាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាត់បង់ការអប់រំទាំងស្រុងទៀតផង។ ក្មេងៗដែលកំពុងស្ថិតនៅក្នុងវ័យសិក្សារៀនសូត្រ ត្រូវខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើស្រែ ធ្វើការនៅក្នុងកងចល័ត និងលើកទំនប់ជីកប្រឡាយ។

***សព្វថ្ងៃនេះ តើមានក្មេងៗជំនាន់ក្រោយកម្ពុជាប៉ុន្មាននាក់ សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមជារៀងរាល់សប្តាហ៍នៅក្នុងថ្នាក់រៀនរបស់ខ្លួន?***

រយៈពេល៥០ឆ្នាំក្រោយព្រឹត្តិការណ៍ដ៏ជូរចត់នេះ មានមនុស្សជំនាន់ក្រោយច្រើនជាង ៧ លាននាក់ បាននិងកំពុងរៀនសូត្រពីបទពិសោធន៍ និងព្រឹត្តិការណ៍កាលពី៥០ឆ្នាំមុនៗ យ៉ាងហោចណាស់ មានក្មេងៗជំនាន់ក្រោយកម្ពុជាប្រមាណ៦០០,០០០ នាក់ សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមជារៀងរាល់សប្តាហ៍នៅក្នុងថ្នាក់រៀនរបស់ខ្លួន។

នៅឆ្នាំ ២០០៩ នៅពេលដែលក្រសួងអប់រំ យុវជន និងកីឡា ដាក់បញ្ចូលកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ទៅក្នុងកម្មវិធីសិក្សាចំណោះទូទៅជាតិ មានគ្រូបង្រៀនប្រហែល ៥,០០០ នាក់ ដែលជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា អក្សរសាស្ត្រខ្មែរ និងសីលធម៌-ពលរដ្ឋវិទ្យា ទទួលបានការបណ្តុះបណ្តាលពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ពីវគ្គបណ្តុះបណ្តាលគ្រូបង្រៀន រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា។ ជាលទ្ធផល ដើម្បីធានាថាក្មេងៗជំនាន់ក្រោយកម្ពុជា ទាំងអស់ទទួលបានការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជារៀងរាល់ឆ្នាំមានសិស្សានុសិស្សរាប់រយពាន់នាក់ ទទួលបានការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលជាមុខវិជ្ជាមួយនៃការរៀនសូត្រប្រចាំថ្ងៃរបស់ខ្លួន។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីបើកសន្និសីទអន្តរជាតិលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៅសាលយុត្តិតេជោ ដែលជាសាលសវនាការមួយក្នុងចំណោមសាលសវនាការមួយចំនួនតូចនៅលើពិភពលោក បម្រើដល់កិច្ចការយុត្តិធម៌ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ នៅក្នុងសុន្ទរកថាគន្លឹះសម្រាប់ការបើកអង្គសន្និសីទនេះ សម្តេចមហាបវរធិបតី បានមានប្រសាសន៍ផ្តោតសំខាន់លើការលើកកម្ពស់ និងពង្រីកវិស័យអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបន្ថែមទៀត ដោយបានស្នើដល់គ្រប់ស្ថាប័នទាំងអស់ ទាំងស្ថាប័នយោធា និងស៊ីវិល ឱ្យចូលរួមផ្តល់ការអប់រំដល់ក្មេងៗជំនាន់ក្រោយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ សម្តេចធិបតី ក៏បានលើកទឹកចិត្តគ្រូបង្រៀនទាំងអស់ឱ្យចូលរួមជាកម្លាំង ដើម្បីផ្សព្វផ្សាយការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងសាលារៀនទូទាំងប្រទេស និងបានសង្កត់ធ្ងន់លើវិសាលភាពនៃការបញ្ជ្រាបមុខវិជ្ជាប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីផ្សេងៗ ដោយមិនសំដៅចំពោះតែការបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រតែមួយមុខប៉ុណ្ណោះទេ។ សម្តេចធិបតី មានប្រសាសន៍ថា «ការអប់រំពីអំពើប្រល័យពូជសាសន៍មិនចាំបាច់កំណត់ត្រឹមតែមេរៀនប្រវត្តិសាស្ត្រនោះទេ។ យើងក៏អាចបញ្ចូលទៅក្នុងមុខវិជ្ជាគ្រប់ប្រភេទចាប់ពីសីលធម៌ និងអក្សរសាស្ត្រខ្មែររហូតដល់ការសិក្សាពីភាពជាអ្នកដឹកនាំ និងការអភិវឌ្ឍន៍ជំនាញទន់ផ្សេងទៀតផងដែរ។ យើងក៏អាចស្វែងរកវិធីច្នៃប្រឌិតផ្សេងៗ ដើម្បីរៀបរាប់រឿងរ៉ាវពិបាកទាំងនេះទៅកាន់មនុស្សដែលមានវ័យ និងជំនាន់ផ្សេងគ្នារួមមាន តាមរយៈសិល្បៈ មាតិកាឌីជីថល ឬគំនូរជីវចលជាដើម»។ សុន្ទរកថារបស់សម្តេចធិបតីក៏បានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះធនធានមនុស្ស និងកាតព្វកិច្ចចូលរួមអនុវត្តសកម្មភាពនានាពីស្ថាប័នផ្សេងៗ ដែលអាចជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តសកម្មភាពអប់រំ និងផ្សព្វផ្សាយពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ដល់ក្មេងៗជំនាន់ក្រោយ ដែលនេះជាផែនការយុទ្ធសាស្ត្រមួយក្នុងចំណោមផែនការយុទ្ធសាស្ត្រដទៃទៀត នៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលអណត្តិទី៧។ សម្តេចធិបតីបានមានប្រសាសន៍បន្តថា «កាតព្វកិច្ចលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា។ មិនមែនតែ[ជាកាតព្វកិច្ច]របស់រាជរដ្ឋាភិបាលម្នាក់ឯងនោះទេ។ សន្និសីទថ្ងៃនេះ គឺជាគំរូដ៏ប្រសើរនៃកិច្ចសហប្រតិបត្តិ




កម្មវិធីសម្ពោធពាក្យស្លោកទាក់ទងនឹងការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅវិទ្យាល័យទួលទំពូង ក្នុងក្រុងភ្នំពេញ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការល្អ និងសាមគ្គីភាពរវាងតួអង្គពាក់ព័ន្ធផ្សេងៗ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលបានជួយរាជរដ្ឋាភិបាលក្នុងការដាក់បញ្ចូលការបង្រៀនអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ ទៅក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈ និងស្ថាប័ន និងសម្រាប់សកម្មភាពផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិដោយប្រើប្រាស់ប្រវត្តិសាស្ត្រដើម្បីត្រិះរិះពិចារណា និងបំផុសគំនិតសម្រាប់អនាគតកម្ពុជា»។

នៅដើមឆ្នាំ២០២៥ ក្រសួងអប់រំយុវជននិងកីឡា និងបញ្ជាការដ្ឋានយោធភូមិភាគ៤ កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទបានអនុវត្តកិច្ចការដ៏មានសារសំខាន់នេះ។ ក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ពផ្សាយសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី៦ថ្មី មានចំណងជើង «ខ្មែរ និងដំណើរឆ្ពោះទៅកាន់វិបុលភាព» ដើម្បីប្រើប្រាស់ជាឯកសារបំពេញបន្ថែមសម្រាប់ការសិក្សារបស់សិស្សនៅថ្នាក់ទី៦ លើមុខវិជ្ជាគោលប្រវត្តិវិទ្យា។ នេះគឺជាការឆ្លើយតបទៅនឹងចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍន៍ធនធានមនុស្សក្នុងការបង្កើនចំណេះដឹងពីប្រវត្តិសាស្ត្រជាតិ ស្របតាមការដាក់ចេញយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៧។

សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ នេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តការងារជាច្រើនក្នុងនោះការកែលម្អសៀវភៅសិក្សាគោលមុខវិជ្ជាភាសាខ្មែរ វិទ្យាសាស្ត្រ សិក្សាសង្គម ប្រវត្តិវិទ្យា ពលរដ្ឋវិទ្យា និង សេដ្ឋកិច្ចវិទ្យា គឺជាអាទិភាពចាំបាច់ក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សាសាធារណៈ និងឯកជនៗ សៀវភៅថ្មីនេះ ក៏មានជំពូកនៃប្រវត្តិសាស្ត្រខ្មែរក្រហមដែរ។ មេរៀនទាំងនោះឆ្លុះបញ្ចាំងឱ្យឃើញពីតថភាពជាក់ស្តែងដែលបានកើតឡើងនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សិស្សានុសិស្សនៅកម្រិតបឋមសិក្សា ជាពិសេសសិស្សថ្នាក់ទី៦ នឹងស្វែងយល់ជាបឋមពីរឿងរ៉ាវពិតទាំងនេះ។

បញ្ជាការដ្ឋានយោធភូមិភាគ៤ កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទបានស្នើសុំការសហការពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរៀបចំវគ្គអប់រំ



កម្មវិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់និស្សិតនៅសាកលវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្សព្វផ្សាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់មន្ត្រីយោធារបស់ខ្លួនដែលកំពុងបម្រើការនៅក្នុងអង្គភាព។ ការស្នើសុំនេះក្នុងគោលបំណងសំខាន់ៗចំនួនបីគឺ៖ ១) អភិវឌ្ឍន៍ចំណេះដឹងរបស់មន្ត្រីយោធាលើមាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីរារាំង ទប់ស្កាត់ជម្លោះ និងថែរក្សាសន្តិភាព។ ២) ធ្វើឱ្យប្រសើរឡើងនូវការត្រិះរិះពិចារណាស៊ីជម្រៅរបស់មន្ត្រីយោធា ដោយផ្អែកលើតថភាពប្រវត្តិសាស្ត្រ និង ៣) បង្កើនសមត្ថភាពមន្ត្រីយោធាដោយប្រើប្រាស់ប្រវត្តិសាស្ត្រជាមូលដ្ឋាន ដើម្បីសម្រួច និងតម្រង់ទិសក្នុងដំណើរការសម្រេចចិត្តផ្នែកយោធា ឱ្យបានសមស្របនាពេលអនាគត។

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានាក្នុងការជំរុញលើកកម្ពស់វិស័យអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម មានមនុស្សជំនាន់ក្រោយដែលជាសិស្សកំពុងសិក្សានៅកម្រិតសិក្សាទាំងបីកម្រិតជាង ៦០០,០០០ នាក់ បាននិងកំពុងសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅតាមសាលារៀនសាធារណៈ និងឯកជនក្នុងទូទាំងប្រទេសកម្ពុជា។ តាមស្ថិតិ និងសូចនាករអប់រំឆ្នាំសិក្សា ២០២៤-២០២៥ របស់ក្រសួងអប់រំ យុវជន និងកីឡា បានឱ្យដឹងថា សិស្សដែលកំពុងសិក្សានៅថ្នាក់ទី៩ និងថ្នាក់ទី១២ មានចំនួនសរុបជាង ៣០,០០០ នាក់ ហើយអ្នកទាំងនោះកំពុងទទួលបានការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមសាលារៀនរបស់ខ្លួន។ ចំណែកស្ថិតិសិស្សដែលកំពុងសិក្សានៅថ្នាក់ទី៦វិញ គឺមានចំនួនសរុបជិត ៣០០,០០០ នាក់។ អ្នកទាំងនោះនឹងទទួលបានការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈសៀវភៅសិក្សាប្រវត្តិវិទ្យាថ្មីនៅឆ្នាំសិក្សាជាបន្តបន្ទាប់ទៀត បន្ទាប់ពីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់ថ្នាក់ទី៦ នាពេលខាងមុខរួច។



សិស្សានុសិស្សនៅខេត្តបាត់ដំបង នៅឆ្នាំ១៩៨២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្មវិធីសម្ពោធពាក្យស្លោកទាក់ទងនឹងការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅវិទ្យាល័យទួលទំពូង ក្នុងក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៣-២០២៨ បានបង្ហាញពីកំណើនស្ថិតិសិស្សចុះឈ្មោះចូលរៀន នៅឆ្នាំ ២០២៦ រហូតដល់ឆ្នាំ ២០២៨ ថា សិស្សនៅកម្រិតបឋមសិក្សា នឹងកើនឡើងពីជាង ១,៨៣ លាននាក់នៅឆ្នាំ ២០២៤ ដល់ជាង ១,៨៦ លាននាក់នៅឆ្នាំ២០២៨។ ដូចគ្នានេះដែរ សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិ កើនឡើងពីជាង ៩២០,000 នាក់ នៅឆ្នាំ ២០២៤ ដល់ជាង ៩៦០,000 នាក់ នៅឆ្នាំ ២០២៨។ ដោយឡែក នៅឆ្នាំសិក្សា ២០២៤-២០២៥ នេះ ចំនួនសិស្សសរុបដែលកំពុងសិក្សានៅក្នុងកម្រិតបឋមសិក្សា មានចំនួនជាង ២,២ លាននាក់។ កំណើនសិក្សានេះនឹងជំរុញឱ្យការរំពឹកឡើងវិញ ការចែករំលែកបទពិសោធន៍ ការសិក្សារៀនសូត្រ ការស្រាវជ្រាវ ការចងក្រង ការបោះពុម្ព និងការបង្រៀនពីទិដ្ឋភាពជួរចត់នាសម័យខ្មែរក្រហម កាន់តែមានសន្ទុះកើនឡើងជាលំដាប់នៅឆ្នាំសិក្សានីមួយៗ ដែលការកើនឡើងនេះនឹងជួយដល់ការថែរក្សាសណ្ដាប់ធ្នាប់សង្គម និងការរារាំងអំពើហិង្សាឬអំពើប្រល័យពូជសាសន៍ កាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន។

ជារួម មេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គឺជាមេរៀនដែលមិនអាចខ្វះបានសម្រាប់មនុស្សជំនាន់ក្រោយកម្ពុជា ទាំងពេលបច្ចុប្បន្ន និងទៅអនាគត ដែលអ្នកទាំងនោះគឺជាសិស្សានុសិស្សនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្ដមសិក្សា ព្រមទាំងមន្ត្រីស៊ីវិល និងមន្ត្រីយោធានៅតាមស្ថាប័ននានាក្នុងព្រះរាជាណាចក្រកម្ពុជា។ ការសិក្សាពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហម មិនត្រឹមតែបង្កើនការចងចាំ និងមិនអាចបំភ្លេចបានពីប្រវត្តិសាស្ត្រពិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចថែរក្សាបាននូវសុខសុវត្ថិភាពសង្គម និងរារាំងអំពើឃោរឃៅមិនឱ្យវិលត្រឡប់មកវិញបានទៀតផង។

ក្នុងមួយឆ្នាំៗ ចាប់តាំងពីពេលនេះតទៅ ប្រទេសកម្ពុជា នឹងមានក្មេងៗជំនាន់ក្រោយដែលត្រូវជាចៅ និងចៅទួតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ច្រើនជាង ៦,000,000 នាក់ សិក្សាពីប្រវត្តិ-សាស្ត្រខ្មែរក្រហមនៅតាមសាលារៀនសាធារណៈ និងឯកជន ព្រមទាំងស្ថាប័ននានាដែលធ្វើកិច្ចការផ្សារលើវិស័យអប់រំពីអំពើប្រល័យពូជសាសន៍។ អ្នកទាំងនោះ នឹងក្លាយជាសសរដែកថែបដែលឈរយ៉ាងរឹងមាំក្នុងការរារាំងអំពើឃោរឃៅ និងធានាបាននូវសុខសន្តិភាពជានិរន្តរ៍នៅកម្ពុជា។

# អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) សហការជាមួយអង្គការនារីដើម្បីសន្តិភាព សាខាខេត្តស្ទឹងត្រែង រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «យេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី»

ស្រេង លីជា







អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) សហការជាមួយអង្គការនារីដើម្បីសន្តិភាព សាខាខេត្តស្ទឹងត្រែង រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «យេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី» នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្លួងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើរតួនាទីមិនត្រឹមតែជាមជ្ឈមណ្ឌលអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ និងវប្បធម៌ នោះទេប៉ុន្តែថែមទាំងជាមជ្ឈមណ្ឌលសហគមន៍ ឬសាលសហគមន៍ ដែលអាចឱ្យប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ប្រើប្រាស់ក្នុងកម្មវិធីជួបជុំ, គាំទ្រសហគមន៍ និងវេទិកាអប់រំផ្សព្វផ្សាយសហគមន៍។

នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥នេះ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្លួងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយអង្គការនារីដើម្បីសន្តិភាព ហៅកាត់ថា ន.ដ.ស (WPM) សាខាខេត្តស្ទឹងត្រែង រៀបចំវគ្គបណ្តុះបណ្តាល

ស្តីពី «យេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី»។ វគ្គបណ្តុះបណ្តាលនេះ មានអ្នកចូលរួមសរុបចំនួន១១នាក់ ក្នុងចំណោមនោះមានស្រី៦នាក់ និងប្រុស៥នាក់រស់នៅតាមបណ្តាកោះ មានដូចជា កោះល្វ, កោះឈើទាលតូច, កោះឈើទាលធំ, កោះហិប និងភូមិរើនសៀន ក្នុងស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ វេទិកានេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ការបណ្តុះបណ្តាលទៅកាន់អ្នកចូលរួមអំពីភាពជាគំរូរបស់អាណាព្យាបាលក្នុងការចិញ្ចឹមបីបាច់ និងអប់រំកូនៗ។ សកម្មភាពនេះគឺជាផ្នែកនៃគម្រោង «ក្មេងស្រីដឹកនាំសកម្មភាព» ដើម្បីលើកកម្ពស់ ក៏ដូចជាជំរុញជំនាញ និងភាពក្លាហានក្នុងការបង្ហាញភាពជាអ្នកដឹកនាំរបស់ស្ត្រី។

បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល កញ្ញា ឡោត សំណាង បុគ្គលិកសម្របសម្រួលរបស់អង្គការនារីដើម្បីសន្តិភាព ថ្លែងអំណរគុណចំពោះកិច្ចសហការរបស់អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្លួងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់ជាទីតាំង និងសម្ភារសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលនេះឡើង។ បន្ថែមពីលើនេះទៀត កញ្ញា ឡោត សំណាង ក៏កោតសរសើរចំពោះភាពស្រស់ស្អាតនៃស្ថាបត្យកម្មអគារ, ការរៀបចំដ៏ល្អរួមទាំងបន្ទប់ទឹក និងបណ្ណាល័យដែលរក្សាទុកនូវប្រភពធនធានសៀវភៅ និងឯកសារដ៏សម្បូរបែបសម្រាប់សាធារណជនអាន និងបង្កើនចំណេះដឹង។





អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) សហការជាមួយអង្គការនារីដើម្បីសន្តិភាព សាខាខេត្តស្ទឹងត្រែង រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «យេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី» នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំ វេទិកាពិភាក្សា និងស្វែងយល់ពី
## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ផេង ពង្សរ៉ាស៊ី








*នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ សិស្សានុសិស្សចំនួន១២នាក់ មកពីវិទ្យាល័យ សុខ អាន លាយបូរ មកចូលរួមវេទិកាថ្នាក់រៀន ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ បានទទួលស្វាគមន៍សិស្សានុសិស្សចំនួន១២នាក់ មកពីវិទ្យាល័យ សុខ អាន លាយបូរ ដែលបានស្នើសុំការពន្យល់បន្ថែមអំពីមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហម។ សិស្សានុសិស្សទាំងនេះ គឺធ្លាប់សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមម្តងរួចហើយ ជាមួយគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៅក្នុងថ្នាក់រៀនរបស់ខ្លួនកាលពីដើមខែឧសភា ឆ្នាំ២០២៥នេះ។

ជាកិច្ចចាប់ផ្តើម បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ បានណែនាំសិស្សានុសិស្សអំពីផ្ទាំងរូបថតពិព័រណ៍អចិន្ត្រៃយ៍ដែលដាក់តាំងបង្ហាញនៅក្នុងបរិវេណការិយាល័យ ទាំងខាងក្រៅ និងខាងក្នុង ព្រមទាំងឯកសារបោះពុម្ពខ្លះទៀតរៀបរាប់ពីហេតុការណ៍នៅក្នុងរបបខ្មែរក្រហម។ នៅក្នុងថ្នាក់រៀន បន្ទាប់ពីសិស្សបានបំពេញតារាងវាស់ស្ទង់ចំណេះដឹងរួចមក លោក ផេង ពង្សរ៉ាស៊ី បានដឹកនាំសិស្សពិភាក្សាអំពីចំណេះដឹងពីមុនរបស់សិស្សអំពី

ប្រវត្តិសាស្ត្រខ្មែរក្រហម។ បន្ទាប់មក លោក ដេង ពង្សរ៉ាស៊ី បានសួរទៅកាន់សិស្សានុសិស្សពីចម្លល់ទាំង ឡាយដែលចង់ពិភាក្សា អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ សិស្សម្នាក់ចង់ឱ្យពន្យល់បន្ថែមពីគោលនយោបាយ៨ចំណុច ដែលខ្មែរក្រហមបានអនុវត្តក្នុងពេលដែលខ្លួនគ្រប់គ្រងប្រទេស។ សិស្សម្នាក់ទៀតចង់ឱ្យមានការពិភាក្សាពីប្រវត្តិខ្មែរក្រហមតាំងពីថ្ងៃកកើត រហូតដល់ថ្ងៃដួលរលំ។ សិស្សជាច្រើននាក់ទៀត បានបង្ហាញពីការគាំទ្រសិស្សទាំងពីរនាក់ ព្រោះចង់ស្វែងយល់បន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានចាប់ផ្ដើមពិភាក្សាគឺ ទី១) ប្រវត្តិកកើតអំពើប្រល័យពូជសាសន៍ខ្មែរក្រហម និង ២) គោលការណ៍៨ ចំណុចរបស់ខ្មែរក្រហម។ ដោយសារមិនមានពេលវេលាគ្រប់គ្រាន់ លោក ដេង ពង្សរ៉ាស៊ី បានសង្ខេបចំណុចខ្លះៗ និងបានពន្យល់ក្បោះក្បាយតែចំណុចសំខាន់ៗតែប៉ុណ្ណោះ។ ជាមួយនឹងការពិភាក្សានេះ លោក ដេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារស្ដីអំពី កុមារកម្ពុជាក្រោយរបបខ្មែរក្រហម ឱ្យសិស្សទស្សនា និងធ្វើការពិភាក្សា ដោយបានប្រៀបធៀបពីជីវិតរស់នៅបច្ចុប្បន្ន និងអតីតកាល ព្រមទាំងបានបណ្ដុះគំនិតសិស្សឱ្យត្រិះរិះពិចារណាពីបុព្វហេតុនៃការកកើតរបបខ្មែរក្រហមដែលបានបំផ្លិចបំផ្លាញជីវិតកុមារ ការអប់រំ និងពីមូលហេតុដែលប្រទេសជាតិខិតខំរារាំងការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហមជាលើកទីពីរ។

ភ្ជាប់ជាមួយនឹងការពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម លោក ដេង ពង្សរ៉ាស៊ី ក៏បានបង្ហាញវិធីសាស្ត្រជាក់លាក់មួយចំនួនក្នុងការរារាំងអំពើហិង្សា និងអំពើប្រល័យពូជសាសន៍។ បទបង្ហាញនេះ គ្រាន់តែជាការផ្ដល់គំនិតដល់សិស្សក្នុងការស្វែងយល់បន្ថែមពីការចូលរួមថែរក្សាសណ្ដាប់ធ្នាប់សង្គម និងការអភិវឌ្ឍន៍ប្រទេសជាតិដោយគ្មានអំពើប្រល័យពូជសាសន៍។

**ក្រោយកិច្ចពិភាក្សាចប់ សិស្សានុសិស្សក៏បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖**

**គង់ ឈាងអ៊ីង** ភេទប្រុស អាយុ២១ឆ្នាំ មកពីវិទ្យាល័យ សុខ អាន លាយបូរ បានរៀបរាប់ថា ៖ «ខ្ញុំទទួលបានចំណេះដឹងបន្ថែម និងបានស្វែងយល់ពីមូលហេតុនៃការចាប់ផ្ដើមកើតមានបក្សកុម្មុយនីស្ដ និងដំណើរការបន្តបន្ទាប់រហូតបង្កើតបានរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យកកើតឡើង ប្រជាជនកម្ពុជាទទួលរងទុក្ខវេទនា ទាំងការរស់នៅ ការបង្អត់អាហារ គ្មានសម្លៀកបំពាក់គ្រប់គ្រាន់ និងគ្មានសិទ្ធិសេរីភាព។ ប្រជាជនត្រូវធ្វើការជាទម្ងន់ និងជួបបញ្ហាជាច្រើនទៀតដែលកើតមានឡើងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ ការចាប់ផ្ដើមនៃរបបខ្មែរក្រហមនេះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩។ ចំពោះខ្ញុំដើម្បីទប់ស្កាត់កុំឱ្យរបបកម្ពុជាប្រជាធិបតេយ្យវិលត្រឡប់មកវិញម្ដងទៀតនាពេលអនាគត ខ្ញុំមានវិធីសាស្ត្រមួយចំនួន គឺត្រូវលុបបំបាត់ការរើសអើងវណ្ណៈ ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ហើយលើកទឹកចិត្តដោះស្រាយបញ្ហាដោយសន្តិវិធី។ យើងមិនត្រូវប្រើអំពើហិង្សា និងត្រូវចេះស្រឡាញ់សន្តិភាព។ ខ្ញុំចង់ឱ្យមជ្ឈមណ្ឌលឯកសារខេត្តតាកែវនៅតែបន្តសកម្មភាពបែបនេះឱ្យបានច្រើន និងញឹកញាប់ ព្រោះអាចផ្ដល់ចំណេះដឹងជាច្រើនដល់អ្នកសិក្សាជំនាន់ថ្មី ដែលពុំទាន់ទទួលបានព័ត៌មាននិងយល់កាន់តែច្បាស់ពីរបបកម្ពុជាប្រជាធិបតេយ្យ»។

**ស៊ីម ចាន់សុវណ្ណាវុតី** ភេទស្រី អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ សុខ អាន លាយបូរ បានលើកឡើងថា៖ «ខ្ញុំបានដឹងពីថ្ងៃខែ ដែលមេដឹកនាំក្នុងរបបខ្មែរក្រហមចូលមកកាន់កាប់ប្រទេស បានដឹងពីគោលការណ៍ធំៗរបស់ខ្មែរក្រហម និងការសម្លាប់ប្រជាជនយ៉ាងសាហាវព្រៃផ្សៃ។ បន្ទាប់មក ខ្ញុំបានដឹងពីដើមកំណើតរបស់ខ្មែរក្រហម និងបានដឹងពីការដួលរលំនៃរបបខ្មែរក្រហម។ ខ្ញុំយល់ឃើញថា ខ្មែរក្រហមមានចក្ខុវិស័យ និងចង់ឱ្យប្រជាជនមានសិទ្ធិស្មើៗគ្នា ប៉ុន្តែខ្មែរក្រហម

ប្រកាន់យកជាតិនិយមជ្រុលហួសហេតុពេក។ ខ្ញុំមិនចង់ឱ្យរបបខ្មែរក្រហមកើតឡើងវិញម្តងទៀតទេ ហើយដើម្បីកុំឱ្យរបបនេះកើតឡើងវិញម្តងទៀត យើងត្រូវអប់រំដល់ក្មេងៗជំនាន់ក្រោយ ឱ្យយល់ដឹងពីផលវិបាកនៃរបបខ្មែរក្រហម។ បន្ទាប់ពីខ្ញុំបានឃើញទិដ្ឋភាពប្រជាជនដែលត្រូវខ្មែរក្រហមជម្លៀស ខ្ញុំមានអារម្មណ៍ថាអាណិតអាសូរ ហើយក៏មានអារម្មណ៍សប្បាយចិត្តដែលប្រជាជនអាចរស់មកដល់ពេលបច្ចុប្បន្ន។ ខ្ញុំគិតថា ការចូលរួមពិភាក្សាពីប្រវត្តិសាស្ត្របែបនេះគឺល្អ ព្រោះបានយល់ដឹងបន្ថែមពីការសិក្សានៅសាលា លើសពីនេះនៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ មានឯកសារជាច្រើនសម្រាប់សិក្សា និងស្វែងយល់បន្ថែម។ ចុងបញ្ចប់ ខ្ញុំចង់ឱ្យសិស្សចូលរួមទស្សនកិច្ចបែបនេះឱ្យបានញឹកញាប់ នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដើម្បីឱ្យសិស្សានុសិស្សបានសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមកាន់តែច្រើន។ នៅពេលខ្ញុំត្រឡប់មកសាលារៀនវិញ ខ្ញុំនឹងចែករំលែកចំណេះដឹងដែលទទួលបានរយៈពេលមួយព្រឹកនេះ ទៅកាន់មិត្តភក្តិដែលពុំបានចូលរួមវេទិកា»។

**អឿន ស្រីណាន** ភេទស្រី អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ សុខ អាន លាយបូរ បានឱ្យដឹងថា៖ «ខ្ញុំអាណិត និងតក់ស្លុត នៅពេលបានដឹងថាប្រជាជនរស់នៅរងទុក្ខវេទនា ទាំងការហូបចុក និងរស់នៅបែកបាក់គ្នា ថែមទាំងបាត់បង់សមាជិកគ្រួសារ។ ខ្ញុំមិនចង់ឱ្យរបបខ្មែរក្រហមកើតឡើងជាលើកទី២ទេ។ ប្រសិនបើខ្ញុំកើតក្នុងរបបខ្មែរក្រហម ខ្ញុំមិនបានសិក្សា និងមិនបានរស់ជុំគ្រួសារទេ ពីព្រោះត្រូវខ្មែរក្រហមបំបិទសិទ្ធិសេរីភាព។ យាយរបស់ខ្ញុំក៏ធ្លាប់ប្រាប់ថា គាត់ត្រូវបំបែកចេញឱ្យរស់នៅឆ្ងាយពីឪពុកម្តាយរបស់គាត់។ ខ្ញុំអាណិតដល់គាត់ជាខ្លាំង ព្រោះគាត់រស់នៅខ្វះភាពកក់ក្តៅពីឪពុកម្តាយ។ ចុងក្រោយ ខ្ញុំចង់ឱ្យកូនខ្មែរជំនាន់ក្រោយ ត្រូវខិតខំសិក្សា ហើយមិនត្រូវដើរជាន់ដានប្រវត្តិសាស្ត្រទេ។ សម្រាប់ខ្ញុំ ដើម្បីទប់ស្កាត់របបខ្មែរក្រហមកុំឱ្យកើតឡើងវិញម្តងទៀត យើងត្រូវចេះគិត និងពិចារណាមុនសម្រេចចិត្តធ្វើអ្វីមួយ និងត្រូវដោះស្រាយបញ្ហាដោយសន្តិវិធី ដោយលើកពីហេតុផលមកបង្ហាញឱ្យបានច្បាស់លាស់ជាមុនសិន»។





នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ សិស្សានុសិស្សចំនួន១២នាក់ មកពីវិទ្យាល័យ សុខ អាន លាយបូរ មកចូលរួមវេទិកាថ្នាក់រៀន ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)










# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!










# សុខ ភ័ណ្ឌ ៖ ម្ដាយខ្ញុំគិតថាខ្ញុំបានស្លាប់បាត់ទៅហើយ

លី សុខឃាង

សុខ ភ័ណ្ឌ ភេទស្រី អាយុ៦២ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិសោប ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ បច្ចុប្បន្ន សុខ ភ័ណ្ឌ រស់នៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ភ័ណ្ឌ បានរៀបរាប់ថា៖ «កាលពីកុមារភាព ខ្ញុំរស់នៅក្នុងស្រុកកំណើតជាមួយម្ដាយឪពុក។ គ្រួសារខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ ហើយមិនមានប្រកបរបរអ្វីផ្សេងក្រៅពីនេះទៀតទេ។ ខ្ញុំមិនបានរៀនសូត្រនៅសាលាទេ ដោយសារតែខ្ញុំធំដឹងក្ដីនៅក្នុងពេលសង្គ្រាម។ ប្រទេសជាតិចាប់ផ្ដើមមានចលាចល ដែលសាលារៀន ទីផ្សារ មន្ទីរពេទ្យ និងវត្តអារាមជាដើម ត្រូវបិទទ្វារ។ ខ្ញុំចងចាំបានច្បាស់ថា ការទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ខ្ញុំ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ និងបាក់បែកផ្ទះសម្បែងអស់ជាច្រើនខ្នង។



សុខ ភ័ណ្ឌ អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលដែលខ្ញុំមានអាយុ ១០ឆ្នាំ ខ្ញុំក៏ត្រូវឃ្លាតចេញពីក្រុមគ្រួសារ។ នៅជំនាន់នោះ កុមារត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅតាមសហករណ៍។ ខ្ញុំនិងកុមារតូចៗផ្សេងទៀត ត្រូវកាប់ទន្ទ្រានខែត្រ និងរើសអាចម៍គោ ដើម្បីធ្វើជីដាក់ស្រែ។ ក្រៅពីនេះ យើងក៏ដាំដំណាំបន្លែជាមួយមីងៗនៅរោងសហករណ៍។ ជារៀងរាល់ថ្ងៃ កុមារត្រូវចូលរួមការប្រជុំណែនាំឱ្យចេះតស៊ូ និងខិតខំធ្វើការឱ្យអស់ពីកម្លាំងកាយចិត្ត។ កុមារមិនត្រូវខ្ជិលច្រអូសឡើយ។ ខ្ញុំពិតជាមិនចង់ជួបការរស់នៅបែបនោះទេដោយសារតែខ្ញុំនៅក្មេង ហើយខ្ញុំពិតជាមានការនឹករឭកដល់ម្ដាយឪពុក និងបងប្អូនខ្ញុំយ៉ាងខ្លាំង។ ប៉ុន្តែ ខ្ញុំមិនហ៊ាននិយាយឬសុំទៅលេងផ្ទះនោះឡើយ។

នៅជំនាន់នោះ ផ្ទះមិនមានមនុស្សរស់នៅទេ។ សមាជិកម្នាក់ៗនៅគ្រួសារសុទ្ធសឹងតែមានការងាររៀងៗខ្លួននៅតាមសហករណ៍។ ពីមួយខែទៅមួយខែ ហើយពីមួយឆ្នាំទៅមួយឆ្នាំ ខ្ញុំមិនដែលបានជួបជុំគ្រួសារខ្ញុំវិញឡើយ។ ជារៀងរាល់យប់ ខ្ញុំតែងតែនឹករឭកដល់ក្រុមគ្រួសាររបស់ខ្ញុំ។ ខ្ញុំស្ថិតក្នុងវ័យកុមារ ដែលត្រូវការថែទាំពីឪពុកម្ដាយ។ ប៉ុន្តែខ្ញុំត្រូវបំបែកចេញពីគ្រួសារទៅវិញ។ កុមារខ្លះក៏បានលួចចេញទៅលេងផ្ទះដោយក្ដីនឹករឭកដល់ឪពុកម្ដាយ។ កុមារខ្លះត្រូវបានចាប់ខ្លួន ហើយក៏ត្រូវដាក់ពិន័យឱ្យធ្វើការច្រើនជាងកុមារដទៃ

ទៀតដែលតម្រូវឱ្យធ្វើរួចរាល់ក្នុងពេលមួយថ្ងៃ។ ចំណែកឯការហូបចុក ខ្ញុំទទួលបានមួយថ្ងៃចំនួនពីរពេលគឺ៖ នៅថ្ងៃត្រង់ និងរសៀល។ ខ្ញុំបានហូបបបរមួយកូនចានតែប៉ុណ្ណោះ។

នៅពេលដែលខ្ញុំមានវ័យជំទង់ ខ្ញុំក៏ត្រូវបញ្ជូនឱ្យទៅខាងកងចល័តធ្វើការលើកទំនប់ និងជីកប្រឡាយនៅតាមសហករណ៍ឆ្ងាយៗ។ ខ្ញុំទៅលើកទំនប់គោកម្ទូរ នៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ទំនប់ នៅជំនាន់នោះមានទំហំធំៗណាស់ ដែលអាចមានចំនួនរាប់រយហិកតា។ ការលើកទំនប់នីមួយៗមានរយៈពេលយូរឆ្នាំណាស់ទម្រាំតែរួចរាល់។ ខ្ញុំរស់នៅ និងធ្វើការលើកទំនប់ ដែលស្ថិតនៅក្បែរខ្ទមតូចៗនៅក្បែរៗទំនប់។ យើងស្នាក់នៅ និងធ្វើការនៅទីនោះដោយមិនមានផ្ទះធំៗសម្រាប់រស់នៅនោះទេ។ ចំណែកឯការហូបចុកវិញ យើងនាំគ្នាទៅរកម្ហូបរកត្រីតាមវាលស្រែនៅពេលដែលយើងទំនេរពីការងារ។ ពេលខ្លះក៏យើងរកបាន ហើយពេលខ្លះយើងក៏អត់ដែរ។

ខ្ញុំបានរស់នៅ និងធ្វើការនៅក្នុងកងចល័តរហូតដល់កងទ័ពវៀតណាមវាយចូលមក ហើយក៏មានការរំសាយសហករណ៍។ ប្រជាជនក៏រត់ទៅរកផ្ទះសម្បែង និងទៅរកបងប្អូននៅស្រុកកំណើតវិញ។ មួយចំនួនធំផ្សេងទៀតក៏នាំគ្នារត់ចូលព្រៃ ព្រោះខ្លួនមិនហ៊ានចូលទៅភូមិវិញ។ ប្រជាជនទាំងនោះបានឮការឃោសនាថា បើចូលទៅភូមិវិញ យួននឹងចាប់អារកជាមួយធាងត្នោត។ ដូច្នេះហើយ ប្រជាជនរួមទាំងកងទ័ពខ្មែរក្រហមក៏បានធ្វើដំណើរចេញពីព្រៃមួយទៅព្រៃមួយដើម្បីឆ្ពោះទៅគោលដៅគឺភ្នំដងរែកនៅតាមបណ្តោយព្រំដែន-កម្ពុជា-ថៃ។

ក្នុងអំឡុងពេលនៃការធ្វើដំណើរ ខ្ញុំមានតែខោអាវពីរសម្រាប់តែប៉ុណ្ណោះ ទុកគ្រាន់ផ្លាស់ប្តូរ ហើយមានអង្ករបន្តិចបន្តួចតាមខ្លួន។ ខ្ញុំត្រូវសម្រាកនៅតាមផ្លូវ ដោយយប់ត្រង់ណាដេកនៅត្រង់នោះ។ ខ្ញុំមិនចេះខ្លាចទេនៅជំនាន់នោះ។ ជួនកាល យើងធ្វើដំណើរជួបទាហានប៉ារ៉ា ហើយបាញ់គ្នាទៅវិញទៅមក។ អ្នកខ្លះក៏រងរបួស ចំណែកឯខ្លះទៀតក៏ស្លាប់។ ការធ្វើដំណើរនៅតាមផ្លូវជួបខបសគ្គណាស់ ប៉ុន្តែក៏សំណាងល្អរបស់ខ្ញុំដែរ ដែលខ្ញុំបានសុខសប្បាយរហូត។

បន្ទាប់ពីការធ្វើដំណើរអស់រយៈពេលជាច្រើនខែក៏បានទៅដល់លើភ្នំ ខ្ញុំរួមទាំងអ្នករួមដំណើរពិតជាមានការសប្បាយចិត្តជាខ្លាំង។ ខ្ញុំបានឃើញគេ ឃើញឯងផ្សេងៗទៀតជាច្រើនហើយ គិតថាខ្ញុំអស់ក្តីបារម្ភ និងការអត់ឃ្លានទៀតហើយ។ បន្ទាប់មកខ្ញុំរួមទាំងនារីផ្សេងៗទៀត ក៏ចូលជាកងនារីដឹកជញ្ជូន គ្រាប់ និងស្បៀងឱ្យទៅកងទ័ពនៅសមរភូមិមុខ។ ខ្ញុំបន្តរស់នៅជាមួយកងទ័ពខ្មែរក្រហមរហូតដល់ខ្ញុំមានគ្រួសារ។ ប្តីរបស់ខ្ញុំធ្វើជាគ្រូបង្រៀន។ ក្រោយពីរៀបការ ខ្ញុំបានបន្តធ្វើការបិតចំរូងដើម្បីផ្តល់ឱ្យកងទ័ពនៅសមរភូមិមុខ។ ការងារបិតចំរូងភាគច្រើនគឺជាបន្ទុករបស់មីងៗដែលជាប្រពន្ធកងទ័ព។ ខ្ញុំបិតចំរូងបានចំនួន៥០០ដើមទៅ១០០០ដើមក្នុងមួយថ្ងៃ។ ខ្ញុំមានផ្ទៃពោះ ប៉ុន្តែប្តីខ្ញុំមិនបានរស់នៅជាប់ជាមួយខ្ញុំនោះទេ។ យូរៗទើបប្តីខ្ញុំបានមកផ្ទះ ដោយសារគាត់ឈរជើងនៅឯសមរភូមិមុខ។ លុះដល់ឆ្នាំ១៩៩៨ តំបន់អន្លង់វែងបានចូលសមាហរណកម្មបង្រួបបង្រួមជាតិរវាងកងទ័ពរដ្ឋាភិបាលកម្ពុជា និងកងទ័ពខ្មែរក្រហម។ បន្ទាប់ពីទទួលបានសុខសន្តិភាពបានពេញលេញហើយ ប្រជាជនដែលជាអតីតកងទ័ពខ្មែរក្រហមបានបន្តរស់នៅក្នុងតំបន់នេះរហូតដល់បច្ចុប្បន្ន។

ក្នុងវ័យ៣៥ឆ្នាំ ខ្ញុំបានត្រឡប់ទៅស្រុកកំណើតដើម្បីទៅជួបម្តាយរបស់ខ្ញុំ។ នៅពេលដែលខ្ញុំបានជួបម្តាយខ្ញុំជាលើកដំបូង ម្តាយខ្ញុំមិនជឿថាខ្ញុំគឺជាកូនស្រីបង្កើតរបស់គាត់។ អ្នកដែលវិលត្រឡប់មកភូមិមុនៗបានប្រាប់ម្តាយខ្ញុំថា«ខ្ញុំបានស្លាប់បាត់ទៅហើយ»។ ម្តាយខ្ញុំបាននិយាយមកកាន់ខ្ញុំថា៖«កូនខ្ញុំស្លាប់បាត់ហើយ។ ឯងមកកុហកខ្ញុំធ្វើអ្វី។ ខ្ញុំបានពន្យល់គាត់ ហើយរំឭកឈ្មោះរបស់ខ្ញុំដែលគាត់តែងតែហៅខ្ញុំកាលពីក្មេងៗ។ នៅពេលនោះហើយ គាត់ចាប់ផ្តើមជឿជាក់ថាខ្ញុំពិតជាកូនស្រីគាត់មែន»។ នៅពេលនោះម្តាយខ្ញុំពិតជាសប្បាយចិត្តណាស់។ គាត់បានឱបខ្ញុំ។ គាត់និយាយបណ្តើរ ហើយទឹកភ្នែកគាត់ក៏បន្តហូរចុះបណ្តើរ៖ «ម្តាយនឹកស្មានតែកូនស្លាប់បាត់ទៅហើយ»។

បច្ចុប្បន្ននេះ ខ្ញុំគឺជាស្ត្រីមេម៉ាយ និងរស់នៅតែម្នាក់ឯង។ កូនៗរបស់ខ្ញុំមានគ្រួសារ និងធ្វើការនៅឆ្ងាយៗអស់ហើយ។ ខ្ញុំរស់នៅផ្ទះដើរស៊ីឈ្នួលបេះស្វាយ ច្រូតស្រូវ និងដកស្ទូង ដើម្បីបានថវិកាផ្គត់ផ្គង់ជីវិតភាពប្រចាំថ្ងៃ។

រូបក្របមុខ៖
ប្រជាជនកម្ពុជាមកជួបជុំគ្នា និងដើររកស្វែងសាច់ញាតិ ឪពុកម្តាយ បងប្អូន កូនចៅ
ដែលបែកបាក់គ្នាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
កម្មករជីកដីដើម្បីចាក់គ្រឹះសាងសង់ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម
នៅវាលពិឃាតជើងឯក ស្ថិតនៅក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ ក្រុងភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 305, May 2025

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.